01100604

E1/302.1/Old-2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-May-2015, 14:31
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៨៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ារី-ជេនី សាដាទិ

*(Ms. Marie-Jeanne SARDACHTI)*

លោកស្រី សែ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក ត្រាវិស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ត្រាវិស ហ្វារ | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក ឱ ហូ (2-TCW-836) | ខ្មែរ |
| លោក ប៊ុច សុខា (2-TCW-909) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឱ ហូ (2-TCW-836)**

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៣

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៣០

**ការសួរសំណួរទៅសាក្សី៖ លោក ប៊ិច សុខា (2-TCW-909)**

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៤៨

សួរដោយលោក ត្រាវិស ហ្វារ ផ្តើមពី ....................ទំព័រ ៥១

សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី ....................ទំព័រ ៦៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ឱ ហូ បញ្ចប់ ហើយនិងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-909 តាមប្រព័ន្ធសោតទស្សន៍។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។

លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក ឱ ហូ ហើយលោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ ហើយសាក្សីបន្ទាប់គឺសាក្សីដែលមានរហស្សនាម 2-TCW-909។ សាក្សីរូបនេះនឹងផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនោះទេ។ សាក្សីបានធ្វើសម្បថរួចហើយ មុននឹងផ្តល់សក្ខីកម្ម។

សូមអរគុណលោកប្រធាន។

[០៩:០៣:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា

ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនចាប់ចោទ នួន ជា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥។ ដោយមេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការបង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មានអាការៈវិលមុខឈឺចង្កេះជាប្រចាំ មិនអាចអង្គុយយូរបាន និងផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៥:០០]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យលោក នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនក្រុមមេធាវីការពារក្ដី ដែលដំបូងនេះក្រុមមេធាវីការពារក្ដីលោក នួន ជា មានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ខិ ហ្វូ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

សូមជម្រាបសួរលោកចៅក្រម លោក លោកស្រីចៅក្រម សូមជម្រាបភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី! ខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរដល់លោក ក្រោយពីលោកបានឆ្លើយទៅជាមួយនឹងភាគីនានាកាលពីម្សិលមិញ។ ខ្ញុំសូមចាប់ផ្តើមសួរលោកអំពីសំណួរទាក់ទងទៅនឹងពេលវេលាដែលលោកធ្វើជាមេភូមិ ហើយលោកបានទទួលសំណើមួយឲ្យធ្វើការជ្រើសរើសពលកម្ម ពលករ ឲ្យទៅធ្វើការសាងសង់ទំនប់១មករា។ តើលោកចាំទេ តើអ្នកណាជាអ្នកស្នើមកលោកឲ្យជ្រើសរើសប្រជាជនចេញពីក្នុងភូមិរបស់លោកនោះ?

**លោក ឱ ហួ៖**

**ឆ៖** ជិន អ្នកដែលស្នើកម្លាំងនោះ គឺមេរបស់ខ្ញុំ គឺគណៈកម្មការឃុំ គាត់ទទួលពីលើមក។

**ស៖** តើលោកចាំដែរឬទេ ថាតើនៅក្នុងខែណានៃឆ្នាំ៧៦ គឺនៅក្នុងខែណាដែលគាត់បានដាក់សំណើមកលោក ក្នុងនាមលោកជាមេភូមិនោះ?

**ឆ៖** សំណើដែលគាត់ស្នើនោះគឺខែ១០ គេយកខាងចល័តទៅមុនគេ។ ខាងខែ១០នោះ គេយកចល័ត ដែលកម្លាំងមាំៗទៅមុន ប្រហែលជាមួយភូមិ៣០នាក់ទៅមុនសិន ព្រោះការងារនោះ វាគ្រាន់តែជញ្ជូនសម្រាស់ជញ្ជូនអីយកដុតយកអីទេ។ ឯកម្លាំងធំនៅច្រូតស្រូវសិន។

[០៩:០៨:២៣]

**ស៖** តើខ្ញុំអាចនិយាយបានទេថា គឺថាជាដំបូងមនុស្ស៣០នាក់មកពីភូមិលោក គឺមកពីកងចល័តត្រូវបញ្ជូនទៅធ្វើការនៅទំនប់ ហើយនៅពេលក្រោយបន្ទាប់មកទៀតគឺមានប្រជាជនបន្ថែមទៀត ត្រូវបានគេបញ្ជូនទៅធ្វើនៅទំនប់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនទាន។

**ស៖** តើលោកអាចប្រាប់បានទេ តើសរុបទាំងអស់ប្រជាជនប៉ុន្មាន -- តើមានប្រជាជនប៉ុន្មាននាក់មកពីភូមិរបស់លោកដែលបញ្ជូនទៅធ្វើការនៅទំនប់១មករា សរុបទាំងអស់?

**ឆ៖** កម្លាំងវ័យកណ្តាលប្រហែលជា១០០នាក់ បើលើសៗបន្តិចបន្តួច តែកម្លាំងចល័ត វាប្រហែលជារវាង៧០នាក់ ទៅ៨០នាក់ប៉ុណ្ណឹងទេ មួយភូមិខ្ញុំ។

**ស៖** បើអ៊ីចឹងខ្ញុំអាចនិយាយបានទេថា ក្នុងរយៈពេល៧ ទៅ៨ខែហ្នឹង គឺមានមនុស្សប្រហែលជា

ជិត២០០នាក់មកពីភូមិរបស់លោកបានចូលរួមនៅក្នុងការកសាងទំនប់។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវណាស់ទាន។

**ស៖** តើលោកចាំទេ តើលោកមានលក្ខណៈវិនិច្ឆ័យអ្វីដែរនៅពេលដែលលោកជ្រើសរើសមនុស្សចេញពីកងទាំងកងចល័ត និងមិនកងចល័តរបស់លោកហ្នឹងយកទៅទីនោះ?

**ឆ៖** នែ៎ ទានថាម្តងទៀតមើល៍ ខ្ញុំស្តាប់មិនទាន់បាន។

**ស៖** លោកបាននិយាយថា គេជ្រើសរើសមនុស្សមកពីកងចល័ត ហើយមនុស្សមកពីភូមិរបស់លោកក៏គេជ្រើសរើសយកទៅដែរ។ តើលោកចាំទេ តើលោកមាន -- តើលោកជ្រើសរើស ឬក៏ប្រមូលមនុស្សហ្នឹងដោយផ្អែកទៅលើលក្ខខណ្ឌអីដែរ? ឧទាហរណ៍ លក្ខខណ្ឌអាយុ ឬក៏កម្លាំង តើលោកចាំទេ តើលោកមានផ្អែកទៅលើលក្ខខណ្ឌអីខ្លះដើម្បីរើសមនុស្សចេញពីភូមិរបស់លោក និងចេញពីកងចល័តនោះ?

[០៩:១១:១៣]

**ឆ៖** បាទ លោកអ្នកដែលទៅធ្វើការងារនៅទំនប់១មករាហ្នឹង គឺមនុស្សដែលមានកម្លាំងពលំពេញបរិបូរ មនុស្សចាស់មិនបានទៅទេ គាត់នៅធ្វើបង្គីឯភូមិ ឯអ្នកដែលមានកម្លាំងគេទៅធ្វើ។

**ស៖** សូមអរគុណលោក។ ខ្ញុំចង់បញ្ជាក់បន្តិចទៅលើចំណុចមួយ កាលពីម្សិលមិញ គឺនិយាយអំពីចំនួនមនុស្ស១០០នាក់។ គឺមនុស្ស១០០នាក់ដែលលោកគ្រប់គ្រង ប៉ុន្តែនៅពេលដែលខ្ញុំអានកំណត់ហេតុស្តាប់ចម្លើយដែលលោកផ្តល់ជាមួយនឹងអ្នកស៊ើបអង្កេត គឺលោកបាននិយាយថា នៅពេលដែលលោកធ្វើការនៅការដ្ឋានហ្នឹងលោកគ្រប់គ្រងមនុស្សប្រហែលជា២០នាក់ប៉ុណ្ណោះ។ តើវាជាការត្រឹមត្រូវទេដែលថា នៅពេលដែលលោកធ្វើការនៅទំនប់១មករា លោកគ្រប់គ្រងមនុស្សតែ២០នាក់ ប៉ុន្តែនៅពេលដែលលោកជ្រើសរើសមនុស្សចេញពីភូមិ និងកងចល័ត គឺលោកជ្រើសរើសមនុស្សដល់រាប់រយនាក់?

**ឆ៖** ទាន ការដែលយើងរើសចំនួនប៉ុណ្ណឹងមែន ដល់តែទៅការដ្ឋានយើងចែកគ្នាជាក្រុមៗទៀតទាន មិនមែនក្តាប់តែឯង មិនមែនមើលតែឯងទេ។ គឺលោកដទៃទៀត លោកជួយមើល ហើយក៏ធ្វើការជាមួយនឹងក្រុមហ្នឹង។ ក្នុង២០នាក់ដែលខ្ញុំត្រួតត្រាហ្នឹង ខ្ញុំក៏រែកដីជាមួយគេទាំង២០នាក់ហ្នឹងដែរ។ អ្នកធ្វើការដទៃទៀតក៏គេធ្វើការអ៊ីចឹងដែរ ដល់រួចទៅយើងជួបគ្នាទៅណា។ ថ្ងៃពេលបាយយើងជួបគ្នាអ្នកដែលធ្វើការហ្នឹង។

[០៩:១៣:៣៤]

**ស៖** ខ្ញុំយល់លោក។ អ៊ីចឹងខ្ញុំអាចនិយាយបានថា ក្រៅពីលោកដែលគ្រប់គ្រងទៅលើមនុស្ស២០នាក់ហ្នឹង គឺមានមនុស្សប្រហែលជា ៩នាក់ទៀតគ្រប់គ្រងទៅលើមនុស្សដទៃទៀត គឺថាធ្វើការជាមួយលោក គ្រប់គ្រងទៅមនុស្សប្រហែលជា ១០០-១២០នាក់ទៀត។ ប្រសិនបើខ្ញុំគណនាអ៊ីចឹង វាត្រឹមត្រូវដែរឬទេ?

**ឆ៖** យើងទៅពីភូមិវា ១០០នាក់មែន ទៅដល់ណោះយើងចែកគ្នាជាប្រាំក្រុមណ៎ាទាន។ គឺមួយក្រុមមានមេមួយៗ ២០នាក់ៗគ្រប់គ្នាទៅ។ ហើយធ្វើនៅជិតៗគ្នាទុំងឯងទាន។

**ស៖** ខ្ញុំយល់ ថាតើលោកចាំទេ តើអ្នកគ្រប់គ្រងបួននាក់ទៀតនោះជានរណា? ខ្ញុំចង់សួរថាមនុស្សបួននាក់ទៀតដែលធ្វើការគ្រប់គ្រងទៅលើមនុស្សដែលកសាងទំនប់ ដែលយកចេញពីភូមិហ្នឹង តើបួននាក់ទៀតហ្នឹងគាត់ជានរណាដែរ?

**ឆ៖** ទានប្រុស មនុស្សដែលបួននាក់ទៀត គឺមេក្រុមរបស់ខ្ញុំហ្នឹងឯង មេក្រុមពីភូមិទៅ។ យើងអាចថាឲ្យគាត់មើលការខុសត្រូវបានហើយ។

**ស៖** តើលោកចាំឈ្មោះមនុស្សបួននាក់ទៀតដែលជាមេក្រុម ដែលលោកនិយាយអំមិញហ្នឹងទេ?

**ឆ៖** មេក្រុមដែលគាត់ធ្វើហ្នឹង ខ្ញុំចាំឈ្មោះខ្លះ មិនចាំខ្លះដែរទាន។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេថាបួននាក់ហ្នឹង មេក្រុមបួននាក់ហ្នឹង មានឈ្មោះអ្វីខ្លះ?

**ឆ៖** ឈ្មោះលោក នេត្រ, ឈ្មោះលោក ឈៀង។ បីនាក់ទៀតខ្ញុំភ្លេចហើយ។ ប៉ុនអស់លោកទាំងអស់នោះបានអនិច្ចកម្មទៅបាត់ហើយដោយជរាពាធរបស់គាត់។

[០៩:១៦:៤០]

**ស៖** តើពួកលោកទាំងប្រាំនាក់គឺជាអ្នកធ្វើការសម្រេចចិត្តទាក់ទងទៅនឹងការងារក្នុងក្រុមមនុស្ស ១០០ នាក់អ៊ីចឹងមែនទេ?

**ឆ៖** យើងទាំងអស់គ្នាហ្នឹងស្ម័គ្រចិត្តទៅធ្វើតែម្តង ស្ម័គ្រចិត្តទៅធ្វើទាំងអស់គ្នាតាមការចាត់តាំងរបស់អង្គការតើ។

**ស៖** ខ្ញុំយល់ថាពួកលោកទាំងប្រាំនាក់ហ្នឹងស្ម័គ្រចិត្តទៅធ្វើការ ទៅធ្វើជាមេក្រុម ប៉ុន្តែថាតើពួកលោកទាំងប្រាំនាក់ហ្នឹង ជាអ្នកសម្រេចចិត្តដោយខ្លួនឯងថាដឹកនាំក្រុម ឬក៏គ្រប់គ្រងក្រុមនៅក្នុងការងារហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំទាំងអស់ហ្នឹងក៏ស្ម័គ្រចិត្តនឹងទៅ ធ្វើការងារប្រឡាយហ្នឹងដែរទាន។

[០៩:១៨:០០]

**សៈ** ខ្ញុំយល់ ប៉ុន្តែឧទាហរណ៍ថានៅពេលដែលចេញការណែនាំទៅដល់មនុស្ស ១០០នាក់មកពីភូមិរបស់លោកហ្នឹង តើនៅពេលដែលធ្វើការសម្រេចចេញការណែនាំហ្នឹង ពួកលោកទាំងប្រាំនាក់ហ្នឹងពិភាក្សាគ្នាក្នុងការសម្រេចការចេញ ការណែនាំហ្នឹង ដើម្បីអនុវត្តទាំងអស់គ្នា ឬក៏យ៉ាងម៉េចដែរ?

**ឆះ** បើល្ងាចឡើងគេជួបគ្នាទាន ល្ងាចឡើងគេជួបគ្នាទៅ យើងនិយាយគ្នាៗទាំងប្រាំនាក់។ ប៉ុន្តែជួនកាលក៏អ្នកធ្វើការហ្នឹងគាត់ស្តាប់ដែរ អ្នកដែលជាកម្មករទាំងអស់គ្នាក៏ស្តាប់ដែរ ប៉ុនថាការដែលយើងត្រូវជួបគ្នាគឺប្រាំនាក់ដែលជាមេក្រុមហ្នឹងឯង មើលការខុសត្រូវទៅលើពួកពលកររបស់យើង។

**សៈ** តើលោកធ្លាប់មានជម្លោះ ឬក៏មានទំនាស់ជាមួយមេក្រុមប្អូននាក់ផ្សេងទៀតដែរឬទេ? តើលោកអាចប្រាប់ៗបានទេថាតើពួកលោកទាំងប្រាំនាក់ធ្វើការជាមួយគ្នាហ្នឹងដោយរបៀបណា?

**ឆះ** ខ្ញុំទាំងប្អូនប្រាំនាក់ដែលធ្វើការជាមួយគ្នាហ្នឹង ខ្ញុំមិនដែលទាស់គ្នាទេទាន។ ស្រឡាញ់គ្នាដូចបងប្អូន បានអ្វីចែកគ្នាស៊ីធម្មតាតើ។ សូម្បីតែកម្មករដែលធ្វើការជាមួយគ្នាហ្នឹងក៏យើងស្រលាញ់គ្នាដូចតែបងប្អូន មិនមានថ្នាំងថ្នាក់ មិនមានទាស់ទែងគ្នាទេ។ មិនមានថាអ្នកនេះធ្វើយឺត អ្នកនោះធ្វើលឿនយ៉ាងម៉េចអត់មានថាគ្នា គិតតែពីខំទាំងអស់គ្នាទៅ ដើម្បីបានសម្រេចការងាររបស់យើង។

[០៩:២០:២៨]

**សៈ** អ៊ីចឹងពួកលោកទាំងប្រាំនាក់ហ្នឹងធ្វើការរាយការណ៍ជារួម គឺថារាយការណ៍ជារួមទៅថ្នាក់លើអ៊ីចឹងមែនទេ? គឺបានន័យថាពួកលោកទាំងប្រាំនាក់រាយការណ៍អំពីអ្វីដែលពួកលោកបានជួបទៅថ្នាក់លើទាំងអស់គ្នាអ៊ីចឹងមែនទេ?

**ឆះ** កាលណាយើងជួបគ្នាហើយ យើងប្រមូលស្ថិតិ យើងប្រមូលអីទាំងអស់មកជួបជុំគ្នា ខ្ញុំរាយការណ៍ទៅលើ។ វាមិនបានទៅរាយការណ៍ទាំងអស់គ្នាទេ តែយើងរាយការណ៍ទៅលើ មានគេមកយករបាយការណ៍រាល់តែថ្ងៃហ្នឹង ទាំងកម្លាំង ទាំងសុខភាពរបស់ប្រជាជនធ្វើការនោះឯង។

**សៈ** ដូច្នេះលោកក្នុងនាមឲ្យប្អូននាក់ផ្សេងទៀត តើលោករាយការណ៍ទៅជាប្រចាំខែ ប្រចាំសប្តាហ៍ ឬក៏ប្រចាំថ្ងៃ?

**ឆះ** រាយការណ៍នោះគឺរាយការណ៍ប្រចាំថ្ងៃនេះទេ។ ដូចជាយើងរាយការណ៍ថា ថ្ងៃនេះយើងធ្វើកម្លាំងយើងប៉ុណ្ណេះ វាឈឺប៉ុណ្ណេះ ហើយបានសម្រេចផលប៉ុណ្ណេះ។ យើងរាយការណ៍តាមអ្នកដែលមកយករបាយការណ៍។

**សៈ** តើលោកមានបានរាយការណ៍ ថាតើក្នុងមួយថ្ងៃហ្នឹងលោកជីកដីបានប៉ុន្មានម៉ែត្រគូប ប៉ុន្មានអីគូបដែរឬទេ? ចង់និយាយថា តើលោកមានរាយការណ៍ពីទិន្នផលប៉ុន្មានគូបក្នុងមួយថ្ងៃដែលក្រុមលោកទាំងអស់ហ្នឹងបានធ្វើការទេ?

**ផៈ** បានរាយការណ៍ទាន ជីកមួយថ្ងៃបានប៉ុន្មានគូបៗ រាយការណ៍ ព្រោះយើងយកមកពីបួននាក់ហ្នឹង គេរាយការណ៍ស្រេចហើយ គេថាក្រុមគេបានប៉ុណ្ណេះគូប ក្រុមនេះបានប៉ុណ្ណេះគូប យើងបូកសរុបគ្នាទៅរាយការណ៍ទៅខាងលើថា ថ្ងៃនេះសម្រេចបានប៉ុណ្ណេះគូប ហើយកម្លាំងដែលជីកនោះមានចំនួនប៉ុណ្ណេះ។

[០៩:២៣:៤៨]

**សៈ** តើពួកលោកទាំងប្រាំនាក់ហ្នឹងគ្រប់គ្រងតែទៅលើមនុស្ស១០០នាក់ ឬមួយក៏ពួកលោកគ្រប់គ្រងទៅលើមនុស្សមកពីភូមិដទៃទៀតដែរ?

**ផៈ** ទាន ព្រោះដែល -- ភូមិដទៃទៀតមានមេភូមិគេផ្សេង គេធ្វើ មេភូមិគេផ្សេង តាមការចាត់ចែងជាក់ស្ដែងរបស់គេទេ។ ខ្ញុំមើលតែភូមិខ្ញុំទេ ហើយនិងគ្នាខ្ញុំបួននាក់ តាមដីដែលគេវាស់ឲ្យ។

**សៈ** ឥឡូវនេះ ខ្ញុំចង់ឲ្យលោកលើកឧទាហរណ៍ជាក់ស្ដែងមួយគឺថា ឧទាហរណ៍ប្រសិនបើមានមនុស្សម្នាក់នៅក្នុងក្រុមទាំងប្រាំនាក់ហ្នឹង ផ្ដាក់ខ្លួនឈឺ ឧទាហរណ៍ថា ប្រសិនបើមានពលករម្នាក់ក្នុងក្រុមលោក នៅពេលព្រលឹមឡើងឈឺ តើលោកធ្វើយ៉ាងដូចម្ដេច តើលោកដោះស្រាយយ៉ាងដូចម្ដេច?

**ផៈ** ជួនបើកាលណាព្រឹកឡើងមានពលកររបស់យើងឈឺក្នុងក្រុមណា យើងជួយមើលគ្នា។ បើថាវាខ្យល់យើងកោសទៅ។ ព្រោះកាលនោះវា ដូចខ្ញុំបានជម្រាបអ៊ីចឹង វាអត់សូវមានថ្នាំមានសង្កូវអីប៉ុន្មានទេទាន ប៉ុន្តែយើងប្រើទឹកក្ដៅ ដាំដើមឈើ។ ដើមឈើចេះតែកាប់ដាក់ទៅ ហាលកាប់ដាក់ទៅ។ រួចឆ្នាំងធំទៅ។ រួចមនុស្សបើឈឺយើងកោសជាន់ចាប់អ៊ីចឹងទៅ ឲ្យគ្នាដេកនៅសម្រាកនឹងកន្លែងយើងដែលសម្រាកហ្នឹងទៅទាន។

[០៩:២៥:៥៥]

**សៈ** តើលោក ហើយនិងមេក្រុមបួននាក់ទៀត តើពួកលោកទាំងបួនទាំងប្រាំហ្នឹងធ្លាប់មានបង្ខំកម្មករដែលឈឺហ្នឹងឲ្យធ្វើការទាំងឈឺទេ?

**ផៈ** ដូចខ្ញុំបាទជម្រាបខាងដើមទាន ពួកខ្ញុំស្រឡាញ់គ្នាដូចបងប្អូនទេ។ បើគ្នាទៅមិនរួចហើយ ក៏ឲ្យគ្នានៅសម្រាកទៅ។ ពេលដែលគ្នាធ្វើការកើត ក៏សុំយើងទៅធ្វើការ។

**ស៖** អ៊ីចឹង អ្នកដែលឈឺហ្នឹងត្រូវស្នើសុំឈប់ទៅមេក្រុម ហើយបន្ទាប់មកទៀត មេក្រុមនីមួយៗ ហ្នឹងយកសំណើហ្នឹងមកពិភាក្សាជាមួយលោក។ តើអ៊ីចឹងមែនទេ?

**ឆ៖** ជួនកាលរស់នៅវាជុំគ្នាណាទាន។ ដូចជាយើងថា មួយរោងម៉ារីយ៉េវែងប្រហែលជា៣០ ម៉ែត្រហ្នឹង យើងដេកទល់ជើងគ្នាទៅ។ អ្នកណាឈឺ យើងដឹងអីតើ ថាអ្នកណាឈឺ ក៏កោសគ្នាទៅ ជួយមើលគ្នាទៅ ហើយក៏ឲ្យដេកនឹងកន្លែងហ្នឹងទៅ។ យើងឃើញទាំងអស់គ្នា ទាំងខ្ញុំបាទក៏ឃើញ មេក្រុមទាំងបួនក៏បានឃើញដូចគ្នា ផ្ទាល់ភ្នែកទាំងអស់គ្នាអីតើ។

**ស៖** សុំអភ័យទោសផងលោកសាក្សី តើលោកសាក្សីអាចនិយាយម្តងទៀត អាចឆ្លើយម្តងទៀតបានទេ ដោយសារតែខ្ញុំមានបញ្ហាបច្ចេកទេសទៅលើនេះ។ សុំលោកសាក្សីជួយឆ្លើយនូវអ្វីដែលលោកឆ្លើយឡើងវិញ។

**ឆ៖** ដែលសួរត្រង់ណាទាន? សួរទៀត ខ្ញុំភ្លេចបាត់ទៅហើយ។

[០៩:២៨:៣៤]

**ស៖** លោកសួរខ្ញុំបានល្អ ប៉ុន្តែអត់អីទេ ខ្ញុំបន្តទៅមុខទៀត ហើយខ្ញុំសុំអភ័យទោសដែរ។ អ្វីដែលខ្ញុំចង់សួរលោកគឺថា អ្នកឈឺហ្នឹងគាត់រាយការណ៍ទៅមេក្រុមរបស់លោក ហើយមេក្រុមបានរាយការណ៍ទៅលោក។ ចុះបើសិនបើអ្នកឈឺហ្នឹងគាត់អត់ជា បានន័យថាមួយថ្ងៃគាត់អត់ជាទេ គាត់ឈឺដល់ទៅពីរបីថ្ងៃ ឬក៏បួនថ្ងៃ ប្រាំថ្ងៃវិញ តើលោកទាំងប្រាំនាក់ហ្នឹងសម្រេចយ៉ាងម៉េចដែរជាមួយអ្នកដែលគាត់ឈឺធ្ងន់ហើយយូរនោះ?

**ឆ៖** ការដ្ឋានដែលធំហ្នឹង អង្គការលោកមានរៀបចំពេទ្យហើយ យើងយកទៅដាក់ពេទ្យការដ្ឋានទៅ ឲ្យគាត់សម្រាកចាក់ថ្នាំនៅកន្លែងពេទ្យនោះបាន មិនអីទេ។

**ស៖** តើលោកចាំថាធ្លាប់មានករណីដែលមានកម្មករឈឺ ហើយបន្ទាប់មកទៀតគេបញ្ជូនកម្មករដែលឈឺហ្នឹងទៅពេទ្យចល័តក្នុងការដ្ឋានហ្នឹងទេ? តើលោកធ្លាប់ចាំថាមានករណីបែបនេះកើតឡើងដែរឬទេ?

**ឆ៖** មានដែរ។ ដូចខ្ញុំបានជម្រាប ការងារធ្វើប្រឡាយដែល យាយគាត់ -- អើ! ថាយាយចុះសព្វថ្ងៃគាត់ចូល៨០ហើយ កាលនោះគាត់នៅក្មេងខ្ទង់៣៥ដែរ។ ដែលដីវាបាក់លើ ខ្ញុំទាំងអស់គ្នាដែលមេក្រុមហ្នឹងទុកតែពីរបីនាក់នៅទៅ ហើយពីរបីនាក់ ហើយនិងកម្មករហ្នឹងឯង រែក សែងគាត់ទៅពេទ្យទៅណាទាន។ ព្រោះប្រើអ្នកក្រៅខ្ញុំខ្លាចលោវាមិនទាន់ចិត្ត ម្លោះហើយសែងរត់ៗ ទៅឲ្យដល់កន្លែងពេទ្យ

រហូតដល់មើលអស់រយៈកាល៤ខែ បានៗជា។ ប្ដីនៅឯផ្ទះហ្នឹងស្មានតែប្រពន្ធស្លាប់ហើយ ក៏ប៉ុន្ដែដល់ពេលនេះ ក៏គាត់ជាមកវិញ រហូតដល់នៅទើបនឹងស្លាប់ប្រាំងមិញនេះទេទាន។

[០៩:៣១:២៣]

**ស៖** សូមអរគុណលោកសាក្សី។ ចុះឧទាហរណ៍ថាមានកម្មករម្នាក់គាត់ភ្ញាក់ពីគេងមកគាត់ក្ដៅខ្លួន គ្រុនផ្ដាសាយ រាកបីបួនថ្ងៃអីអ៊ីចឹង។ អ៊ីចឹងប្រហែលជាលោកបញ្ជូនអ្នកជំងឺហ្នឹងទៅពេទ្យដែរ អ៊ីចឹងមែនទេ? ហើយចុះប្រសិនបើអ្នកដែលឈឺហ្នឹង គាត់អត់ -- គាត់ទៅពេទ្យចល័តហ្នឹងហើយ ប៉ុន្ដែពេទ្យចល័តហ្នឹងព្យាបាលអត់ជា តើលោកចាំទេថាគេធ្វើយ៉ាងម៉េចតទៅទៀត? លោកចាំពីករណីជាក់ស្ដែងហ្នឹងទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ការដ្ឋាននីមួយៗដែលការដ្ឋានធំៗ អ៊ីចឹងអង្គការរៀបចំពេទ្យ។ ពេទ្យនោះគឺពេទ្យនៅក្នុងការដ្ឋាន បើពេទ្យនៅក្នុងការដ្ឋានោះគាត់មើលមិនជល់ទេ ក៏បញ្ជូនទៅពេទ្យតំបន់។ បើតំបន់ហ្នឹងគេមើលមិនកើត បញ្ជូនទៅភូមិភាគ ទាន។ ហ្នឹងចំពោះអ្នកឈឺនៅការដ្ឋាន។

**ស៖** តើលោកចាំទេ ក្នុងរយៈពេល៦ខែនុ៎ង មានមនុស្សប៉ុន្មាននាក់នៅក្នុងក្រុមទាំង១០០នាក់របស់លោកហ្នឹង គឺថាមានមនុស្សប៉ុន្មាននាក់ដែលធ្លាប់បញ្ជូនទៅពេទ្យតំបន់ ដោយសារតែគាត់មើលនៅពេទ្យចល័តហ្នឹងអត់ជា?

**ឆ៖** វាមិនមានថាបញ្ជូនច្រើនទេទាន។ ជួនកាលក៏មិនបានទៅដល់តំបន់ទេ ដែលបានតំបន់ដែលខ្ញុំដឹងហ្នឹង អង្គាល់ដែលខ្ញុំធ្វើនៅនឹងការដ្ឋានកំប៉ឺយ ហ្នឹងខ្ញុំបានបញ្ជូនទៅពេទ្យស្រុក។ ស្រុកគេថា ម៉េចក៏យកមនុស្សមិនដាក់ពេទ្យការដ្ឋានហើយ ហើយថា ខ្ញុំបាទជម្រាបគាត់ ប្រាប់គាត់ថា ពេទ្យការដ្ឋានខ្ញុំវាឆ្ងាយប៉ុនគ្នា ក៏យកមកស្រុកបណ្ដោយ។ ដល់ស្រុកហ្នឹងគេយកទៅឯខាងតំបន់ទៅ។ នេះដែលខ្ញុំបញ្ជូនទៅណ៎ាទាន។ ខ្ញុំមិនសូវចាំទេ ដែលឥឡូវស្មារតីវាអត់សូវចាំ ស្ដាប់នៅចាំបន្ដិចៗទាន ខ្សោយស្មារតី។

[០៩:៣៤:៣០]

**ស៖** ប៉ុន្ដែលោក ហើយនិងមេក្រុមទាំងបួននាក់នោះ មានមនុស្សប្រហែលជា១០០នាក់ ហើយលោកធ្វើការក្នុងរយៈពេលប្រហែលជា៦ខែ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើមានមនុស្សប៉ុន្មាននាក់ដែលឈឺហើយមើលនៅពេទ្យចល័តនៅការដ្ឋាននុ៎ងអត់ជា ហើយត្រូវបញ្ជូនទៅពេទ្យតំបន់។ ខ្ញុំចង់ដឹងថាក្នុងរយៈពេល៦ខែហ្នឹង មានមនុស្សប៉ុន្មាននាក់ដែលឈឺបញ្ជូនទៅពេទ្យតំបន់ មានពីរនាក់ ប្រាំនាក់ ឬក៏១០នាក់? ខ្ញុំចង់ឲ្យលោកប្រាប់ជាចំនួន។

**ផ៖** ទៅពេទ្យតំបន់ទាល់តែធ្ងន់ខ្លាំងណាស់បានខ្ញុំបញ្ជូនទៅ បើថាអាចស្រួល យើងមើលកន្លែងយើងទេ ព្រោះថ្នាំយើងប្រើថ្នាំខ្មែរទៅ។ ព្រោះកាលណោះមានអ្នកចេះថ្នាំខ្មែរច្រើនដែរទាន។ ហើយមើលទៅក៏វាកបតាមសេចក្តីប្រាថ្នាដែរ។ អ៊ីចឹងបានមិនសូវបានជាបញ្ជូនទេ ទាល់តែបញ្ជូនមួយៗទាល់តែឃើញថាខ្លួនឯងគ្មានលទ្ធភាពនឹងមើលទាន។

**ស៖** ខ្ញុំយល់អ្វីដែលលោកបាននិយាយ។ តើលោកអាចប៉ាន់ប្រមាណថាតើមានមនុស្សប៉ុន្មាននាក់ត្រូវបានគេបញ្ជូនទៅពេទ្យតំបន់ ហើយពេលដែលព្យាបាលហើយ គាត់ត្រឡប់មកធ្វើការនៅការដ្ឋានវិញ។ តើមានមនុស្សពីរនាក់ ប្រាំនាក់ ឬក៏១០នាក់? ខ្ញុំដឹងថាវាពិបាកក្នុងការប៉ាន់ប្រមាណប៉ុន្តែតើលោកអាចប៉ាន់ប្រមាណមើលថាមានមនុស្សប៉ុន្មាននាក់ដែលទៅពេទ្យតំបន់ ហើយជាត្រឡប់មកវិញ?

**ផ៖** ក្រុមខ្ញុំ ភូមិខ្ញុំហ្នឹង ខ្ញុំបានបញ្ជូនទៅមួយទេទាន ម៉ាធ្វើការដ្ឋាន តាំងពីធ្វើការដ្ឋាន។ ក្រៅពីនោះមើលតែក្នុងពេទ្យការដ្ឋានទេទាន។ ព្រោះក្នុងពេទ្យការដ្ឋានហ្នឹងក៏វាមានថ្នាំក្រែលដែរ អង្គការលោកយកចិត្តទុកដាក់ដែរទាន។

[០៩:៣៧:១៥]

**ស៖** ខ្ញុំយល់លោក។ អ៊ីចឹងមនុស្សម្នាក់ដែលមើលអត់ជានៅពេទ្យចល័តហ្នឹងត្រូវបានគេបញ្ជូនទៅពេទ្យតំបន់ហ្នឹង តើអ៊ីចឹងគាត់អាចជា ហើយត្រឡប់មកវិញទេ ឬមួយក៏យ៉ាងម៉េច?

**ផ៖** បាទ ៤ខែបានគាត់ត្រឡប់មកវិញបានជាទាន។ ទៅតំបន់ហ្នឹង ដែលសម្រាកបាន១៥ ហ្នឹងតាមសម្តីគាត់និយាយ ខ្ញុំមិនបានទៅផ្ទាល់ដែរទាន។ តាមសម្តីគាត់និយាយ តែខ្ញុំទៅសួរគាត់ដែរគាត់មកដឹងថាមកនៅ -- ទៅដល់តំបន់បាន១៥ថ្ងៃ គេបញ្ជូនទៅភូមិភាគ ដល់ទៅភូមិភាគហ្នឹង បាន៤ខែទានបានមកផ្ទះវិញ។ គាត់ជាតាមធម្មតា។

**ស៖** លោកសាក្សីខ្ញុំចង់និយាយអំពីអ្វីដែលលោកឆ្លើយកាលពីម្សិលមិញ ក្នុងចំណោមមនុស្ស១០០នាក់មកពីភូមិហ្នឹង គឺអ្នកដែលធ្វើការក្រោមការគ្រប់គ្រងរបស់លោក និងមេក្រុមដទៃទៀតហ្នឹង គឺមិនមានអ្នកណាម្នាក់ស្លាប់ដោយសារជំងឺទេ។ តើអ៊ីចឹងមែនទេ?

**ផ៖** ក្នុងការដែលធ្វើការដ្ឋាន ដូចខ្ញុំថាហ្នឹងវាដូចជាចេះតែសុខសប្បាយទៅទាន មិនឃើញមានស្លាប់ទេ គ្រាន់តែឈឺខ្លះៗ មើលមួយថ្ងៃជាអ៊ីចឹងទៅ កោសខ្យល់ណេះណោះទៅក៏ជាក៏មាន។

**ស៖** លោកសាក្សី ខ្ញុំអាចនិយាយបានទេថាសុខភាពរបស់ប្រជាជនទាំង១០០នាក់ហ្នឹង គឺស្ថិតក្នុងការសម្រេចចិត្តរបស់លោកនិងមេក្រុមដទៃទៀត។ គឺបានន័យថា ពួកលោកទាំងប្រាំនាក់ហ្នឹងជាអ្នក

ទទួលខុសត្រូវទៅលើបញ្ហាសុខភាពរបស់មនុស្ស១០០នាក់ហ្នឹង ហើយមានអ្នកផ្សេងគេមកអន្តរាគមន៍ ឬក៏មកជ្រៀតជ្រែកទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** មនុស្សទាំង១០០នាក់ លើខ្ញុំប្រាំនាក់ហ្នឹងឯងទាន។ គឺខ្ញុំ ហើយនិងប្រធានក្រុមទាំងបួននាក់ទៀត អ្នកមើលការខុសត្រូវ។

[០៩:៤០:០៨]

**ស៖** ចុះប្រសិនបើមនុស្សណា -- ប្រសិនបើណាអ្នក១០០នាក់ហ្នឹង មានអ្នកណាម្នាក់គាត់និយាយថា ឥឡូវនេះខ្ញុំអស់កម្លាំងខ្លាំង ខ្ញុំដើរអត់រួចទេ តើលោកអាចឲ្យខ្ញុំសុំសម្រាក១៥នាទីបានអត់។ តើក្នុងករណីអ៊ីចឹងលោកអនុញ្ញាតឲ្យពួកគេសម្រាក១៥នាទីសិន ឬមួយក៏លោកថាបង្ខំឲ្យត្រូវតែធ្វើការ?

**ឆ៖** ការងារធ្ងន់ៗអ៊ីចេះទាន ពេលដែលយើងធ្វើការទាំងអស់គ្នាយើងមិនអាចឲ្យសម្រាកម្នាក់បានទេ បើថាវាអន់ហើយ ក៏យើងដើរតិចៗទៅ កុំប្រញាប់ពេក។ ដើរវាមួយព្រឹកត្រូវឈប់ពីរដង មួយព្រឹក ឈប់ពីរដង -- បីដង ឈប់បីដង ម៉ាធ្វើការហ្នឹង ពីម៉ោងប្រាំមួយ ដល់ម៉ោងដប់មួយហ្នឹងឯង។

**ស៖** ការសម្រាកហ្នឹង គឺសម្រាកយ៉ាងម៉េចដែរ មួយម៉ោងម្តង ឬក៏មួយម៉ោងកន្លះម្តង ឬក៏យ៉ាងម៉េច លោកចាំទេ?

**ឆ៖** ដែលសម្រាកហ្នឹង វាពីរម៉ោងទាន ពីរម៉ោង បានយើងសម្រាកម្តង។ សម្រាកម្តង១៥នាទីទេណ៎ាទាន។ មិនសម្រាកយូរទេ តែ១៥នាទី ឯកភាពតាមក្រុមគេណ៎ា ព្រោះមួយការដ្ឋានហ្នឹង។

**ស៖** អ៊ីចឹងកម្មករ១០០នាក់នៅក្នុងក្រុមរបស់លោកហ្នឹង គឺថាឈប់សម្រាកដូចកម្មករផ្សេងៗដែលមកពីភូមិផ្សេងៗទៀត។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយទាន ឈប់ដូចតែគេហ្នឹងដែរ។

[០៩:៤៣:១១]

**ស៖** លោកនិងមេទាំងបួននាក់ទៀតហ្នឹង ជាអ្នកទទួលខុសត្រូវលើការស្នាក់នៅរបស់កម្មករទាំង១០០នាក់ហ្នឹងមែនទេ? គឺថាលោកទទួលខុសត្រូវថានៅកន្លែងដែលអ្នកទាំងអស់ហ្នឹងសម្រាកនៅពេលយប់ តើអ៊ីចឹងទេ?

**ឆ៖** យប់ខ្ញុំទាំងអស់គ្នាទាំងប្រាំនាក់ហ្នឹងទទួលខុសត្រូវទៅលើមនុស្ស១០០នាក់ហ្នឹងឯង។ ទាំងការសម្រាក នៅយប់ ទាំងការហូបចុក ទាំងអស់។ ព្រោះបើកាលណា វាខ្វះនូវចំណុចណាយើងរាយ-ការណ៍មកខាងក្រោយមក យើងធ្វើប្រឡាយហ្នឹង គេចាត់ជាបញ្ហាពីរ។ គឺអ្នកនៅភូមិនេះ គេហៅ

សមរភូមិក្រោយ អ្នកទៅធ្វើប្រឡាយហ្នឹង គេហៅថាសមរភូមិមុខ។ ដូច្នេះ បើសមរភូមិមុខ សំណូមពរ ហើយ អ្នកសមរភូមិក្រោយនេះ គ្នាប្រឹងឯក្រោយឲ្យទៅ។ ហើយអ្នកទាំងបួននាក់ហ្នឹងឯង ដែលសហការគ្នា សុំមកខាងក្រោយនោះ។

[០៩:៤៤:៣៤]

**ស៖** អ៊ីចឹងគឺលោកនិងមេទាំងបួននាក់ហ្នឹង ជាអ្នកទទួលខុសត្រូវថាឲ្យអ្នកកម្មករទាំង១០០នាក់ គឺថាស្នាក់នៅឲ្យបានសមរម្យ។ តើអ៊ីចឹងមែនទេ?

**ឆ៖** កន្លែងសម្រាកឲ្យបានសមរម្យ តាមរបៀបនោះឯងទាន វាមិនបានសមរម្យដូចដែល -- ដូចយើងសព្វថ្ងៃទេទាន វាគ្រាន់ថាមានកន្លែងដេកត្រឹមត្រូវ ក្រាលកូនឈើ ក្រាលអីទៅ សម្រាកទៅ ហើយក្រាលកន្ទេល ត្នោត សម្រាកទៅ ប៉ុណ្ណឹងទេវាមិនបានជាអស្ចារ្យក្នុងការធ្វើកន្លែងសម្រាកទេ។

**ស៖** តើលោកនិងមេក្រុមទាំងបួននាក់ទៀតមានសិទ្ធិផ្តល់សម្ភារៈ ឧទាហរណ៍ ដូចជាកន្ទេល មុង លោកអាចយករបស់របរទាំងអស់ហ្នឹងមកកន្លែងសម្រាកពេលយប់ហ្នឹងបានទេ?

**ឆ៖** កាលណាយើងទៅធ្វើការងារនៅប្រឡាយ យើងបានប្រាប់កម្លាំងយើងស្រេចថា ត្រៀមរបស់ណា អ្នកមានអង្រឹងក៏យកអង្រឹងទៅ អ្នកមានមុងយកមុងទៅ ទៅចងសម្រាកនៅកន្លែងការដ្ឋានដែលយើងសម្រាកនោះ។ ហ្នឹងថ្ងៃដែលយើងចេញដំបូងណាទាន។ ទៅអ្នកមានមុងយកមុង អ្នកមានអីយកហ្នឹងទៅៗ ដើម្បីសម្រាកទាំងអស់គ្នា។ គឺគេដោះស្រាយខ្លួនគេ យើងដោះស្រាយខាងលើពីផ្ទះរបស់ពលករម្នាក់ៗហ្នឹង។

**ស៖** អ៊ីចឹងមានន័យថា កម្មករទាំង១០០នាក់ហ្នឹង មានសិទ្ធិយករបស់របរអ្វីមកក៏បានដែរ សម្រាប់គេងពេលយប់។ ខ្ញុំអាចនិយាយអ៊ីចឹងបានទេ?

**ឆ៖** បាទ ត្រូវហើយទានត្រូវអ៊ីចឹង។

[០៩:៤៧:៣៨]

**ស៖** ចុះសម្ភារៈផ្សេងទៀតនោះ ប្រសិនបើពួកគាត់អាចទៅភូមិសម្រាកហើយអ៊ីចឹង ពេលមកវិញ គាត់អាចមានសិទ្ធិយកចំណីអាហារ ឬក៏របស់របរអីផ្សេងទៀតទេនៅពេលដែលត្រឡប់ចូលមកធ្វើការនៅការដ្ឋានសាងសង់ទំនប់វិញនោះ?

**ឆ៖** បើគាត់មាន គាត់យកមកបានទេទាន។ ជារបស់របរដែលគាត់ ដែលថាត្រូវហូបចុកអីណា យកមកបាន យកមកពិសាខ្លួនឯងបាន។

**សៈ** លោកផ្ទាល់និងមេក្រុមផ្សេងទៀតនុ៎ងមានធ្លាប់និយាយប្រាប់អ្នកទាំង១០០ហ្នឹងថា ពួកគាត់មិនអាចមានសិទ្ធិយកអ្វីមកកន្លែងសាងសង់ហ្នឹងបានទេ? លោកមានធ្លាប់ប្រាប់អ្នកកម្មករទាំងអស់ហ្នឹងថាអ៊ីចឹងទេ?

**ផៈ** បាទ ការនិយាយគឺបាននិយាយអ៊ីចឹងមែនទាន មិនត្រូវយករបស់របរហួបដោយខ្លួនទេ ក៏ប៉ុន្តែបើគេយកខ្លួនគេក៏តាមគេយកមកចុះទាន ព្រោះរបស់វាបន្តិចបន្តួច យើងអធ្យាស្រ័យគ្នាទៅ។

**សៈ** ឥឡូវនេះខ្ញុំចង់សួរលោកពាក់ព័ន្ធទៅនឹងមនុស្សទាំង១០០នាក់នោះ។ តើលោកស្គាល់ឈ្មោះកម្មករដែលជាកូនក្រុមរបស់លោកទាំងអស់ទេ ស្គាល់ឈ្មោះពួកគាត់ទាំងអស់គ្នាទេ?

**ផៈ** ទាន ខ្ញុំបាទមិនចាំទេទាន ទោះកាលណោះក៏ខ្ញុំស្គាល់មិនអស់ដែរ។

[០៩:៥០:00]

**សៈ** ខ្ញុំយល់ ក៏ប៉ុន្តែនៅសម័យនោះនៅពេលធ្វើការនៅការដ្ឋានហ្នឹង តើលោកស្គាល់ក្រុម កូនក្រុមរបស់លោកហ្នឹងទាំងអស់គ្នាទេ លោកដឹងថាអ្នកណាជាអ្នកណាអី ច្បាស់ទេពេលនុ៎ង?

**ផៈ** យើងអាចស្គាល់ថាអ៊ីចេះទាន។ ស្គាល់ថាពូ"ក", ពូ"ខ", ពូ"ង" នេះ គាត់នៅក្រុមសម្រាប់សមមិត្តនេះ គាត់នៅក្រុមសមមិត្តនោះ តែប៉ុណ្ណឹងទេទាន។ ហើយខ្ញុំក៏ស្គាល់ពលកររបស់ខ្ញុំ ២០នាក់ហ្នឹង ដូចគ្នាហ្នឹងដែរ។

**សៈ** អ៊ីចឹងខ្ញុំអាចនិយាយបានថាលោកទាំងប្រាំនាក់ដែលជាមេៗហ្នឹង គឺថាស្គាល់កូនក្រុមទាំងអស់ ទាំង ១០០នាក់ហ្នឹង មែនទេ?

**ផៈ** បាទ ស្គាល់ទាំង ១០០នាក់ហ្នឹង ស្គាល់តាមចង្កោមគេទេ មិនស្គាល់ជាមនុស្សទេ គ្រាន់តែដឹងថាចង្កោមនេះ នៅក្រុមនេះៗ តែជាពលករនៅក្នុងការដ្ឋានជីប្រឡាយហ្នឹងទាន។

**សៈ** ខ្ញុំយល់ច្បាស់ហើយលោក។ តើកម្មករទាំង ១០០នាក់ហ្នឹង លោកដឹងទេថាអ្នកណាខ្លះជាអ្នកថ្មី អ្នកណាខ្លះជាអ្នកចាស់ លោកស្គាល់ច្បាស់ទេ?

**ផៈ** ស្គាល់ច្បាស់ទាំងអស់ទាន ស្គាល់ច្បាស់ទាំងអស់។ អ្នកនេះជាប្រជាជនចាស់ អ្នកនេះជាប្រជាជនថ្មី ប៉ុន្តែអ្នកនេះជាចាម ជាខ្មែរ។ ស្គាល់ទាំងអស់តើទាន ដែលនៅក្នុងក្រុមរបស់យើងហ្នឹង។ ហើយក៏គាត់នៅក្នុងការដ្ឋានជាមួយនឹងពួកយើងទាំងអស់គ្នាហ្នឹងឯង។

**សៈ** តើលោកនិងមេក្រុមទាំងបួននាក់ផ្សេងទៀតហ្នឹង ធ្លាប់ចេញបញ្ជាឲ្យប្រជាជនថ្មីធ្វើការធ្ងន់ជាងប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ទេ?

[០៩:៥៣:០៧]

**ឆ៖** ខ្ញុំមិនធ្លាប់ទេ មិនធ្លាប់ដាក់កំណត់អ៊ីចឹងទេ ថ្មី ចាស់ ដូចតែគ្នា ធ្វើតាមកម្លាំងដូចតែគ្នា។ មិនមានថាអ្នកថ្មីធ្វើឲ្យវាតឹងតែង ហើយអ្នកចាស់បន្ធូរហ្នឹង អត់ទេ ធ្វើដូចគ្នាទៅ ដើម្បីសម្រេចការងារទាំងអស់គ្នា។

**ស៖** អ៊ីចឹងខ្ញុំអាចនិយាយបានទេថា លោកនិងមេក្រុមប្អូននាក់ទៀតហ្នឹង គឺប្រព្រឹត្តចំពោះកម្មករទាំង ១០០នាក់ហ្នឹង គឺ ស្មើៗគ្នា ដូចៗគ្នាទាំងអស់អ៊ីចឹងទេ?

**ឆ៖** បាទត្រូវហើយទាន អ៊ីចឹងហើយ។

**ស៖** ក្នុងរយៈពេល៦ខែ ដែលលោកគ្រប់គ្រង មនុស្ស១០០នាក់មកពីភូមិរបស់លោកជាមួយមេប្អូននាក់ផ្សេងទៀតនោះ លោកមានធ្លាប់បានចេញសេចក្តីសម្រេចបញ្ជូនកម្មករណាម្នាក់ទៅឲ្យថ្នាក់លើពីព្រោះថាគាត់ធ្វើការមិនខ្លាំង តើលោកធ្លាប់ស្នើសុំដាក់វិធានការវិន័យទៅលើអ្នកណាម្នាក់នៅក្នុងចំណោមកម្មករទាំង១០០នាក់ហ្នឹងទេ?

**ឆ៖** ចំពោះខ្ញុំ ហើយនិងមិត្តខ្ញុំប្អូននាក់ទៀតមិនដែលទេ មិនដែលយកពលករខ្លួនឯងទៅឲ្យថ្នាក់លើធ្វើ ដាក់ពិន័យអីទេទាន។ បើការងារដែលវាដោះស្រាយមិនរួច យើងដោះស្រាយតែនៅក្នុងក្រុមយើងទៅ ឯកភាពគ្នាទៅធ្វើម៉េចឲ្យតែបានឆាប់រួច តាមកម្លាំងទាំងអស់គ្នា។

**ស៖** នៅពេលដែលក្រុមការងារទាំងប្រាំធ្វើការ តើមានទាហាន ឬមានឈ្លបយាមអ្នកទាំង១០០នាក់ហ្នឹងទេ? គឺខ្ញុំចង់សួរថា តើមានអ្នកណា មានទាហាន ឬក៏ឈ្លបត្រួតត្រាលើអ្នកទាំង១០០ ដែលកំពុងតែធ្វើការទេ?

[០៩:៥៦:០០]

**ឆ៖** ការដ្ឋាន គេតែងតែមានអ្នកការពារសន្តិសុខឲ្យ តែងតែមានអ្នកការពារសន្តិសុខឲ្យពលករទាំងអស់គ្រប់ការដ្ឋាន មិនដែលចោលទេ។

**ស៖** អ៊ីចឹង ខ្ញុំយល់ត្រឹមត្រូវទេថា ឈ្លបដែលធ្វើការនៅទីនោះហ្នឹងដោយសារតែបញ្ហាសន្តិសុខខាងក្រៅ មិនមែនមកដើម្បីឃ្លាំមើល ឬក៏តាមដានទៅលើអ្នកធ្វើការទាំងអស់ហ្នឹងទេ តើអ៊ីចឹងទេ?

**ឆ៖** មិនមានមកឃ្លាំមើលអ្នកធ្វើការទេទាន មើលសន្តិសុខខាងក្រៅ។

**ស៖** សូមអរគុណលោកសាក្សី ចំពោះចម្លើយនេះ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកចំណុចមួយដែលលោកបានឆ្លើយកាលពីម្សិលមិញ គេសួរលោកអំពីក្រុមថតកុនមួយដែលមកថតនៅទំនប់ ១មករា នោះ

ហើយគេបានថតសកម្មភាពរបស់លោកនៅការដ្ឋានសាងសង់ទំនប់។ លោកឆ្លើយថា លោកមានមោទនភាពក្នុងការធ្វើការណាស់។ អ៊ីចឹងអារម្មណ៍មោទនភាពរបស់លោកហ្នឹងដោយសារតែលោកបានបំពេញការងារហ្នឹង តើលោកដឹងទេថាមេក្រុមផ្សេងទៀតហ្នឹងក៏មានមោទនភាពដូចលោកអ៊ីចឹងដែរមែនទេ ដែលបានធ្វើការនៅការដ្ឋានសាងសង់ទំនប់នោះ?

[០៩:៥៨:១៧]

**ប្រធានអង្គជំនុំ៖**

កុំទាន់អាល់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

គាត់កំពុងតែសួរសាក្សីឱ្យគិតអំពីអារម្មណ៍របស់អ្នកផ្សេងហើយ។ កាលមុនគាត់សួរអំពីសន្តិសុខ អ៊ីចឹងឥឡូវនេះខ្ញុំចង់ដឹងថាតើសាក្សីនេះមានតួនាទីអ្វីពាក់ព័ន្ធនឹងសន្តិសុខ អ៊ីចឹងគាត់ម៉េចទៅដឹងថាតើមានឈ្លបហ្នឹង បេសកកម្មអីយ៉ាងម៉េច តួនាទីអីយ៉ាងម៉េចក៏មិនដឹងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំឯកភាពជាមួយនឹងព្រះរាជអាជ្ញាថា គាត់មិនអាចដឹងពីអារម្មណ៍របស់អ្នកផ្សេងទេ ក៏ប៉ុន្តែគាត់អាចជម្រាបបានថាតើមេក្រុមទាំងប្អូននោះ ដែលធ្វើការជាមួយគាត់នោះ មានបាននិយាយទេថា ពួកគេរីករាយនឹងបំពេញការងារ រីករាយក្នុងការចូលរួមចំណែកក្នុងការសាងសង់ទំនប់។ ខ្ញុំមិនសុំឱ្យសាក្សីប្រាប់អំពីអារម្មណ៍របស់អ្នកផ្សេងទេ ខ្ញុំគ្រាន់តែចង់ដឹងថាតើមេក្រុមទាំងប្អូននាក់ផ្សេងទៀតនោះ គាត់មានបានពិភាក្សាជាមួយគាត់ទេថា ពួកគាត់មានសប្បាយរីករាយទេដែលអាចធ្វើការនៅទំនប់បាន។ អ៊ីចឹងខ្ញុំគិតថា ខ្ញុំមានអារម្មណ៍ -- ខ្ញុំអាចសួរបាន។

**លោក នីកូឡាស គូមជែន៖**

បើសិនជាគាត់សួរអ៊ីចឹងមែនគឺអត់អីទេ គាត់អាចសួរបាន។ គាត់អាចសួរថាតើអ្នកផ្សេងទៀតនោះមានបាននិយាយឬអត់ ថាខ្លួនបានរីករាយនៅចំពោះមុខកម្មាភិបាលផ្សេងទៀត។

[០៩:៥៩:៥៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ខ្ញុំសួរអ៊ីចឹងហើយអំមិញហ្នឹង គឺខ្ញុំសួរដូចដែលព្រះរាជអាជ្ញានិយាយអ៊ីចឹងហើយ។

**ប្រធានអង្គជំនុំ៖**

មេធាវី វ៉ិចទ័រ កូប៉េ រៀបចំសំណួររបស់លោកចុងក្រោយអំមិញនេះឡើងវិញដើម្បីឲ្យច្បាស់លាស់ ដើម្បីសាក្សីអាចស្ដាប់បាន ហើយនិងឆ្លើយតបចំបញ្ហា ចំសំណួរតែម្ដង។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី កាលពីម្សិលមិញលោកបានឆ្លើយថាលោកផ្ទាល់នេះ មានមោទនភាពណាស់ ហើយនិងរីករាយមែនទែនដែលបានបង្ហាញការងារទៅជូនក្រុមថតកុន។ អ៊ីចឹង លោកចាំទេថាពេលហ្នឹង គឺមេក្រុមទាំងបួននាក់ដែលជាមិត្តភ័ក្តិរបស់លោកនុ៎ង មានបង្ហាញពីអារម្មណ៍ថា មានមោទនភាពទេ? ពួកគាត់មានបាននិយាយប្រាប់លោកថា ពួកគាត់រីករាយទេនៅពេលដែលឃើញក្រុមថតកុនមកថតសកម្មភាពពួកគាត់ធ្វើការអ៊ីចឹងនុ៎ង?

**ឆ៖** សប្បាយរីករាយណាស់ទាន បានដើរតួឯកកុនមួយពេលដែលលើកប្រឡាយហ្នឹង។ គឺអាក្រមាក្រហមហ្នឹង យើងព័ទ្ធកទៅ ខ្លះក្រវាត់ចង្កេះក៏បានស្រេចតែចិត្ត ហើយក៏រែកដីរត់ទៅ ប៉ុន្តែផ្លូវរត់ឡើងមួយ ផ្លូវចុះមួយ សុទ្ធតែចុះសុទ្ធតែរត់ ឡើងក៏សុទ្ធតែរត់ដែរទាន ដើម្បីឲ្យវាសកម្មភាពហ្នឹងវាល្អប្រហែលជាពីរម៉ោង។ ប៉ុន្តែ រត់ហ្នឹងក៏មិនមែនរត់តែឯងពេញពីរម៉ោងទេទាន វាមានរត់ទៅអ៊ីចឹងទៅវាច្រើនតកន្ទុយគ្នាណ៎ាទាន។ មើលទៅវា មើលក្នុងកុនទៅវាដូចជាសកម្មល្អណាស់។

[១០:០២:០៧]

**ស៖** ខ្ញុំយល់ច្បាស់អំពីចម្លើយរបស់លោក ប៉ុន្តែដើម្បីឲ្យច្បាស់ទាំងអស់គ្នា ខ្ញុំចង់ដឹងថាលោកមានមោទនភាព និងរាយរីកទេដែលលេចមុខនៅក្នុងកុនហ្នឹង? ទាំងក្រុមការងាររបស់លោក ទាំងមិត្តរួមក្រុមរបស់លោកនោះ រីករាយទេ?

**លោក នីកូឡាស គូមជែន៖**

លោកបាននិយាយថា លោក និងមិត្តរួមក្រុមរបស់លោក--

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសួរម្ដងទៀត ខ្ញុំចង់ដឹងថាតើលោករីករាយទេនៅពេលដែលលោកឃើញខ្លួនឯងហ្នឹងលេចមុខនៅក្នុងកុននោះ អ៊ីចឹង ខ្ញុំដឹងថាសំណួរនេះវាពិបាកប៉ុន្តែសុំឲ្យលោកឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ឆ៖** រីករាយណាស់ទាន។ ជួនកាលមិនបានឃើញរូបឯងមែនក្នុងថតហ្នឹងវាឃើញរូបពួកម៉ាក ថាឃើញមិត្តនេះឃើញមិត្តនោះរែកដី ឃើញមិត្តនេះរត់ ហើយប្រយ័ត្នហ្នឹងម្នាក់ៗខ្លាចដួល ដើម្បីឱ្យវាល្អ។

[១០:០៣:៣៣]

**ស៖** សុំទោសដែលខ្ញុំសួរទៅវាធ្វើឱ្យលោកភ័ន្តច្រឡំ។ ឥឡូវខ្ញុំចង់សួរឡើងវិញម្តងទៀត។ លោកនិង -- ឥឡូវៗខ្ញុំសួរអ៊ីចេះវិញ មិនបាច់និយាយពីកុនទេ។ ខ្ញុំសួរថាលោកហើយនិងក្រុមការងាររបស់លោកនោះ មិត្តទាំងបួនរបស់លោកហ្នឹងសប្បាយរីករាយនឹងធ្វើការទេ?

ខ្ញុំមិនសុំឱ្យសាក្សីគិតអំពីអារម្មណ៍របស់មិត្តរបស់លោកផ្សេងទៀតទេ ក៏ប៉ុន្តែខ្ញុំសួរថាតើពួកគាត់ហ្នឹងមានរីករាយឬក៏អត់? មានប្រាប់លោកឬអត់ថាពួកគេធ្វើការហ្នឹងគឺរីករាយណាស់ នៅពេលដែលធ្វើនៅការដ្ឋានហ្នឹង?

**ឆ៖** ធ្វើទាំងអស់គ្នាគេរីករាយណាស់ទាន។ គេរីករាយ គេសប្បាយ។ ទាំងមេក្រុមដែលបានដឹកនាំហ្នឹងក៏រីករាយដែរ។ បើក្រុមមួយហ្នឹងគេ មេក្រុមគេរែកមុខ កូនក្រុមហ្នឹងរែកតាមក្រោយទៅ។ ទៅចាក់រួចទៅ ត្រឡប់មកវិញ មកកាប់ទៅទៀត កាប់រួចទៅ វាទៅមកៗហ្នឹង ហើយអ្នកថតហ្នឹងក៏ចេះតែថតទៅ។ ដល់តែគេយកមកបញ្ចាំងឱ្យមើល ក៏មើលល្អមើលដែរ។

**ស៖** នៅពេលដែលលោកធ្វើការនៅទីនោះ លោកមានបានកត់សម្គាល់ឃើញទេថា កម្មករទាំង ១០០នាក់ហ្នឹង លោកមានសង្កេតឃើញថាពួកគាត់រីករាយ ហើយនិងមានមោទនភាពទេ។ លោកឃើញផ្ទាល់ភ្នែកទេ មើលទៅឃើញថាពួកគាត់ទាំង១០០នាក់ហ្នឹងមានការសប្បាយរីករាយទេក្នុងការចូលរួមសាងសង់ទំនប់នោះ?

**ឆ៖** ទាន មិនអាចមើលចិត្តមនុស្សផ្ទុះទេណាទាន។ ក៏ប៉ុន្តែដែលសួរគ្នាទៅ ពេលដែលយើងឈប់សួរគ្នាទៅ គេថាគេសប្បាយ។

[១០:០៦:១៧]

**ស៖** លោកនិយាយថា ពួកគេសប្បាយហ្នឹង។ ពួកគេហ្នឹង គឺថាចង់សំដៅលើគ្នាច្រើនទេ? លោកអាចជម្រាបបានទេថាកម្មករភាគច្រើនហ្នឹង គឺថាពួកគាត់សប្បាយរីករាយមែនទែន ក្នុងការចូលរួមសាងសង់ទំនប់ ១មករា នេះ?

**ឆ៖** បាទ ក្រុមខ្ញុំ១០០នាក់។ ទាំង១០០នាក់ ទាំងមេ ទាំងកើយទាំងអស់ហ្នឹង សប្បាយរីករាយ

ណាស់ទាន។

**លោក នីកូឡាស គូមជែន៖**

សាក្សីគាត់បានប្រាប់ហើយ គាត់ថាគាត់មិនអាចមើលចិត្តផ្ទះរបស់កម្មករទេ។ ដូច្នេះ ខ្ញុំមានអារម្មណ៍ថាមេធាវីការពារក្តីព្យាយាមរៀបចំសំណួររបស់គាត់ ហើយសួរថា គួរតែសួរថាតើកម្មករហ្នឹងគាត់មានបានបង្ហាញការរីករាយ ឬក៏អត់?

**លោក វ៉ិចទ័រ កូប៉េ៖**

យើងមិនមែននៅទីនេះដើម្បីទាញចេញចម្លើយពីសាក្សីពាក់ព័ន្ធនឹងចំណុចនេះទេ។ អ្វីទាំងអស់ហ្នឹង គឺថាសុទ្ធតែបានកត់ត្រាទុក។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សាក្សីគាត់បាននិយាយថា គាត់បានសួរទៅកម្មកររបស់គាត់ ថាពួកគាត់មានអារម្មណ៍យ៉ាងម៉េច? អ៊ីចឹងហើយបានជាខ្ញុំសួរថាតើជួនកាលហ្នឹងគាត់អាចមើលឃើញដោយផ្ទាល់ភ្នែកគាត់ទេថាកម្មករទាំងអស់ហ្នឹង គាត់មានភាពសប្បាយរីករាយ?

**លោក ឱ ហ្វូ៖**

**ឆ៖** គាត់សប្បាយរីករាយណាស់ ពេលដែលគេថតកុនទុំង។

[១០:០៨:២៥]

**ស៖** ខ្ញុំចូលទៅប្រធានបទផ្សេងទៀត។ ខ្ញុំចង់និយាយអំពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅទីនោះ ក្នុងរយៈពេល៦ខែ ដូចដែលលោកបាននិយាយកាលពីម្សិលមិញ។ លោកនិយាយថាមានការបាក់ដី។ តើលោកអាចរៀបរាប់លម្អិតពាក់ព័ន្ធនឹងហេតុការណ៍បាក់ដីនេះបានទេ? លោកអាចជម្រាបបានទេ ថាហេតុអីបានជាដីហ្នឹងបាក់អ៊ីចឹង? ហើយមុនពេលដែលបាក់ដីហ្នឹង តើមានហេតុការណ៍អ្វីកើតឡើង លោកអាចរៀបរាប់ឲ្យបានលម្អិតបន្តិចបានទេ?

**ឆ៖** ទាន ដែលដីដែលវាបាក់នោះអ៊ីចេះ ពេលដែលយើងធ្វើការយប់ ពេលយើងធ្វើការយប់ក្រុមនីមួយៗហ្នឹងសុទ្ធតែចង់ប្រឡងប្រណាំងណាស់។ គេច្រោះដីខាងក្រោមឲ្យប្រហោងទៅ អាខាងលើហ្នឹងគេ-ចរាទៅ គេស្រណុកបុកដែកស្នៀងគាស់ ដល់ពេលដែលសម្រាកហ្នឹង ខ្ញុំក៏វាមិនបានប្រាប់ថាកុំឲ្យជ្រកក្នុងហ្នឹងនោះ អាងតែមនុស្សធំៗហើយ គាត់ទៅជ្រកក្នុងហ្នឹងនោះ។ ដល់គាត់ជ្រកក្នុងហ្នឹងមិនដឹងអាដីហ្នឹងបាក់មក វាបាក់ខ្លួនវា គ្មានពីណាទៅជាន់ទេ។ បើយើងនិយាយតាមធម៌ទៅថា វាកម្ម

វាដល់តែម្តង។ បើដីវាមួយផ្ទាំងធំប្រហែលជាមួយឡាន ពីរឡានហ្នឹងណ៎ា។ វាធំណាស់។ ដល់ខាងក្រោមយើងជីកអ៊ីចឹង យើងជីកទៅ វារលុងស្រួលទៅ អាខាងលើយើងច-វា ដល់ដែលទៅជ្រកពេលយប់នោះ គាត់ទៅជ្រក ទៅចូលក្រោមដែលយើងជីកហ្នឹងឯង បានវាបាក់សង្កិននោះ។ បើគាត់ច្រកឆ្ងាយបែបគាត់រត់រួចទេ អាហ្នឹងឆ្នាំទី១ ឆ្នាំដែលធ្វើប្រឡាយ១មករា ទី១មក។ អាហ្នឹងលើកដំបូងដែលបាក់ដីលើកដំបូង ដែលអាបាក់ដីឆ្នាំ៨៨នោះ អានោះវា-ចដើមត្នោតទេទាន។ ដើមត្នោតនៅនឹងអែបច្រាំងហ្នឹង យើងជីកវា ដល់ជីកៗឫសអ៊ីចឹងដែរ ដល់ជីកទៅគាត់អាល័យតែជីក មិនបានមើលអាដើមត្នោតមកក៏វាបាក់ទៅ។ អាហ្នឹងយកទៅភូមិភាគដែលព្យាបាលបួនខែបានជានោះ។ ដល់អាទី១ហ្នឹង វាអត់ជាទេស្លាប់បណ្តោយទាន។

**ស៖** នេះជាសំណួរពិបាក ក៏ប៉ុន្តែខ្ញុំនឹងព្យាយាមសួរឲ្យបានច្បាស់បំផុតតាមដែលអាចធ្វើទៅបាន។ តើលោកអាចជម្រាបបានទេថានេះគឺជាគ្រោះថ្នាក់ធម្មតា ឬក៏វាជាគ្រោះថ្នាក់ដែលបណ្តាលមកពីលក្ខខណ្ឌលំបាកលំបិនដែលតម្រូវឲ្យកម្មករធ្វើនោះ?

**ឆ៖** ខ្ញុំមិនដឹងឆ្លើយថាទៅម៉េចទេ ព្រោះអានេះការងារដែលធ្វើទាំងអស់គ្នា ប៉ុន្តែអ្នកដែលគេ-ចហ្នឹង គេចង់បានឆាប់របស់គេដែរ។ គេប្រឹងរបស់គេដែរ ដើម្បីឲ្យវាឆាប់ឲ្យវាបាន សម្រាប់ការងារ។ ហើយបើអ្នកដែលជ្រកមិនបានគិតខ្លួនឯង ដឹងធ្វើម៉េចទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំទៅឃើញថាដល់ម៉ោងហើយ អ៊ីចឹងប្រហែលដល់ពេលត្រូវឈប់សម្រាកហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសម្រាប់ នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ។

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី! លោកសាក្សីមុនពេលដែលយើងឈប់សម្រាក គឺយើងបានពិភាក្សាគ្នាអំពីបញ្ហាដែលលោកនិងមេក្រុមប្អូននាក់ទៀត ទទួលខុសត្រូវទៅលើស្ថានភាពរបស់អ្នកភូមិ ១០០នាក់ ទាក់ទងទៅនឹងការស្នាក់នៅ ក៏ដូចជាជំងឺដង្កាត់នានា។ ឥឡូវនេះ ខ្ញុំមានប្រធានបទមួយទៀត ដែលខ្ញុំចង់សាកសួរលោកផងដែរ។ ហើយប្រធានបទនេះ គឺអំពីបញ្ហាស្បៀងអាហាររបស់អ្នកភូមិ១០០ នាក់ដែលមកពីភូមិលោក។ តើលោកនិងមិត្តរបស់លោកប្អូននាក់ទៀតហ្នឹងជាអ្នកទទួលខុសត្រូវក្នុងការផ្តល់អាហារទៅដល់អ្នកភូមិ១០០នាក់នុំងមែនឬទេ?

**លោក ឱ ហួ៖**

**ឆ៖** អាហារចំពោះពលករ -- អត់ទោសហៅថាពលករ កម្មករក៏បាន ថាអ៊ីចឹងខ្ញិលណ៎ាទានកុំប្រកាន់។ កម្មករទាំង១០០នាក់ដែលយើងបានធ្វើនេះ ខ្ញុំបានស្នើពីភូមិមក គេដឹកយកមកឲ្យដល់ៗកន្លែង ទាំងបន្លែ ទាំងអង្ករ យកមកដល់កន្លែងយើង។

[១០:៣៤:២៦]

**ស៖** អ៊ីចឹងគឺលោកហើយនិងមិត្តលោកប្អូននាក់ទៀតទទួលខុសត្រូវលើបញ្ហាស្បៀងអាហារ ដែលត្រូវដឹកជញ្ជូនមកឲ្យកម្មករ ១០០នាក់នៅការដ្ឋានទំនប់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងទាន។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានលម្អិតបន្តិចបានទេថាតើការស្នើស្បៀងអាហារហ្នឹងស្នើដោយរបៀបណា? ហើយតើគេបញ្ជូនស្បៀងហ្នឹងដោយរបៀបណាមកកម្មករទាំង១០០នាក់ហ្នឹង? ថាតើក្នុងរយៈពេល៦ខែហ្នឹង គេមានដំណើរការបញ្ជូន ដឹកជញ្ជូនអីយ៉ាងដូចម្តេចដែរ ស្បៀងអាហារនោះ?

**ឆៈ** ស្បៀងអាហារយើងបាននិយាយគ្នាស្រេចហើយ មុននឹងចេញធ្វើការណ៎ាទាន។ មុនចេញធ្វើការ ទាំងអ្នកនៅឯក្រោយ ទាំងអ្នកទៅមុខ។ ប្រាប់ថាបើខ្ញុំស្នើអី លោកដែលឱ្យទៅតែចំពោះស្បៀងអាហារប្រចាំថ្ងៃ យើងកំណត់ថា ព្រឹកឡើងយកទៅដល់ៗ រាល់ថ្ងៃសម្រាប់មួយពេលៗហ្នឹងឯង ទោះគេ -- របបរួមវាអីចឹង ត្រូវអីចឹង គ្នាទៅយកពីកន្លែងរួមមក មួយសង្កាត់គេធ្វើតែមួយកន្លែងទេ យកមកគ្នាទុកនៅរោងបាយខ្លះ បញ្ជូនមកការដ្ឋានខ្លះ តែការដ្ឋានគេត្រូវឱ្យបានច្រើនជាងនៅឯភូមិ ព្រោះការងារវាធ្ងន់ តែច្រើនហ្នឹង ក៏មិនច្រើនហួសប៉ុន្មានទេទាន វាមួយពេល យើងនិយាយមួយកំប៉ុងទៅចុះ។ ហើយគិតទៅគ្នាប៉ុន្មាននាក់ គេយកប៉ុណ្ណឹងទៅ។ បើទោះជាមានកូនក្មេង ដែលជាកូនរបស់ពលករទៅជាមួយហ្នឹង ក៏គេគិតក្នុងហ្នឹងដែរ ដែលកុមារតូចៗដែលជាកូនគ្នាទៅណោះ! ក៏គេគិតក្នុងហ្នឹងឱ្យដែរ។

**សៈ** ឥឡូវនេះ ខ្ញុំនិយាយពីទំនប់១មករា។ លោកបាននិយាយអំពីចង្ក្រានបាយ តើៗនៅការដ្ឋានហ្នឹង គេមានចង្ក្រានបាយឱ្យលោកដែរ គឺបានន័យថា គេមានចង្ក្រានបាយសម្រាប់អ្នកភូមិ១០០នាក់ដែលយកម្ហូបពីភូមិមកចម្អិន ឬមួយក៏យ៉ាងម៉េច?

**ឆៈ** ចំពោះអាហារ យើងទៅដល់ យើងរៀបចំចង្ក្រានខ្លួនយើង។ ក្នុងមនុស្សដែលនៅធ្វើការនៅចង្ក្រានហ្នឹង វាតែបួននាក់ទេទាន ទាំងរែកទឹក ទាំងពុះអុស ទាំងអីទាំងអស់ តែបួននាក់ទេ សម្រាប់មនុស្ស១០០នាក់ហូបហ្នឹង។ ហើយខ្ទះពីរទៅ ឆ្នាំងសម្លមួយទៅ ប៉ុណ្ណឹងឯង ឆ្នាំងដាំទឹកមួយទៅ ហើយឆ្នាំងដាំទឹកនៅការដ្ឋានហ្នឹង គេ -- ខាងការដ្ឋាន គេដោះស្រាយរួមទេទាន។

[១០:៣៨:០៤]

**សៈ** លោកអាចប្រាប់បានទេថាជាទូទៅ កម្មករ១០០នាក់ ដែលក្រោមការគ្រប់គ្រងរបស់លោកហ្នឹង តើពួកគេហូបយ៉ាងដូចម្តេចដែរនៅពេលព្រឹកគេហូបអ្វី ពេលថ្ងៃ ពេលល្ងាច គេមានអ្វីហូបដែរឬទេ? ដូច្នេះ ខ្ញុំចង់ដឹងថាជារួម ឬក៏ជាមធ្យមហ្នឹង តើមនុស្ស១០០នាក់ ហ្នឹងគាត់មានការហូបចុកហ្នឹងយ៉ាងដូចម្តេចដែរ?

**ឆៈ** នៅកន្លែងការដ្ឋាន មិនជិតទេទាន ដល់ពេលទៅហូបបាយ យើងកាន់ចានមួយៗម្នាក់ទៅៗកន្លែងគេដាំបាយហ្នឹង គេដួសដាក់មក មួយវែកៗម្នាក់ទៅណាទាន។ ហើយក៏សម្ល ក៏គេដួសមកឱ្យទៅម្នាក់ៗបើយកចានទៅបីនាក់ហ្នឹង ចានសម្លហ្នឹង ក៏ពិសាបីនាក់ហ្នឹងទៅតាមស្ម័គ្រចិត្តនៃមនុស្សទាំងអស់នោះទេទាន ហើយគ្មានធ្វើអាដែង អាកន្លែងអង្គុយជាតុ ជាអីទេ យើង -- គ្មានកន្ទេលទេ អង្គុយចោងហោងនឹងដី។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ លោក ហើយនិងមិត្តរបស់លោកបួននាក់ទៀត គឺជាអ្នកទទួលខុសត្រូវទៅលើ -- គឺជាអ្នកទទួលខុសត្រូវ ធានាថាមនុស្ស១០០នាក់ដែលនៅក្រោមការគ្រប់គ្រងរបស់លោកហ្នឹង គឺទទួលបានអាហារទាំងពេលព្រឹក ពេលថ្ងៃ និងពេលល្ងាច តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំ អង្គាល់ដែលខ្ញុំធ្វើប្រឡាយហ្នឹងពេលព្រឹកគ្មានទេទាន គ្មានបាយហូបទេ បាយតែពីរពេលតែព្រឹក -- តែថ្ងៃត្រង់ ហើយនិងល្ងាចទេទាន ប៉ុណ្ណឹងទេ។ អត់មានពេលព្រឹកទេ។

**ស៖** ខ្ញុំយល់ ប៉ុន្តែទាក់ទងទៅនឹងការរៀបចំ គឺថាលោកហើយនិងមេក្រុមបួននាក់ទៀតហ្នឹង គឺជាអ្នកចាត់ចែង គឺជាអ្នកធានាថាមនុស្ស ១០០នាក់ហ្នឹង គាត់មានអាហារហូបចុកនៅពេលៗបាយនីមួយៗតើអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែនទាន។

**ស៖** អ៊ីចឹង លោកហើយនិងមេក្រុមទាំងបួននាក់គឺថាមានចេតនាធានា ឬក៏មានចេតនាថារកឲ្យបានម្ហូបអាហារគ្រប់គ្រាន់សម្រាប់ប្រជាជន១០០នាក់ ខ្ញុំដឹងថាពេលខ្លះវាមិនគ្រប់គ្រាន់មែន ប៉ុន្តែលោកមានគោលដៅធ្វើម៉េចឲ្យបានគ្រប់គ្រាន់អ៊ីចឹងមែនទេ?

[១០:៤១:២០]

**ឆ៖** បាទ អ៊ីចឹងមែនទាន គឺយើងត្រូវធ្វើម៉េចឲ្យបានគ្នា កម្មកររបស់យើងទាំងអស់ឲ្យបានហូបឲ្យគ្រប់គ្រាន់ដើម្បីនឹងការធ្វើការងារទាន។

**ស៖** ឥឡូវនេះ ខ្ញុំមានសំណួរមួយទៀតអំពីសមាសភាពក្រុម គឺមានសាក្សីមួយគាត់និយាយថាក្រុមកម្មករមកពីភូមិហ្នឹងពេលខ្លះគេដូរវេនគ្នា។ ដូច្នេះ ខ្ញុំចង់ដឹងថាតើមនុស្ស ១០០នាក់មកពីភូមិលោកហ្នឹង គឺគាត់ធ្វើការនៅហ្នឹងរហូតក្នុងរយៈពេល៦ខែ ឬក៏លោកមានដូចមនុស្សមកពីភូមិផ្សេង មកដូចជំនួសអ្នកនៅក្នុងក្រុមហ្នឹងដែរ?

**ប្រធានអង្គជំនុំ៖**

មានៗមូលដ្ឋានឯកសារយោងអ្វីដែរទេលោកមេធាវី? ប្រសិនជាមានសូមបង្ហាញនូវលេខឯកសារនិងលេខ ERN ផង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនិយាយអំពីសាក្សីដែលនឹងមកនៅពេលបន្ទាប់។ ខ្ញុំមិនច្បាស់ថាតើគាត់និយាយអំពីអ្វីនោះទេ គាត់និយាយអំពីក្រុម។ ដូច្នេះ ខ្ញុំនិយាយមិនច្បាស់លាស់អំពីចំណុចនេះ។ ដូច្នេះខ្ញុំមិនចង់និយាយពីអ្វីដែល

សាក្សីនោះគាត់និយាយទេ ប៉ុន្តែខ្ញុំចង់និយាយអំពីក្រុម ថាតើលោកសាក្សីហ្នឹងគាត់មានផ្លាស់ប្តូរឈ្មោះ ផ្លាស់ប្តូរមនុស្សឬក៏អត់ទេ។ ដូច្នេះ ខ្ញុំដកសំណួរខ្ញុំចេញ។

**ស៖** ឥឡូវខ្ញុំចង់សួរសាក្សី ថាតើក្នុងនាមលោកជាមេដឹកនាំក្រុម ថាតើលោកមានផ្លាស់ប្តូរសមាជិកក្នុងចំណោមមនុស្ស ១០០នាក់ហ្នឹង ឬមួយក៏មនុស្ស ១០០នាក់ហ្នឹង ធ្វើការរហូតក្នុងរយៈពេល ៦ខែហ្នឹង ដោយមិនមានការផ្លាស់ប្តូរអ្នកផ្សេងមកពីភូមិទេ?

**លោក ឱ ហួ៖**

**ឆ៖** មានដែរទាន មានអ្នកផ្លាស់ប្តូរដែរ មានផ្លាស់ប្តូរគ្នា។

[១០:៤៤:00]

**ស៖** អ៊ីចឹងគឺលោក ហើយនិងមេក្រុមបួននាក់ទៀតហ្នឹង គឺជាអ្នកទទួលខុសត្រូវក្នុងការធានាថាមានមនុស្ស១០០នាក់ មិនចាំបាច់ថាមនុស្ស ១០០នាក់ហ្នឹងជានរណាទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទធ្វើម៉េចឲ្យតែគ្រប់ទៅណាទាន។ តើថាសមាជិកយើង ២០នាក់ហ្នឹង ឲ្យបាន២០នាក់ជាប់ទៅ ជាប់២០នាក់ទៅធ្វើការ។ ហើយបើការងារនោះវាធូរបានយើងអាចដកកម្លាំងបាន បើថាការងារនោះកំពុងសម្រុក យើងមិនអាចៗខ្វះទេ ព្រោះយើងធ្វើការនេះ បង្ខំ ដូចបង្ខំឲ្យស្រេច ក្នុង៦ខែហ្នឹង ឲ្យដល់កន្លែងពីទំនប់ ១មករា ដល់ថ្នល់បណ្តោយ។

**ស៖** តើមានធ្លាប់ទេដូចថា មានមនុស្សខ្លះនៅក្នុងក្រុម១០០នាក់ ហ្នឹងត្រូវបានគេដូរ ជំនួស ឬក៏ផ្លាស់ជាមួយអ្នកមកពីភូមិថ្មីហ្នឹង។ តើធ្លាប់មានករណីហ្នឹងទេ?

**ឆ៖** ធ្លាប់មាន ជួនកាលគ្នាអ្នកនៅឯណោះវាហត់នឿយខ្លាំង ក៏សុំ -- ខ្ញុំសុំ -- ដូចគាត់ថា "ខ្ញុំសុំទៅផ្ទះវិញ" ក៏គាត់ទៅៗ។ ទៅៗ ខ្ញុំក៏ត្រូវប្រាប់អ្នកនៅខាងក្រោយនោះថាឲ្យប្តូរមនុស្សមក។ ហើយមនុស្សក៏គេប្តូរមក។

**ស៖** ដោយពិចារណា ដោយគិតដល់ការផ្លាស់ប្តូរហ្នឹងថា តើក្នុងមួយពេលហ្នឹង មាន -- ថាតើគេជំនួស ឬក៏គេផ្លាស់ប្តូរមនុស្សហ្នឹងប៉ុន្មានដងដែរ ទៅតាមដែលលោកចាំហ្នឹង គេផ្លាស់ប្តូរមនុស្សពីភូមិមកការដ្ឋានហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** ការផ្លាស់ប្តូរហ្នឹងទៀងទេ គឺជួនកាលអ្នកខ្លះគេអត់ដូរទេ អ្នកខ្លះគេដូរ។ អ្នកខ្លះដែលគេមិនដូរហ្នឹង ព្រោះមនុស្សហ្នឹងចម្រើនដល់ការងារខ្លាំង។ អ្នកដែលដូរយើងឃើញថា គ្នាវាយ៉ាប់យ៉ឺនក្នុងកម្លាំងការងារ គ្នាសុំទៅធ្វើការឯក្រោយវិញ។ ដល់ទៅក្រោយឯណោះក៏ត្រូវតែធ្វើការដែរ ព្រោះទៅ

ក្រោយ ទៅបោចរពាក់យកមកឲ្យតាៗធ្វើបង្គី។ តាៗគាត់ធ្វើបង្គីនៅក្រោយហ្នឹងឯង។ ហើយមិនមែនថាអ្នកដែលដូរហ្នឹងទៅដល់សម្រាកទេទាន អត់បានសម្រាកទេ មួយជីវិតនៃការងារការដ្ឋានប្រឡាយ ១មករា នោះ។ បានន័យថា ការដ្ឋាន ១មករា ហ្នឹងមិនមានថាអ្នកណាម្នាក់ធ្វើទេ គឺធ្វើទាំងអស់គ្នាហ្នឹងឯង។

[១០:៤៧:៤៩]

**ស៖** លោកសាក្សី ខ្ញុំបានសួរអំពីក្រុម អំពីការដំណើរការរបស់ក្រុមមនុស្ស ១០០នាក់ដែលលោកគ្រប់គ្រង រួមជាមួយមេក្រុមទាំងបួននាក់នោះរួចទៅហើយ។ ក៏ប៉ុន្តែយើងដឹងថា មានម្តងម្កាលដែលថា គឺថាមាននៅពេលការដ្ឋានហ្នឹង គឺមានមនុស្សដល់ទៅ ២០.០០០នាក់ធ្វើការ។ តើលោកអាចធ្វើការប្រៀបធៀបបានទេ? ថាតើលោក ហើយនិងមេក្រុមទាំងបួននាក់ដែលគ្រប់គ្រងទៅលើក្រុមកម្មករ ១០០នាក់ហ្នឹង តើលោកអាចធៀបជាមួយនឹងមេក្រុម១០០នាក់មកពីភូមិផ្សេងទៀតនោះបានទេ? តើលោកអាចធៀបបានទេ ថាតើលោកធៀបទៅនឹងមេក្រុម មេភូមិ មកពីភូមិផ្សេងៗក្នុងតំបន់៤២ហ្នឹង ឃើញការអនុវត្តការងារហ្នឹងមានលក្ខណៈប្រហែលគ្នា ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថា ដែលតាមដែលខ្ញុំមើលកម្លាំងគេធ្វើហ្នឹង ដូចគ្នាខ្លះ មិនដូចគ្នាខ្លះ។ តែខ្ញុំមិនដឹងការងារហ្នឹងគេចាត់ចែងយ៉ាងម៉េចទេណា បញ្ហាគេរៀងខ្លួន។ ខ្ញុំមិនអាចឆ្លើយឲ្យពិស្តារជូនលោកមេធាវីបានទេ។

**ស៖** នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់នោះ តើលោកសង្កេតឃើញថា ស្ថានភាពការងាររបស់ក្រុមផ្សេងមកពីភូមិផ្សេងហ្នឹង តើលោកមើលទៅឃើញថាមេក្រុមហ្នឹងគេធ្វើ --មេក្រុមផ្សេងហ្នឹងគេធ្វើយ៉ាងម៉េចដាក់ជាមួយកូនក្រុមគេ ហើយតើលោកអាចធៀបមេក្រុមផ្សេងហ្នឹងជាមួយនឹងលោកហ្នឹង តើមានលក្ខណៈយ៉ាងដូចម្តេចដែរ?

**ឆ៖** វាខុសគ្នាខ្លះដែរទេ ជួនកាលគេលេង មេក្រុមផ្សេងហ្នឹង គេប្រឹងផ្សេងទៅ គេរៀបចំវិធីសាស្ត្រគេផ្សេងទៅ ឯខ្ញុំក៏ទៅតាមបញ្ហារបស់ខ្ញុំផ្សឹងទៅ។ វាអត់ដូចគ្នាត្រង់ហ្នឹងទាន។

[១០:៥០:៤៣]

**ស៖** ប៉ុន្តែចំពោះស្ថានភាពការងារ ក៏ដូចជាស្ថានភាពស្បៀងអាហារ ថាតើលោក ហើយនិងមេក្រុមលោកទាំងបួននាក់នោះ ថាតើលោក ហើយនិងមេក្រុមបួននាក់ហ្នឹង លោកអាចគិតថាពួកលោកជាក្រុមដែលតឹងតែងខ្លាំង ឬក៏ក្រុមដែលតឹងតែងល្មម ធូរល្មម ឬក៏ក្រុមដែលធូរខ្លាំង? តើលោកធៀបក្រុមលោកជាមួយនឹងក្រុមផ្សេងៗដែលនៅក្បែរលោកនឹងបានទេ?

**ឆ៖** ខ្ញុំជម្រាបទៅថា បើកាលណាដែលយើងសម្រុកខ្លាំង យើងប្រមូលកម្លាំងយើងទាំងអស់គ្នា សួរយោបល់គ្នាទាំងអស់គ្នា តើយើងធ្វើយ៉ាងម៉េចឱ្យសម្រេចការងាររបស់យើង។ បើគេទាំងអស់គ្នាគេថាត្រូវធ្វើអ៊ីចេះធ្វើអ៊ីចុះ យើងយកតាមមតិ ទោះបីជាប្រជាជនថ្មីក៏ដោយ ប្រជាជនចាស់ក៏ដោយដែលគេមានរបៀបពិសោធការងារ យើងធ្វើតាមគេទៅអត់ខុសទេទាន។

**ស៖** តើខ្ញុំអាចនិយាយបានទេថា បទពិសោធរបស់កម្មករនៅការដ្ឋាន កម្មករនីមួយៗ គឺអាស្រ័យទៅលើមេក្រុម ឬក៏អ្នកគ្រប់គ្រងរបស់គេនីមួយៗ។ តើខ្ញុំអាចនិយាយអ៊ីចឹងបានទេ?

**ឆ៖** គិតក៏គ្នាថាអ៊ីចឹងក៏បាន តែសំខាន់នៅលើកម្មករទេ បើកម្មករគេស្ម័គ្រចិត្តហើយ មេក្រុមចេះតែដើរតាមគេទៅ។ យើងមិនអាចបង្ខំទេ ពីព្រោះមនុស្សមានចិត្តដូចគ្នា គេក៏មានចិត្ត យើងក៏មានចិត្ត។ បើកាលណាឱ្យតម្លៃទៅលើគេហើយ គេប្រឹងហើយ បើយើងមិនឱ្យតម្លៃទៅលើគេទេ គេអាក់អន់ចិត្ត។ បើយើងឱ្យតម្លៃទៅលើគេ ទោះបីជាការងារប៉ុនណាក៏គេប្រឹងដែរ។

[១០:៥៣:១០]

**ស៖** សូមអរគុណលោកសាក្សី។ សំណួរបន្ទាប់របស់ខ្ញុំគឺចង់សួរអំពី គឺថាជាទូទៅតើលោកយល់ទេថាគោលដៅនៃការកសាងទំនប់ហ្នឹងគឺមានគោលដៅអ្វីដែរ? ហេតុអ្វីបានជាអង្គការសម្រេចកសាងទំនប់ ១មករានេះ?

**ឆ៖** អ៊ីចឹង ខ្ញុំបាទមិនដឹងទេណាស់។ ខ្ញុំបាទដែលដឹង ដឹងតែថា តាមគំនិតរបស់ខ្ញុំគឺថា អង្គការធ្វើហ្នឹងដើម្បីយកទឹកធ្វើស្រែ តែអ្នកខ្លះគេបាននិយាយថា អង្គការលោកធ្វើហ្នឹង ដើម្បីដាក់វារីអគ្គីសនី តែតាំងពីហ្នឹងមកវាមិនឃើញមានវារីអគ្គីសនីទេណាទាន ប៉ុន្តែកន្លែងគេធ្វើហ្នឹងមានមែន។ គេដាក់ថានេះកន្លែងវារីអគ្គីសនី ហើយខ្ញុំក៏វាមិនចេះដែរ ចេះតែបាទនឹងគេទៅ ដែលចំពោះមិត្តភ័ក្តដែលដើរទៅមើលថ្ងៃសម្រាក។ ហើយដែលចំពោះខ្ញុំផ្ទាល់ ខ្ញុំដឹងតែថាជីកប្រឡាយហ្នឹងយកមកធ្វើស្រែទេទាន។

**ស៖** តើអ្នកណាជាអ្នកទទួលប្រយោជន៍ក្រោយចុង -- គឺថាអ្នកដែលទទួលប្រយោជន៍ក្រោយគេនៃទំនប់ហ្នឹង ប្រសិនបើទំនប់ហ្នឹងវាដំណើរការទៅវាមានប្រសិទ្ធភាព។ តើអ្នកណាជាអ្នកទទួលប្រយោជន៍ពីទំនប់នោះ?

**ឆ៖** ទំនប់ហ្នឹងធ្វើមួយឆ្នាំជីកដល់កំប៉ើយ។ ពួកអ្នកស្រុកយើងទាំងអស់គ្នាហ្នឹង បានទទួលណាទាន។ បានធ្វើស្រែប្រាំងចាប់ពីឆ្នាំ១៩៧៨មក យើងធ្វើជាប់រហូតៗដល់សព្វថ្ងៃដែលគេជួសជុលរួចទៅទៀត។ សព្វថ្ងៃគេបានស្រូវទាំងរយទាំងពាន់ណាទាន។

[១០:៥៥:៥៤]

**ស៖** តាមដែលលោកដឹង គឺថា តាមដែលលោកយល់ គឺថាមនុស្ស១០០នាក់ដែលនៅក្នុងក្រុមរបស់លោកហ្នឹង មនុស្ស១០០នាក់ដែលធ្វើការកសាងទំនប់ហ្នឹង នៅពេលក្រោយក៏ពួកគាត់អាចទទួលប្រយោជន៍ពីទំនប់ហ្នឹងដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន ទាន។ សព្វថ្ងៃគេបានទឹកហ្នឹងឯងព្រោះស្រូវ។

**ស៖** អ៊ីចឹងគោលបំណងចម្បងនៃទំនប់ហ្នឹង គឺដើម្បីផ្តល់ស្បៀងអាហារដល់ប្រជាជនទាំងអស់រួមទាំងប្រជាជន១០០នាក់ ហើយក៏ជាមូលហេតុដែលលោកមានមោទនភាពក្នុងការកសាងទំនប់ហ្នឹងដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន ទាន។

**ស៖** តើលោកសង្កេតឃើញថា កម្មករ១០០នាក់ ដែលធ្វើការនៅទំនប់ហ្នឹង តើពួកគាត់អាចឃើញអំពីលទ្ធភាព ដែលថាទំនប់ហ្នឹងនឹងផ្តល់ប្រយោជន៍ ដែលពួកគាត់កំពុងសង់ហ្នឹង នឹងផ្តល់ប្រយោជន៍ដល់ពួកគាត់ដែរឬទេ?

**ឆ៖** សព្វថ្ងៃទទួលដែរទាន។ គេបានទទួលគ្រប់គ្នាដែរ។ អ្នកខ្លះដែលមានស្រែនៅខាងក្រោមហ្នឹងក៏គេបានធ្វើស្រែនៅក្រោមហ្នឹង តាមលទ្ធភាពដែលគេទទួលបានតាមអ្នកដែលធ្វើ។ អ្នកខ្លះក៏គេដាំបន្លែ ដាំបង្កាទៅ អ្នកខ្លះក៏ធ្វើតែស្រែទេ។

[១០:៥៨:០០]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានសំណួរមួយចុងក្រោយទាក់ទងទៅនឹងទំនប់។ តើលោកធ្លាប់ឃើញការរៀបការនៅការដ្ឋានទំនប់នោះដែរឬទេ? តើការរៀបការហ្នឹងគេធ្វើតែនៅតាមភូមិទេ ឬក៏នៅការដ្ឋានទំនប់ហ្នឹង ក៏គេមានការរៀបការដែរ?

**ឆ៖** ការដែលរៀបការហ្នឹង រួចទំនប់ ១មករា ឯជើង។ ១មករា អាទី១ យើងធ្វើរួច ដល់រដូវស្លូង អាហ្នឹងបានគេរៀបការនៅឯភូមិគេឯនេះទេ។

**ស៖** អ៊ីចឹង លោកចង់និយាយថា ការរៀបការហ្នឹង គេអត់មានធ្វើ ឬក៏អត់មានពាក់ព័ន្ធអីនឹងការកសាងទំនប់ហ្នឹងទេ។ តើលោកចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** មួយពេលដែលយើងធ្វើទំនប់ហ្នឹង យើងប្រឹងតែធ្វើទំនប់ទេទាន អត់បានរៀបការទេ យើងប្រឹងធ្វើទៅ។ ដល់ទៅរដូវដែលថា យើងចុះធ្វើស្រែហើយ មកគេឆ្លៀតពេលមួយថ្ងៃអ៊ីចឹងទៅ ក្នុងមួយឃុំ

ហ្នឹង គឺផ្ទៀតពេលមួយថ្ងៃអ៊ីចឹងទៅ គេការម្ដង។ អ៊ីចឹងបានវាច្រើនគួរណាទាន។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំបានសួរលោកច្រើនអំពីតួនាទីរបស់លោកជាមេដឹកនាំក្រុមក្នុងការកសាងទំនប់ ហើយឥឡូវនេះ ខ្ញុំមានសំណួរបន្ថែមពីរបីទៀត ទាក់ទងទៅនឹងតួនាទីរបស់លោកជាមេភូមិវិញ។ ព្រោះខាងព្រះរាជអាជ្ញាផ្តោតសំខាន់តែទៅលើតួនាទីរបស់លោកជាមេភូមិ។ ឥឡូវនេះ ខ្ញុំសូម ខ្ញុំមិនសួរអំពីទំនប់ទេ ខ្ញុំសួរអំពីភូមិវិញម្ដង។ ជាដំបូង ខ្ញុំចង់សួរលោកទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយកាលពីម្សិលមិញ។ គឺថាកាលពីម្សិលមិញ ឆ្នាំ៧៨ លោកបានចាកចេញការងារជាមេភូមិ ដោយសារអង្គការលែងទុកចិត្តលោក។ តើលោកអាចប្រាប់បានទេ ថាហេតុអ្វីបានជាអង្គការលែងទុកចិត្តលោក? តើលោកអាចប្រាប់បានទេ?

[១១:០១:០២]

**ឆ៖** ការងារហ្នឹងខ្ញុំមិនដឹងដែរទេ មិនដឹងជាហេតុអ្វីដែរ បានជារំសាយ ប៉ុន្តែអ្នករំសាយ តិចបានរស់ណាស់ទាន។ តែរំសាយគេឲ្យធ្វើវិញ ដល់ធ្វើវិញ ពេលហ្នឹងដែលគេចាប់កំហុស ឯខ្ញុំគេរំសាយទៅ គេរំសាយអត់មានឲ្យធ្វើអ្វីទេទាន វាទទួលដាច់ដោយរណសិរ្សសាមគ្គីសង្គ្រោះជាតិទៅ។

**ស៖** តើអង្គការមានដាក់វិន័យ ឬក៏មានគេ -- គេមានបញ្ជូនលោកទៅមន្ទីរអប់រំអ្វីទេ នៅពេលដែលអង្គការរំសាយលោកនោះ?

**ឆ៖** ខ្ញុំដែលគេរំសាយទៅ អត់មានទៅកន្លែងអប់រំឯណាទេ។ ខ្ញុំកាន់គោ កាន់ក្របីទៅភ្ជួរដូចប្រជាជនធម្មតាហ្នឹងឯង។ គេធ្វើម៉េច ក៏ខ្ញុំធ្វើអ៊ីចឹងដូចគេ។ កាលនៅធ្វើមេភូមិ ក៏ខ្ញុំគ្រាន់តែវាមិនបានកាន់គោទៅភ្ជួរទេ វាទៅពិនិត្យមើលទៅទូទៅ។ ដល់ពេលរំសាយទៅ ក៏ខ្ញុំធ្វើតែមួយកន្លែងទៅ។ ជាកម្មករដូចគេ ដូចឯងដែរទេ។

**ស៖** ក្នុងរយៈពេលបីឆ្នាំ គឺក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ ក្នុងនាមលោកជាមេភូមិ តើលោកធ្លាប់បញ្ជាឲ្យចាប់មនុស្សដែរឬទេ? តើលោកធ្លាប់មានបញ្ជាឲ្យចាប់មនុស្សដែរទេ?

**ឆ៖** ទានប្រុស រឿងបញ្ជាឲ្យចាប់ ខ្ញុំមិនមានទេ ស្រេចនៅលើការងារសន្តិសុខសង្កាត់ចុះ។ គេរកឃើញក៏ឃើញទៅ ខ្ញុំមិនត្រូវការទេ ខ្ញុំគិតតែពីរឿងស្រែ ហើយនិងទំនប់ និងសុខភាពប្រជាជននៅក្នុងភូមិទេទាន។

[១១:០៣:០១]

**ស៖** តើលោកមានធ្លាប់ស្នើសុំការណែនាំដើម្បីបញ្ជូននរណាម្នាក់ទៅអប់រំ ដោយសារតែគាត់

មានប្រព្រឹត្តបទល្មើសស្រាល បទល្មើសតូចតាច ឬក៏បទល្មើសធ្ងន់អីដែរទេ?

**ឆ៖** ការងារដែលអប់រំ ខ្ញុំអប់រំមិនដែលយកឲ្យគេទៅអប់រំទេ។ ខ្ញុំនិយាយតែខ្លួនខ្ញុំ ហើយនិងពួកម៉ាកមិត្តភក្តិរបស់ខ្ញុំដែលធ្វើការហ្នឹងជាមួយគ្នា អប់រំគ្នាទៅ ដូចយើងបងប្អូនអប់រំគ្នាឯង ដូចបងប្អូននៅក្នុងផ្ទៃតែមួយដែលអប់រំគ្នាឯង។ អ៊ីចឹង មិនដែលយកទៅដើម្បីឲ្យគេដទៃទៀតគេអប់រំទេ។

**សៈ** ចុះប្រសិនបើមានអ្នកភូមិណាម្នាក់មកតវ៉ាថាគាត់ឃ្លាន ឬក៏ប្រាប់ថា -- ឬក៏ថាមានអ្នកលួចដំឡូង លួចអីដោយសារឃ្លានហ្នឹង។ ថាតើក្នុងស្ថានភាពបែបហ្នឹង ក្នុងនាមលោកជាមេភូមិហ្នឹងលោកដោះស្រាយដោយរបៀបណា?

**ឆ៖** បាទ រឿងដំឡូង រឿងអី ខ្ញុំប្រាប់ឲ្យដាំតើ។ ដាំទៅគេគាស់ស៊ីខ្លួនគេទៅ។ របស់គេផ្ទាល់ទៅឯរួមរបស់ៗរួមហ្នឹង យើងដាំរួមផ្សេងតើ! តាមផ្ទះរបស់គេដែលចែកឲ្យដាំក្បាល២៥ បណ្ដោយ៣០ហ្នឹងដាំទៅ។ ហើយមាន់ក៏ចិញ្ចឹមទៅ ក៏ប៉ុន្តែបើរោងបាយត្រូវការ ត្រូវតែឲ្យគេខ្លះ ដូចជា មាន់ ដូចជាដំឡូងអាហ្នឹងមិនបាច់ទេ គេមិនបាច់ចាំរោងបាយត្រូវការ មិនត្រូវការទេ វាគ្មានត្រូវការអីទេ។

[១១:០៦:២២]

**សៈ** តើមានអ្នកធ្លាប់មកតវ៉ាជាមួយលោកថា អត់អីហូបដែរឬទេ? ហើយប្រសិនបើមានតវ៉ាហ្នឹង តើលោកមានបញ្ជូនគេទៅណាអីទៀតទេ? តើនៅពេលដែលគេតវ៉ាហើយហ្នឹងមានធ្វើអ្វីទៀតទេ?

**ឆ៖** មិនដែលទេទាន មិនដែលមានពីណាមកតវ៉ាអ៊ីចឹងទេទាន។ ពីព្រោះថាម្នាក់ៗដូចខ្ញុំបាននិយាយដែរថា យើងប្រជុំម្ដងៗ គេហៅថា អប់រំ ប្រជុំអប់រំ ឬប្រជុំបំពាក់បំប៉នស្មារតីអ៊ីចឹងចុះទានកាលណោះគេនិយាយអ៊ីចឹងទាន។ បើប្រជុំបំពាក់បំប៉នស្មារតី គឺក្រោយពេលដែលយើងមកពីធ្វើការរួមយើងផ្ដៀតទៅដាំទៅតាមដំបូក ទៅតាមអីទៅ។ ហើយដីកន្លែងខ្ញុំវាៗមើមណាស់ ដំឡូង វាស្រួលណាស់គឺថាដាំទៅតែ៦ខែបានពិសាហើយ ហើយដំឡូងដែលយើងដាំពីខែប្រាំងនោះក៏វាពិសាខែវស្សាទៅ។

**សៈ** សូមអរគុណលោកសាក្សី។ ក្នុងរយៈពេលបីឆ្នាំដែលលោកធ្វើជាមេភូមិ តើលោកធ្លាប់ចូលក្នុងបរិវេណមន្ទីរសន្តិសុខ ឬក៏មន្ទីរអប់រំដែរឬទេ? តើលោកធ្លាប់ដែរទៅក្នុងបរិវេណមន្ទីរអប់រំ មន្ទីរសន្តិសុខអីដែរទេ?

**ឆ៖** ខ្ញុំមិនដែលឡើងអីទេ ព្រោះស្មារតីខ្ញុំតិចណាស់។

**សៈ** ខ្ញុំយល់ចម្លើយរបស់លោក ប៉ុន្តែខ្ញុំចង់សួរថា តើលោកធ្លាប់ឃើញគេសម្លាប់មនុស្សដែរឬទេ ក្នុងពេលដែលលោកធ្វើជាមេភូមិនោះ?

[១១:០៨:៣៥]

**ឆ៖** ខ្ញុំមិនដែលឃើញទេទាន។ មិនដែលឃើញមែន ដឹងគេស្លាប់របៀបម៉េចទេទាន ព្រោះខ្ញុំដូចខ្ញុំបានជម្រាបអ៊ីចឹង ស្មារតីខ្ញុំតិចណាស់។ វាឃើញអ៊ីចឹងៗមិនៗស្រួលទេ ខ្ញុំមិនសូវចង់ដឹងទេ។

**ស៖** ម្សិលមិញគេសួរលោកអំពីគ្រួសារប្រាំបីគ្រួសារ ដែលស្នាក់នៅក្នុងភូមិរបស់លោក។ ហើយលោកនិយាយថា បន្ទាប់មកគេបញ្ជូនអ្នកភូមិ ប្រាំបីគ្រួសារហ្នឹងទៅកន្លែងផ្សេង។ តើអាចទេដែលថាគេបញ្ជូនអ្នក ប្រាំបីគ្រួសារហ្នឹងទៅមន្ទីរអប់រំកែប្រែនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

គ្រាន់តែជាកំណត់ត្រាឲ្យច្បាស់លាស់ ទៅតាមដែលខ្ញុំចាំ គឺថាមានគ្រួសារ១៥ ហើយក្នុងហ្នឹងសាក្សីគាត់ព្យាយាមលាក់ប្រាំបី ហើយប្រាំពីរត្រូវបានបញ្ជូនទៅ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់បញ្ជាក់ទេ សាក្សីគាត់លាក់ប្រាំបី ហើយបញ្ជូនទៅប្រាំពីរ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របជាមួយខាងព្រះរាជអាជ្ញា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះ ខ្ញុំចង់សួរសាក្សី ថាតើអាចទេដែលថាគ្រួសារទាំងប្រាំពីរហ្នឹងត្រូវបានគេបញ្ជូនទៅមន្ទីរអប់រំកែប្រែនោះ?

**លោក ឱ ហួ៖**

**ឆ៖** ខ្ញុំ -- កាលនោះ ខ្ញុំនៅធ្វើការនៅឯភូមិចាមទេណាទាន ប៉ុន្តែថ្ងៃដែលគេបញ្ជូនទៅហ្នឹង គេដឹកឡានទៅៗចម្ការកៅស៊ូទៅ ទៅឯណាខ្ញុំមិនដឹងទេទាន ប៉ុន្តែតាមអ្នកខ្លះថាយកទៅកន្លែងស្រឡៅទង ខ្ញុំក៏អត់បានដឹងទេ អាហ្នឹងជាផ្នែករបស់សន្តិសុខ ព្រោះខ្ញុំកាលនោះខ្ញុំដឹកនាំកម្លាំងទៅឯស្ទូងស្រែនៅឯភូមិចាមឯណោះ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ អ៊ីចឹងតើយើងអាចនិយាយបានដែរឬទេថាលោកមិនបានដឹងអំពីអ្វីដែលកើតឡើងចំពោះគ្រួសារទាំងប្រាំពីរនេះទេ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរៀបចំសំណួរលោកម្តងទៀត ហើយសំណួរអំមិញទំនងជានាំមុខផង ហើយសាក្សីស្តាប់សំណួរលោកមិនយល់ទេបានជាគាត់មិនឆ្លើយតប។ រៀបសំណួរឡើងវិញ ហើយជៀសវាងសំណួរនាំមុខ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំមិនច្បាស់ថា ខ្ញុំសួរសំណួរនាំមុខទេ ក៏ប៉ុន្តែឥឡូវខ្ញុំសូមសួរសំណួរហ្នឹងឡើងវិញ។ លោកសាក្សី តើជាការត្រឹមត្រូវដែរឬទេ ដែលថាលោកមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះគ្រួសារទាំងប្រាំពីរហ្នឹងទេ?

[១១:១២:៤៣]

**លោក ឱ ហ្វូ៖**

**ឆ៖** ខ្ញុំបានជម្រាបហើយទាន ថ្ងៃហ្នឹងខ្ញុំត្រូវទៅធ្វើការនៅការដ្ឋានស្ទូងឆ្ងាយពីភូមិ ប្រហែលជា ៧គីឡូ ឆ្ងាយពីភូមិ ខ្ញុំទៅដេកហ្នឹងទេ។ ហើយថ្ងៃហ្នឹង គេយកឡានមកដឹកដែលពួកអ្នកទៅហ្នឹងឯងតែត្រង់ថាអ្នកដឹកហ្នឹង គេយកទៅស្រឡៅទង ឬក៏ទៅចម្ការកៅស៊ូ ខ្ញុំមិនបានដឹងទេទានត្រង់ហ្នឹងនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សីដែលបានឆ្លើយនឹងសំណួរខ្ញុំ។

សូមអរគុណលោកប្រធាន ខ្ញុំសួរចប់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ បាទជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ខ្ញុំនឹងចោទសំណួររបស់លោក -- ទៅកាន់លោកមួយចំនួនដើម្បីសុំបំភ្លឺអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ ហើយនិងថ្ងៃនេះ។

[១១:១៤:២៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដើម្បីបន្តចេញពីសំណួរដែលសួរដោយសហភាគារបស់ខ្ញុំទាក់ទងទៅនឹងគោលបំណងនៃ

ការសាងសង់ទំនប់។ កាលពីម្សិលមិញ លោកបាននិយាយអំពីការប្រជុំមួយដែលលោកបានចូលរួមគឺ ប្រហែលជាម៉ោង១៣:៤៦នាទី ដែលលោកបានពន្យល់ថា ឃុំបានមកដើម្បីពន្យល់មកកាន់លោកអំពីអ្វី ដែលទាក់ទងទៅនឹងការសាងសង់ទំនប់ហ្នឹង ហើយគេពន្យល់លោកដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ពួក គាត់ពន្យល់អំពីរបៀបធ្វើការងារ គេពន្យល់ថាយើងត្រូវធ្វើការលំបាកលំបិនដើម្បីឱ្យមានប្រព័ន្ធស្រោច ស្រពមួយ គេពន្យល់ពីរបៀបលើកទំនប់”។ បាទ សូមបញ្ចប់ការដកស្រង់។ អម្បាញ់មិញលោកបាន ពន្យល់ទៅសហភាតារបស់ខ្ញុំថា លោកគិតថាគោលបំណងគឺដើម្បីមានទឹកធ្វើកសិកម្ម។ តើនេះវាមាន ទំនាក់ទំនងទៅនឹងអ្វីដែលគេបានពន្យល់លោកនៅថ្ងៃនោះដែរឬទេ អំពីរបៀបធ្វើទំនប់ គោលបំណងសង់ ទំនប់អីនេះជាដើមនេះ?

**ឆ៖** វាអ៊ីចេះលោកស្រី ដែលការគេពន្យល់ៗថាយើងធ្វើប្រឡាយដើម្បីបានទឹកយកទៅធ្វើស្រែ។ ហើយដល់ពេលដែលយើងប្រឹងធ្វើទៅវាបានដូចគេថាមែនទាន។

**ស៖** តើនៅពេលប្រជុំនោះ គេមានបានធ្វើការណែនាំផ្នែកបច្ចេកទេសដើម្បីឱ្យលោកចេះធ្វើការ ដែរឬទេ? ប្រសិនបើជាខ្ញុំមិនច្រឡំទេនៅក្នុងក្រុមដែលលោកគ្រប់គ្រងនោះ លោកគ្រាន់តែបានធ្វើការជីក ប្រឡាយនោះទេ តែប៉ុណ្ណឹងទេ។ តើខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំៗបាននាំកម្លាំងជីកប្រឡាយផ្ទាល់ទាន នាំកម្លាំងជីប្រឡាយផ្ទាល់ តែផ្ទាល់២០នាក់។ ឯ ៨០នាក់ទៀត ខ្ញុំចែកជាក្រុមៗ វាបានបួនក្រុមទៀត។ ហើយយើងទាំងអស់គ្នាហ្នឹងឯងប្រឹងធ្វើដូចគ្នា។

[១១:១៧:១៧]

**ស៖** នៅពេលប្រជុំដែលគេពន្យល់ពីគោលបំណងនៃការលើទំនប់ហ្នឹង តើគេបានបង្រៀនលោក ឬក៏ឱ្យសេចក្តីណែនាំផ្នែកបច្ចេកទេសដល់លោក ដើម្បីឱ្យលោកដឹងថាតើត្រូវជីកប្រឡាយហ្នឹងយ៉ាងណា ដែរឬទេ?

**ឆ៖** បាទគេប្រាប់ដែរទាន គេវាស់ឱ្យស្រេច គេៗធ្វើគេស្ទង់មកពីប្រឡាយហ្នឹងមក ចំនួនប៉ុនណា ទទឹងប៉ុនណា បាតក្រោមប៉ុនណា គេប្រាប់ទាំងអស់ទាន។ យើងជីកតាមបង្គង់គេទៅ ជម្រាលប៉ុនណា ផ្តេកប៉ុនណា យើងធ្វើតាមគេទាំងអស់។

**ស៖** តើអ្នកដែលធ្វើការណែនាំដល់លោកហ្នឹងជាអ្នកណាដែរ លោកចាំឈ្មោះដែរឬទេ?

**ឆ៖** អ្នកដែលណែនាំនោះគឺលោក ប៊ិន, លោក វុត កាលនោះទាន ដែលលោកជាគណៈកម្មការ ឃុំ។

**សៈ** ខ្ញុំក៏បានយល់ផងដែរ ថានៅពេលដែលលោកជីកប្រឡាយហ្នឹង លោកដេកនៅនឹងកន្លែងតែម្តង។ អ៊ីចឹងខ្ញុំ សំណួររបស់ខ្ញុំចង់ដឹងថា ពីព្រោះថានៅពេលដែលយើងជីកទំនប់ហ្នឹង យើងមិនជីកនៅតែកន្លែងទេ ព្រោះថាជីកបន្តទៅមុខរហូត។ អ៊ីចឹងខ្ញុំចង់សួរថាតើលោកនៅតែបន្តដេកនៅតែកន្លែងតែមួយទេ ឬក៏នៅពេលដែលយើងជីកបន្តទៅមុខបានឆ្ងាយហើយ យើងដូរកន្លែងដេកហ្នឹងតាមហ្នឹងដែរ?

[១១:១៩:២៩]

**ឆៈ** លោកស្រី ខ្ញុំសូមជម្រាបថាប្រឡាយហ្នឹង ដែលយើងជីហ្នឹង មិនបាច់ដូរទេ។ គេវាស់ឲ្យបើថា ១០០ម៉ែត្រហ្នឹង គឺថាល្មមមួយប្រាំងហ្នឹងប្រឹងម៉េចឲ្យទៅរួច ១០០ម៉ែត្រហ្នឹងចុះ។ ១០០ម៉ែត្របណ្តោយប្រឡាយ ជម្រៅផ្សេង ជម្រៅប្រឡាយហ្នឹងផ្សេង ទំហំផ្សេង។ អ៊ីចឹងយើងធ្វើយ៉ាងម៉េចឲ្យគ្រប់ ១០០ម៉ែត្រ មួយបណ្តោយប្រឡាយ។ អ៊ីចឹងអត់រ៉ុវផ្ទះទេ។ យើងធ្វើ៦ខែ ហ្នឹងឲ្យតែវាចប់ទៅបានហើយ។

**សៈ** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថាក្នុងរយៈពេល៦ខែហ្នឹងលោកនៅ ដេកនៅកន្លែងដដែលទេ ព្រោះថានៅក្នុងរយៈពេល៦ខែហ្នឹង គឺត្រូវជីកយ៉ាងណាឲ្យបានត្រឹមតែប្រវែង ១០០ម៉ែត្រហ្នឹងហើយ តែប៉ុណ្ណឹងទេ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆៈ** បាទ ត្រឹមត្រូវណាស់លោកស្រី ត្រឹមត្រូវ។

**សៈ** ខ្ញុំ -- មិនដឹងថាខ្ញុំយល់លោកមិនច្បាស់ឬក៏យ៉ាងណាទេ តើ -- ចង់និយាយថាលោកនៅចម្ងាយប៉ុន្មានពីជើងទំនប់ហ្នឹងដែរ? គឺថាមានក្រុមផ្សេងទៀតគេធ្វើការនៅហ្នឹងដែរ គេអ្នកផ្សេងនោះ គេអ្នកលើកទំនប់។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកនៅចម្ងាយពីទំនប់ប្រហែលប៉ុន្មានដែរ?

**ឆៈ** បើយើងវាស់ពីទំនប់មក ខ្ញុំនៅឆ្ងាយពីទំនប់ប្រហែលជា២០០ ហ៊ើ! -- ប្រហែលជា ៧០០ ម៉ែត្រៗ កន្លែងត្រង់ដែលកន្លែងខ្ញុំធ្វើហ្នឹង។ ហើយគេអ្នកដទៃ គេនៅតាមកន្លែងគេដែលអង្គការឲ្យជីកហ្នឹងទាន។ អត់អាចរើបានទេ។ គេដាក់ហ្នឹងមួយប្រាំងបណ្តោយហ្នឹង ព្រោះវាជ្រៅ។

[១១:២២:២១]

**សៈ** បើសិនជាខ្ញុំច្រឡំសូមប្រាប់ខ្ញុំ។ លោកបានឆ្លើយមុនហ្នឹងថា ក្រុមរបស់លោកទាំង១០០នាក់ ដែលមកពីភូមិរបស់លោកហ្នឹង ត្រូវបែងចែកជាប្រាំក្រុមតូចៗ។ អ៊ីចឹងខ្ញុំសួរថាតើក្រុមតូចៗផ្សេងទៀតនោះធ្វើការនៅកន្លែងផ្សេងទៀត កន្លែងលើកទំនប់ផ្សេងទៀតហ្នឹង ឬក៏ទាំងប្រាំក្រុមតូចៗហ្នឹងនៅតែមួយកន្លែងជាមួយគ្នានឹងលោកទេ កន្លែងដែលលោកក្តាប់រួមហ្នឹង?

**ឆៈ** ន៎ លោកស្រី នៅជាមួយគ្នា ប៉ុន្តែគ្រាន់តែយើងចែកថា លោកនេះនៅត្រង់ណេះៗ វាមក

ជាមួយគ្នាហ្នឹងឯង អស់ត្រង់ហ្នឹងយើងទៅធ្វើខាងមុខទៀតទៅ។

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា សម្រាប់ក្រុមដែលមកពីភូមិផ្សេងនោះគេធ្វើការនៅលើផ្នែកផ្សេងទៀត គេជីកផ្នែកផ្សេងទៀត។ តើត្រឹមត្រូវដែរឬទេ និយាយដូច្នេះ?

**ឆ៖** បាទ អ៊ីចឹងហើយ គឺគេចែកអ៊ីចឹង ក្រុមគេ សង្កាត់គេ ស្រុកគេ តំបន់គេ គេនៅផ្សេងទៅ។ បើមកត្បូងហ្នឹងវាតំបន់៤២។ តំបន់៤២ហ្នឹង គឺតាំងពីចម្ការលើ តាំងពីអីទៅ។ ហើយបើគេ ៤៣ ទៅខាង ៦មករា វាអត់ចូលគ្នាទេ។ គេទៅខាង៤៣ គេទៅខាង៤៣ ហើយយើងខាង៤២ មកខាង៤២ ទៅ។

[១១:២៤:១៣]

**ស៖** បាទ នៅក្នុងលក្ខខណ្ឌនេះ ករណីនេះ នៅពេលដែលលោកនិយាយថាលោកបានផ្លាប់ប្តូរបទពិសោធន៍ជាមួយក្រុម -- ប្រធានក្រុមផ្សេងៗទៀតនោះ តើលោកយល់ស្របដែរឬទេ គឺថាលោកគ្រាន់តែផ្លាស់ប្តូរបទពិសោធន៍តែជាមួយមេក្រុមដែលមកពីភូមិជាមួយលោកទេ ឬក៏លោកបានផ្លាស់ប្តូរបទពិសោធន៍ជាមួយមេក្រុមមកពីភូមិផ្សេងទៀតផងដែរ?

**ឆ៖** យើងមើលគេទាន មើលគេ អាគេធ្វើយ៉ាងម៉េចលឿន អាគេធ្វើយ៉ាងម៉េចយឺត អាគេធ្វើយ៉ាងម៉េចសុខសប្បាយនឹងគ្នា យើងយកចំណុចល្អរបស់គេ អាណាអាក្រក់យើងកុំយក យើងយកតែចំណុចដែលគេធ្វើល្អ អាគេធ្វើអាក្រក់យើងកុំយក ហើយក៏យើងកុំរិះគន់គេ។

**ស៖** សំណួរខ្ញុំអម្បាញ់មិញនេះ គ្រាន់តែថាចង់នេះទេ តើលោកបានផ្លាប់និយាយគ្នាជាមួយមេក្រុមផ្សេងទៀតដែលមកពីភូមិផ្សេងទៀតដែរឬទេ ដើម្បីប្រៀបធៀបលក្ខខណ្ឌការងារពលកររបស់លោកជាមួយនឹងពលកររបស់ពួកគាត់?

**ឆ៖** នែ៎ ផ្លាប់និយាយ ខ្ញុំមិនផ្លាប់ទិតៀនការងារនៅក្រុមគេហ្នឹង ខ្ញុំមិនផ្លាប់ទៅនិយាយទេ ព្រោះដើរចោលក្រុមមិនកើតទេទាន។

[១១:២៥:៥៧]

**ស៖** អ៊ីចឹង ជាការត្រឹមត្រូវដែរឬទេក្នុងការនិយាយថា លោកមានស្វ័យភាពសមល្មមដែរទៅតាមភូមិ ទៅតាមតំបន់ ឬក៏តាមក្រុមរបស់លោកនៅក្នុងទំនប់ ១មករានេះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំមិនដឹងទេទាន ប៉ុន្តែខ្ញុំគ្រាន់តែថាមានទំនុកចិត្តខ្លួនឯងថា ដែលខំធ្វើនេះព្រោះចង់ធ្វើទំនុកតាមការណែនាំរបស់អង្គការតែប៉ុណ្ណឹងទេ។

**ស៖** លោកបាននិយាយកាលពីម្សិលមិញ ហើយថ្ងៃនេះផងដែរ អំពីភាពរាំងស្ងួតដែលទទួល --

ជួបប្រទះនៅតំបន់ហ្នឹងចន្លោះឆ្នាំ៧៧ ដល់ឆ្នាំ៧៨ -- ៧៦-៧៧។ អ៊ីចឹង តើលោកអាចប្រាប់នូវចន្លោះពេលជាក់លាក់បានទេ? ប្រហែលជាខែណាដែរ ពេលដែលជួបគ្រោះរាំងស្ងួតនេះ?

**ឆ៖** លោកស្រីកាលណោះ ឆ្នាំ៧៦។ បើយើងៗធ្វើបុណ្យដូចសព្វថ្ងៃនេះ គេថាខែភ្ជុំៗធំ។ ចាប់ពីខែភ្ជុំធំទៅរាំងរហូតៗ។ ក្នុងឆ្នាំ៧៦ហ្នឹង មនុស្សត្រូវពិសាបាយនៅឆ្នាំ៧៧ណ៎ាទាន។ យើងធ្វើស្រែឆ្នាំ៧៦យកមកពិសានៅ៧៧។ ឆ្នាំហ្នឹងឯងទានដែលវាពិបាកខ្លាំង។ វារាំងពេក រាំងរហូតដល់ងាប់ស្រូវស្កកហើយ។

**ស៖** លោកបានឆ្លើយថា ការជីកប្រឡាយហ្នឹងបានចាប់ផ្ដើមក្នុងខែតុលា ឬក៏ចុងឆ្នាំ១៩៧៦។ អ៊ីចឹង តើលោកដឹងដែរឬទេ បើគ្រោះរាំងស្ងួតដែលលោកបាននិយាយនេះគឺវាជាមូលហេតុនាំឱ្យកើតដល់ការជីកទំនប់ លើកទំនប់ហ្នឹងឡើង។ ដោយសាររាំងស្ងួតហ្នឹងហើយបានចេញជាគម្រោងជីកហ្នឹង។ តើអ៊ីចឹងឬក៏យ៉ាងណា?

[១១:២៨:៤៦]

**ឆ៖** ខ្ញុំមិនដឹងទេទាន ការងារនេះការងាររបស់អង្គការគេ ក៏ប៉ុន្តែគ្រាន់តែដឹងថា ខែ១០ ហ្នឹងមេឃុំគាត់អញ្ជើញភូមិទាំងអស់ទៅប្រជុំ ប្រជុំថាអង្គការត្រូវការជីកប្រឡាយហើយប្រាំងនេះ។ ហើយគឺជីកមកពីអន្លង់ចង្កៀង កាត់តាមភូមិព្រៃស្រង៉ែ ទៅតាមកំប៉ើយ។ គឺឆ្នាំទី១ បានដល់ត្រឹមកំប៉ើយទេទាន។ រួចបានទទួលប៉ុណ្ណឹង បានដំណឹងប៉ុណ្ណឹងទេទាន។ ហ្នឹងមិនទាន់ជីកទេ គ្រាន់តែអង្គការបានប្រាប់មក។ ហើយយើងទាំងអស់គ្នាក៏ទទួលត្រៀមខ្លួនចាំជីកប្រឡាយហ្នឹង ហើយត្រូវឆ្នាំហ្នឹងវារាំងស្ងួតផង វាងាប់ស្រូវផង មនុស្សវាអរនឹងបានប្រឡាយហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំជិតចូលទៅដល់ប្រធានបទថ្មីហើយ តែឥឡូវនេះសមស្របនឹងសម្រាកឥឡូវឬក៏យ៉ាងណាលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នក

ជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយ និងសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និង បង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំបន្តសួរលោកបន្តទៅទៀត។ កាលពីម្សិលមិញនៅពេលដែលលោកឆ្លើយតបទៅនឹងលោកចៅក្រម ឡាវ៉ែន ខ្ញុំដូចជាយល់ឃើញថាលោកពន្យល់ថាមានទំនប់ទី១ -- ខ្ញុំមិនដឹងថានៅក្រោមរបប លន់ នល់ ឬក៏មុនរបប លន់ នល់ នោះទេ ក៏ប៉ុន្តែមានទំនប់ទី១ ដែលមានប្រព័ន្ធស្រោចស្រពនោះរាក់ទេ។ តើខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ? លោកអាចពន្យល់បានទេថា តើទំនប់ហ្នឹងត្រូវបានធ្វើឡើងនៅពេលណាដែរ?

**លោក ឱ ហួ៖**

**ឆ៖** ទាន ទំនប់ហ្នឹងវាអត់បានប្រើអីទេ។ ទំនប់ហ្នឹងធ្វើមួយជំនាន់សង្គ្រាមប្រជាជាតិប្រជាធិបតេយ្យ។ ដែលខ្ញុំថាសង្គ្រាមប្រជាជាតិប្រជាធិតេយ្យ គឺសង្គ្រាមជាមួយ លន់ នល់។ ហើយទំនប់ហ្នឹង

វាអត់បានទេ អត់បើកប្រើទេ។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺទំនប់ ១មករានេះ គឺជាទំនប់ទី១នៅក្នុងតំបន់លោកហើយ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ទំនប់នេះជាទំនប់ទី១។ ជាទំនប់ដែលទី១ដែលខ្ញុំបាន ក្នុងមួយជីវិតនេះយើងឃើញទំនប់នេះឯងដែលយើងបានជាទីសង្ឃឹមដល់ក្នុងជីវិតរបស់យើង។

[១៣:៣៥:១២]

**ស៖** អ៊ីចឹងខ្ញុំសូមសំណួរមួយទៀត។ មុននឹងកើតទំនប់នេះមក តើលោកធ្វើយ៉ាងម៉េចដែរ ដើម្បីស្រោចស្រពដំណាំដាំដុះនោះ។ លោកធ្វើយ៉ាងម៉េចដែរ មុននឹងគេលើកទំនប់ហ្នឹងឡើងហ្នឹង?

**ឆ៖** ទំនប់ហ្នឹងពីដើម យើងអត់មានដែលធ្វើប្រដាប់បូមទឹកដូចសព្វថ្ងៃទេ សព្វថ្ងៃគេបច្ចេកទេសគេៗធ្វើបូមដាក់ស្រែ គេចង់ធ្វើស្រែប្រាំងគេអី បូមដាក់ស្រែ។ សព្វថ្ងៃគេ កន្លែងខ្លះនៅៗបារាយណ៍ គេបង្ហូរទឹកហ្នឹងទៅដល់ស្រែគេហ្នឹងណា ខែប្រាំងហ្នឹង។ ហើយស្រូវគេហ្នឹង ចុះមួយឆ្នាំធ្វើប្រាំងហ្នឹងពីរដងទាន។ ដំបូងគេព្រោះៗស្រូវប្រាំងហ្នឹងទៅ ដល់គេច្រូតមួយសា គេភ្ជួរព្រោះមួយសាទៀត។ ហើយសព្វថ្ងៃគេជិតច្រូតទៀតហើយ។

**ស៖** ខ្ញុំមិនដឹងថាសំណួរខ្ញុំអម្បាញ់មិញនេះច្បាស់លាស់ឬទេ ឥឡូវខ្ញុំសួរម្តងទៀត។ សំណួរអម្បាញ់មិញ ខ្ញុំចង់ដឹងថា មុនពេលដែលលើកទំនប់ហ្នឹងឡើងនោះ តើលោកធ្វើយ៉ាងណាដែរ ដើម្បីដាំដុះហើយដើម្បីឱ្យមានទឹកធ្វើដំណាំដាំដុះនោះនៅរដូវរាំងស្ងួតនោះ? តើលោកធ្វើយ៉ាងម៉េចដែរ ដើម្បីប្រកបរបរកសិកម្មនោះ?

**ឆ៖** អូ៎! គេនែ៎ លោកស្រីចង់សួរថាដែលមុនធ្វើទំនប់ ធ្វើប្រឡាយហ្នឹង បានទឹកឯណាយកទៅស្រោចស្រពស្រែ អ៊ីចឹងទាន? ការដែលមុនធ្វើប្រឡាយនោះ យើងពឹងទៅលើមេឃទេទាន បើភ្លៀងវាគ្រប់គ្រាន់នោះក៏គ្រប់គ្រាន់ទៅ បើមិនគ្រប់គ្រាន់ទេ វាស្អកទៅ។

[១៣:៣៧:២១]

**ស៖** កាលពីម្សិលមិញដែរ ខ្ញុំហាក់ដូចជាយល់ឃើញថានៅ -- លោកបានពន្យល់អំពីប្រវែងទំនប់នោះ លោកនិយាយថាប្រវែង១០គីឡូម៉ែត្រ ទំនប់ហ្នឹង។ តើខ្ញុំយល់ហ្នឹងត្រឹមត្រូវដែរឬទេ ឬក៏លោកនិយាយប្រាប់ថាម្សិលមិញប្រវែងទំនប់ហ្នឹងប្រវែងខុសពី ១០គីឡូម៉ែត្រហ្នឹងទេ?

**ឆ៖** ប្រវែងប្រហែលជា ១០គីឡូម៉ែត្រហ្នឹងគឺពីទំនប់១មករា ទៅទំនប់៦មករាទេទាន។ មិនមែន

ជាទំនប់ដែលស្រុកបារាយណ៍ទេ មិនមែនជាប្រឡាយស្រុកបារាយណ៍ទេ។ ទំនប់ហ្នឹង -- ខ្ញុំជម្រាបម្តងទៀតថា ទំនប់ហ្នឹង ទំនប់១មករានេះគឺចាប់ពីថ្នល់ជាតិលេខ៧១ ទៅទល់នឹង៦មករា។ អាហ្នឹងគេហៅថាទំនប់ ១មករា។ ឯ ៦មករានោះជាទំនប់មួយគេហៅថា ស្ពាន៦មករា តែវាជាមួយនឹងគ្នាហ្នឹង វាភ្ជាប់ជាមួយគ្នាទៅរហូតពី ១មករាទៅទាន។

**ស៖** អ្វីដែលខ្ញុំចាប់អារម្មណ៍ចង់ដឹងនោះគឺថា ប្រវែងទំនប់១មករា ពីព្រោះថានៅក្នុងសំណុំរឿងយើងមានឯកសារមួយ គឺឯកសារ IS18.86, ERN ជាភាសាបារាំងគឺ 00347726, ERN ជាភាសាខ្មែរ គឺ 00231627, ERN ជាភាសាអង់គ្លេសគឺ 00096744។ គឺជាឯកសារដែលនិយាយអំពីការជម្លៀសទៅកំពង់ធំ នៅថ្ងៃទី៣០ មករា ឆ្នាំ១៩៧៧ ដែលធ្វើដោយសហព្រះរាជអាជ្ញា។ នៅក្នុងឯកសារនេះបង្ហាញថាទំនប់ហ្នឹងមានប្រវែង៥៨គីឡូម៉ែត្រ។ តើលោកធ្លាប់ដឹងពីចម្ងាយទំនប់ដែលថាមានប្រវែង៥៨គីឡូម៉ែត្រហ្នឹងដែរឬទេ? តើទំនប់ ១មករានេះមានប្រវែង៥៨គីឡូម៉ែត្រ ឬមួយយ៉ាងណា?

[១៣:៤០:០៦]

**ឆ៖** បើប្រវែងប៉ុណ្ណឹង ទាល់តែទាំងប្រឡាយផងទាន រាប់ទាំងប្រឡាយដែលទៅដល់ស្រែ ដល់ហ្នឹង បានវាបាន បើថាទួលទំនប់ហ្នងវាតិចទេ ប្រឡាយតើដែលវាវែង។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថាចម្ងាយ១០គីឡូម៉ែត្រដែលលោកបានលើកឡើងនេះ គឺជាជញ្ជាំងទំនប់ទេដែលមានប្រវែង១០គីឡូម៉ែត្រហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** ជាជញ្ជាំងទំនប់ទាន ជាជញ្ជាំងទំនប់ដែលគេទប់ការពារឲ្យទឹកវានៅ។

**ស៖** តើលោកដឹង -- យ៉ាងម៉េចបានជាលោកដឹងថាទំនប់ហ្នឹងមានប្រវែង១០គីឡូម៉ែត្រនោះ?

**ឆ៖** រឿងប្រវែងប៉ុណ្ណឹង ខ្ញុំមិនបានវាស់ទេណាទាន ប៉ុន្តែបើលោកឲ្យខ្ញុំស្មានៗប៉ណ្ណឹងឯង។

**ស៖** លោកប៉ាន់ប៉ាន់ប្រមាណថាប្រហែល១០គីឡូម៉ែត្រហ្នឹងដោយឈរលើមូលដ្ឋានអ្វីដែរ?

**ឆ៖** ដោយឈរលើមូលដ្ឋាន ពីភូមិខ្ញុំ ពីថ្នល់ទៅទំនប់១មករា វា៤គីឡូម៉ែត្រ។ ហើយពីទំនប់១មករាទៅត្រឹមផ្លូវខ្វែក វា៤គីឡូម៉ែត្រទៀត។ ពីផ្លូវខ្វែកទៅដល់ដែល៦មករា ទៅដល់ដែលចប់ទំនប់១មករា វាប្រហែលជា៤គីឡូម៉ែត្រទៀតទេប៉ុណ្ណឹងទៀត បើខ្វះក៏ខ្វះបន្តិច បើលើសក៏លើសបន្តិចប៉ុណ្ណឹង។

[១៣:៤២:៤៥]

**ស៖** សូមអរគុណដែលបានឆ្លើយបញ្ជាក់។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីផ្នែកមួយចំនួននៃចម្លើយរបស់លោកនៅឆ្នាំ២០០៨ គឺឯកសារE3/5255 គឺនៅលេខERN ជាភាសាបារាំងគឺ 0026627,

ERNជាភាសាអង់គ្លេស គឺ 00250045, ជាភាសាខ្មែរគឺ 00239909។ មានកត់ត្រាដូចនេះក្នុងចម្លើយរបស់លោក៖ “ដើម្បីសង់ទំនប់នេះ គឺថ្នាក់កណ្ដាលដែលដាក់ផែនការមកថ្នាក់ក្រោមឱ្យធ្វើ រួចហើយរាយការណ៍ទៅថ្នាក់លើ” បាទសូមចប់ការដកស្រង់។ បាទ ខ្ញុំចង់ដឹងថាតើពេលដែលលោកនិយាយថាថ្នាក់កណ្ដាលហ្នឹងមានន័យថាយ៉ាងម៉េច? ហើយថ្នាក់ក្រោមហ្នឹងមានន័យយ៉ាងម៉េច? ហើយថ្នាក់លើហ្នឹងមានន័យយ៉ាងម៉េចដែរក្នុងក្របខ័ណ្ឌដែលលោកធ្វើការនៅទំនប់នោះ ពាក្យទាំងបីហ្នឹងសំដៅលើអ្វី?

**ឆ៖** ថ្នាក់ក្រោម ខ្ញុំធ្វើការគឺថ្នាក់ភូមិហ្នឹងឯងទាន ថ្នាក់ក្រោម។ ហើយថ្នាក់កណ្ដាលគឺចាប់ពីសង្កាត់ទៅដល់តំបន់ ហើយដល់ថ្នាក់លើនោះ គឺថ្នាក់លោកប្រធាន ថ្នាក់លោកប្រធានធំៗខាងលើរដ្ឋមន្ត្រីលើៗហ្នឹងទាន។ ព្រោះទំនប់នោះដែលធ្វើ មិនមែនអ្នកតូចតាចធ្វើទេ គឺអ្នកធំដឹកនាំធ្វើទាន។

**ស៖** តើលោកស្គាល់ឈ្មោះមេធំៗនៅថ្នាក់លើទេ?

**ឆ៖** ខ្ញុំមិនស្គាល់ទេទាន ថ្នាក់លើដែលមេធំៗនោះ ប៉ុន្តែដែលអ្នកបាននិយាយប្រាប់ខ្ញុំគឺអង្គការខាងលើហ្នឹង។

**ស៖** នៅពេលដែលលោកនិយាយអង្គការ ដែលនិយាយអំពីផែនការហ្នឹង គឺលោកចង់និយាយអំពីថ្នាក់កណ្ដាលដែលជាមេផ្ទាល់របស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** អង្គការថ្នាក់លើ អង្គការថ្នាក់កណ្ដាល ថ្នាក់ដែលត្រួតត្រាមកលើខ្ញុំហ្នឹង គេហៅអង្គការថ្នាក់កណ្ដាល មកត្រួតត្រាខ្ញុំ ហើយនិងថ្នាក់ក្រោមខ្ញុំ មានពួកខ្ញុំហ្នឹង ធ្វើតាមបញ្ជារបស់អង្គការទៅ។ កាលណាគាត់បានព័ត៌មានពីអង្គការថ្នាក់លើ គាត់មកបញ្ជាថ្នាក់ក្រោមមក។

[១៣:៤៦:៣៤]

**ស៖** អ៊ីចឹងនៅពេលដែលលោកនិយាយថា គឺថ្នាក់កណ្ដាលដែលដាក់ផែនការឱ្យធ្វើទៅថ្នាក់ក្រោមនោះគឺលោកចង់និយាយថា គឺ ប៊ិន ហើយនិង វុត ហ្នឹងហើយដែលជាអ្នកកំណត់ផែនការហ្នឹង ដាក់មកឱ្យលោកដែលជាអ្នកថ្នាក់ក្រោមធ្វើ លោកចង់និយាយអ៊ីចឹងឬក៏យ៉ាងម៉េច?

**ឆ៖** មិនមែនទេ ប៊ិន និង វុត ទទួលផែនការពីលើមកទៀត ពីស្រុក ពីតំបន់មកទៀត។ ព្រោះប៊ិន, វុត គាត់សង្កាត់មែន ប៉ុន្តែនៅក្រោមគេទេ។ នៅខាងលើគឺ ស្រុក ហើយនិងតំបន់នោះទៀតដែលជាមេរបស់គាត់។ ហើយ ប៊ិន និង វុត ហ្នឹង ជាមេរបស់ខ្ញុំឯណោះទេ បន្ទាប់ពីខាងថ្នាក់កណ្ដាលខាងលើនោះ។ ខ្ញុំមិនដឹងទេទាន សួរអ៊ីចឹង ខ្ញុំមិនសូវដឹងទេទាន ការងារហ្នឹង។

**ស៖** មិនមានបញ្ហាអ្វីទេ ខ្ញុំគ្រាន់តែសួរលោកអ្វីដែលលោកធ្លាប់ស្គាល់តែប៉ុណ្ណោះទេ។ ចំណុច

មួយទៀតទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹង កាលពីម្សិលមិញនេះ នៅពេលដែលលោកនិយាយពីម៉ោងធ្វើការងារនៅលើការដ្ឋាននោះ លោកបាននិយាយអំពីការចាប់ផ្តើមឡើងនៅម៉ោងបួនព្រឹកនៅក្នុងចម្លើយកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារដដែលហ្នឹង គឺ E3/5255, ទំព័រជាភាសាបារាំង គឺទំព័រដដែលគឺ 00227227, ERN ជាភាសាអង់គ្លេស គឺ 00250046, ជាភាសាខ្មែរគឺ 00239909។ លោកឆ្លើយដូច្នេះ៖ "គេចាប់ផ្តើមធ្វើការនៅម៉ោងប្រាំមួយកន្លះរហូតដល់ដប់មួយថ្ងៃត្រង់ រួចហើយបន្តពីម៉ោងពីររហូតដល់ម៉ោងប្រាំ។ ហើយពេលយប់នោះពីម៉ោងប្រាំពីរ ដល់ម៉ោងដប់។ ដើម្បីបញ្ចប់ផែនការលើកទំនប់ហ្នឹង គេត្រូវធ្វើការពីម៉ោងបួនជិតភ្លឺ រហូតដល់ម៉ោងដប់មួយថ្ងៃត្រង់ រួចបានបន្តពីម៉ោងពីររហូតដល់ម៉ោងប្រាំល្ងាច។ ហើយពេលយប់ពីម៉ោងប្រាំពីរដល់ម៉ោងដប់"។ សូមបញ្ចប់ការដកស្រង់។ បាទ ខ្ញុំ តាមខ្ញុំយល់នេះគឺថាមិនមែនពេញមួយរយៈពេល៦ខែ នៃការលើកទំនប់នោះទេ ដែលត្រូវចាប់ផ្តើមធ្វើពីម៉ោងបួនព្រឹកនេះ។ ក៏ប៉ុន្តែនៅពេលជិតចប់ហើយដែលត្រូវសម្រុកដើម្បីឲ្យលើកទំនប់ឲ្យចប់។ តើខ្ញុំយល់អ៊ីចេះត្រឹមត្រូវដែរឬទេ?

**ឆ៖** នែ៎ លោកស្រីយល់ហ្នឹងត្រឹមត្រូវណាស់ទាន ការងារប្រញាប់ពេក។

[១៣:៤៩:៤០]

**ស៖** លោកបានឆ្លើយកាលពីម្សិលមិញ ប្រហែលជាមុនម៉ោង១៥:១៦នាទី លោកឆ្លើយថាលោកទទួលសម្រាករាល់ពេល១០ថ្ងៃម្តង។ សំណួររបស់ខ្ញុំគឺថា ព្រឹកមិញលោកបាននិយាយជាមួយសហភាតារបស់ខ្ញុំគឺថា ម្តងម្កាល គឺត្រូវការផ្លាស់វេនគ្នាក្នុងសមាជិកក្រុមរបស់លោកទាំង១០០នាក់ ធ្វើការនៅការដ្ឋាននោះ។ តើពេលនោះ រយៈពេល១០ថ្ងៃសម្រាកម្តងនេះ គឺក្នុងរយៈពេល៦ខែហ្នឹង ដែលត្រូវតែ១០ថ្ងៃសម្រាកម្តង ឬក៏១០ថ្ងៃម្តងហ្នឹងក្រៅពីរយៈពេល៦ខែហ្នឹងទេ?

**ឆ៖** ការងារធ្វើការ អង្គការគេកំណត់អ៊ីចឹង ធ្វើការ១០ថ្ងៃឈប់មួយថ្ងៃ។ ឈប់ពេញមួយថ្ងៃ។ ពីភូមិក៏គេឈប់ធ្វើការដែរ ឈប់ទាំងអស់គ្នា។

**ស៖** ខ្ញុំសូមបំភ្លឺសំណួរខ្ញុំអំមិញ។ តាមពិតអម្បាញ់មិញខ្ញុំចង់សួរថា ក្នុងរយៈពេលសម្រាកនេះៗ គឺត្រូវការផ្លាស់វេនគ្នា ក្នុងសមាជិកក្រុមហ្នឹងត្រូវដូរគ្នាហ្នឹង លោកថាពេលខ្លះដូរវេនគ្នាក្នុងរយៈពេល៦ខែ ឬក៏ ខ្ញុំចង់សួរថាតើក្រៅពីរយៈពេល៦ខែហ្នឹងទេឬដែលលោកនិយាយអំពីរឿងការដូរសមាជិកក្រុមផ្លាស់គ្នាម្នាក់ម្តងអ៊ីចឹង?

**ឆ៖** ការដូរហ្នឹងវាដូរក្នុងពេលដែល ក្នុងពេល៦ខែហ្នឹងក៏ដូរដែរទាន។ ប៉ុន្តែដូរលុះត្រាតែកម្លាំង

ហ្នឹងវាខ្សោយពេក គេដូរសុំទៅធ្វើការឯក្រោយ។ មិនមែនដូរឈប់ធ្វើការទេណាទាន។ ឈប់ធ្វើពីខាងប្រឡាយទៅធ្វើការឯក្រោយវិញទេទាន។

**សៈ** ខ្ញុំសួរម្តងទៀត តើការផ្លាស់ប្តូរវេនគ្នាហ្នឹងសួរហ្នឹងនៅពេលអាថ្ងៃទី១០ ត្រូវសម្រាកហ្នឹងបានគេដូរសមាជិកក្រុម ឬក៏គេដូរក្រៅពីថ្ងៃសម្រាក?

**ឆៈ** វាដូរហ្នឹងថ្ងៃមិនសម្រាកក៏ដូរបានដែរ តែឲ្យតែមានថ្នូរមក។ ឲ្យពីភូមិហ្នឹងមានថ្នូរមកដូរ។ បើថាពីភូមិវាគ្មានដូរទេ នៅហ្នឹងកន្លែងហ្នឹងទៅ។ អត់អាចទៅសម្រាកបានទេ វាបាត់មនុស្ស។

[១៣:៥២:៤៣]

**សៈ** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ ឥឡូវនេះ ខ្ញុំសូមចូលទៅចំណុចមួយទៀត ហើយនិងខ្ញុំចាប់អារម្មណ៍ទៅលើរយៈកាលដែលលោកធ្វើជាមេភូមិរបស់លោក លោកមិនបានធ្វើការនៅការដ្ឋានទេពេលនោះ ហើយលោកបាននិយាយថា និយាយអំពីស្ថានភាពទាក់ទងនឹងជនជាតិចាមនៅក្នុងភូមិរបស់លោក។ អ៊ីចឹងខ្ញុំសូមសួរលើចំណុចមួយដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត។ ជាបឋម ខ្ញុំសូមអានអ្វីដែលត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក។

**កញ្ញា អង់តា ហ្គីសសេៈ**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញ ហើយចាក់ខ្សែអាត់ឲ្យគាត់ស្តាប់ ពីព្រោះថាច្បាស់លាស់ជាងលោកប្រធាន។ បន្ទាប់មកខ្ញុំចោទសំណួរទៅគាត់។ បើអ៊ីចឹងខ្ញុំសូមសួរលោកប្រធាន តើលោកប្រធានអាចអនុញ្ញាតឲ្យខ្ញុំចាក់ខ្សែអាត់ហ្នឹងដែរឬទេ? គឺជាខ្សែអាត់លេខ D166/35R នៅចន្លោះម៉ោង ០១:៤៤:១១ ហើយនិងម៉ោង ០១:៤៥:៥១។ ខ្ញុំបានផ្ញើ អ៊ីម៉ែលមួយជូនជាដំណឹងហើយថាយើងខ្ញុំចង់ប្រើខ្សែអាត់នេះលោកប្រធាន។

[១៣:៥៤:៣០]

**ប្រធានអង្គជំនុំៈ**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**កញ្ញា អង់តា ហ្គីសសេៈ**

សម្រាប់ផ្នែកបច្ចេកទេស ខ្ញុំសូមអានចម្លើយនេះជាលាយលក្ខណ៍អក្សរសិន ហើយបន្ទាប់មកទៀតខ្ញុំនឹងជម្រាបជូនពេលដែលខ្ញុំចង់ចាក់ខ្សែអាត់នេះ។ នៅក្នុងចម្លើយរបស់លោកនេះ គឺឯកសារ E3/5255, ERN ជាភាសាបារាំងគឺ 00277229, ជាភាសាអង់គ្លេសគឺ 00250047, ជាភាសាខ្មែរគឺ

00239911។ គេសួរលោកដូចយ៉ាងអ៊ីចេះ៖ “តើលោកដឹងអំពីគោលនយោបាយ សម្លាប់ជនជាតិចាមដែរឬទេ? លុបបំបាត់ជនជាតិចាមដែរឬទេ?” ហើយកាលនោះចម្លើយរបស់លោក លោកឆ្លើយថា៖ “ខ្ញុំមិនដឹងដែរ ខ្ញុំគ្រាន់តែដឹងថាគេចង់ឲ្យមានតែជនជាតិខ្មែរមួយប៉ុណ្ណោះ”។ បាទសុំបញ្ចប់ការដកស្រង់។ តាមការពិតលោកសាក្សី លោកឆ្លើយច្បាស់លាស់ជាងហ្នឹង។ អ៊ីចឹង ឥឡូវខ្ញុំសុំអនុញ្ញាតចាក់ខ្សែអាត់នេះលោកប្រធាន បន្ទាប់មក ខ្ញុំនឹងសុំឲ្យលោកសាក្សីគាត់បំភ្លឺ។

**ប្រធានអង្គជំនុំ៖**

សុំផ្នែកបច្ចេកទេសចាក់ខ្សែអាត់តាមសំណើសុំរបស់លោកស្រីមេធាវី!

[១៣:៥៦:៥៣]

*(ការចាក់បង្ហាញឯកសារជាសំឡេង)*

“ស៖ បាទ តើលោកបានដឹងទេថា មាននយោបាយ មាគ៌ានយោបាយរបស់គេដើម្បីលុបបំបាត់ចាមហ្នឹង លែងឲ្យមានជាក្រុមចាម ជាជនជាតិចាមហ្នឹង? ឆ៖ ខ្ញុំមិនសូវដឹងដែរ ប៉ុន្តែគ្រាន់តែថាគេឲ្យធ្វើតែមួយ គឺជាប្រជាជនតែមួយ គ្មានចាម គ្មានខ្មែរ។ ស៖ តើលោកធ្លាប់បានសង្កេតឃើញ ឬក៏គិតថាពួកចាមហ្នឹងត្រូវបានគេចុចយក ទោះបីជាអ្នកហ្នឹងក្នុងភូមិខ្មែរ ក្នុងកងចល័ត គឺគេចុចយកចាមៗដើម្បីធ្វើបាប ឬដើម្បីធ្វើទុក្ខបុកម្នេញ ឬក៏ចាប់អីទេ? ឆ៖ ខ្ញុំ បើក្នុងភូមិដទៃទៀត ខ្ញុំមិនដឹងទេ ប៉ុន្តែបើក្នុងភូមិខ្ញុំវាគ្មានទេ។”

*(ចប់ការបង្ហាញឯកសារសំឡេង)*

[១៣:៥៨:៤២]

**កញ្ញា អង់តា ហ្គីសសេ៖**

បើខ្ញុំសួរទៅខាងអ្នកបកប្រែ ខ្ញុំមិនដឹងថាហេតុអីក៏អត់មានអ្នកបកប្រែជាភាសាបារាំងនូវអ្វីដែលនិយាយអម្បាញ់មិញនេះជាភាសាខ្មែរ។ សុំឲ្យបកប្រែទៅជាភាសាបារាំងដោយផ្ទាល់។ បើអ៊ីចឹងទេ ខ្ញុំសុំអនុញ្ញាតឲ្យចាក់ខ្សែអាត់នេះមួយសារទៀត ដើម្បីឲ្យបកប្រែ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំសុំអនុញ្ញាតធ្វើការសង្កេត ប្រសិនបើខ្ញុំយល់គឺថា មេធាវីការពារក្ដីជឿជាក់ថាការបកប្រែដែលយើងបានស្ដាប់ ហើយដែលមាននៅក្នុងឯកសារនេះគឺមិនត្រឹមត្រូវ ឬក៏មិនពេញលេញ។ ហើយខ្ញុំយល់ថា ពួកគាត់មានសិទ្ធិជំទាស់ទៅលើបញ្ហានេះ ប៉ុន្តែ ខ្ញុំគិតថាដើម្បីសន្សំពេលវេលាគឺថា ពួក

គេអាចធ្វើការស្នើទៅអង្គភាពគ្រប់គ្រងតុលាការដើម្បីឲ្យមានការបកប្រែជាជាងការស្នើដែលអ្នកបកប្រែនៅក្នុងសាលសវនាការឲ្យបកប្រែនៅក្នុងពេលនេះ ហើយផ្តល់ការបកប្រែដោយផ្ទាល់ ដែលថា អាចថាការបកប្រែហ្នឹងវាដូច ឬក៏មិនដូចគ្នាទៅទាំងបីភាសា។ ដូច្នេះ ខ្ញុំគិតថា ក្នុងពេលអនាគតយើងគួរតែលើកឡើងបញ្ហានៃការបកប្រែមិនត្រឹមត្រូវ ឬក៏មិនពេញលេញ ដើម្បីឲ្យមានប្រយោជន៍ដល់ភាគីទាំងអស់ គឺថាពួកគេគួរតែលើកសំណើទៅខាងផ្នែកគ្រប់គ្រងតុលាការ ជាជាងយើងមកលើកនៅក្នុងពេលសវនាការបែបនេះ។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេះ**

អត់បញ្ហាអីទេ។ ខ្ញុំអាចធ្វើសំណើទៅខាង ស៊ី.អឹម.អេស ក៏ប៉ុន្តែដោយសាររយៈពេលខ្សែអាត់យើងនេះវាខ្លីហ្នឹង អ៊ីចឹងខ្ញុំគិតថាដូចជាមិនមានបញ្ហាអ្វីទេ ចំពោះអ្នកបកប្រែផ្ទាល់មាត់។ បើសិនជាមានបញ្ហាគុណភាពសំឡេងនោះ អ៊ីចឹងយ៉ាងហោចណាស់ក៏ខ្មែរដែលនៅទីនេះ អាចស្តាប់ខ្សែអាត់នេះបានដែរ ហើយក្រោយមក ខ្ញុំអាចសុំទៅ ស៊ី.អឹម.អេស ឲ្យជួយបកប្រែ។

[១៤:០១:00]

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**សះ** ខ្ញុំសួរទៅសាក្សីដើម្បីឲ្យគាត់ជួយបញ្ជាក់។ អ្វីដែលដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតដែលបានសួរសំណួរចម្លើយលោក--

**លោក នីកូឡាស គូមជែន៖**

អ្វីដែលគាត់បាននិយាយ គឺជាការនាំមុខខ្លាំងចំពោះសាក្សី។ ដូច្នេះ ខ្ញុំនឹងស្នើសុំឲ្យមានការបញ្ជាក់ឡើងវិញ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំដូចមិនយល់ការអន្តរាគមន៍របស់សហព្រះរាជអាជ្ញាទេ ព្រោះថាឆន្ទៈរបស់យើងហ្នឹង ហើយចង់ឲ្យចាក់អម្បាញ់មិញនេះ ចាក់អ្វីដែលសាក្សីគាត់បាននិយាយពីមុនមក កុំឲ្យគេថាខ្ញុំនឹងសួរនាំមុខគាត់។ ខ្ញុំមើលទៅឃើញថា ការជំនុំជម្រះ មើលទៅដូចជាពិបាកមែនទែន។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**សះ** លោកសាក្សីលោកបានស្តាប់នូវអ្វីដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតហើយៗ តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា លោកបានឆ្លើយថាលោកមិនដឹងគោលនយោបាយទាក់ទងនឹង

ជនជាតិចាមនេះយ៉ាងណានោះទេ ក៏ប៉ុន្តែគ្រាន់តែដឹងថាឲ្យមានប្រជាជនតែមួយគត់ មិនឲ្យមានតែចាម ឬក៏ខ្មែរលាយឡំគ្នាទេ ឲ្យមានប្រជាជនតែមួយគត់។ តើលោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១៤:០២:២៣]

**លោក ឱ ហួរ៖**

**ឆ៖** កាលដែលស្តាប់លោកអង្គការថ្នាក់កណ្តាលគាត់បាននិយាយមក គាត់ថាក្នុងប្រទេសកម្ពុជាយើងមានតែប្រជាជនតែមួយទេគឺខ្មែរតែម្តង។ គ្មានអ្នកថ្មី គ្មានអ្នកចាស់ គ្មានចាម គ្មានជ្វាអីទេ គឺខ្មែរទាំងអស់។

**ស៖** លោកបានឆ្លើយកាលពីម្សិលមិញ ហើយថ្ងៃនេះលោកបានបញ្ជាក់ផងដែរ យើងបានឮនៅក្នុងខ្សែអាត់ហើយ គឺថាលោកមិនដឹងថានៅក្នុងភូមិផ្សេងទៀតនោះ មានរឿងអ្វីកើតឡើងនោះទេ។ ក៏ប៉ុន្តែនៅក្នុងភូមិយើងនោះ -- ភូមិលោកនោះ គឺថាមិនមានការធ្វើទុក្ខបុកម្នេញ ឬក៏ការធ្វើបាបទៅលើជនជាតិចាមនោះទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយទាន អត់មានធ្វើបាបគេទេ។

**ស៖** លោកបានឆ្លើយ ខ្ញុំសូមឲ្យលោកបំភ្លឺទាក់ទងនឹងចាមនេះដដែល ម្សិលមិញនៅពេលដែលគេសួរសំណួរទៅលោក ពេលដែលសហព្រះរាជអាជ្ញាសួរលោកកាលពីម្សិលមិញនេះ លោកឆ្លើយថាចាមនៅក្នុងភូមិលោកនោះ មានលទ្ធភាពសម្លាប់សត្វដែលខ្លួនចិញ្ចឹមបាន។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើគេអាច -- ចាមទាំងអស់នេះអាចសម្លាប់សត្វក្រៅពីសត្វជ្រូកបាន ដើម្បីប្រារព្ធពិធីជំនឿសាសនារបស់គេ ឬក៏យ៉ាងម៉េច?

[១៤:០៤:១៦]

**ឆ៖** អត់មែនទេទាន ព្រោះចាមដែលមកនៅភូមិខ្ញុំហ្នឹង គាត់តែងនិយាយថា ខ្ញុំបើមិនបានសំឡេះខ្លួនឯង ពួកខ្ញុំគេមិនឲ្យស៊ីទេ។ កាលនោះចាមដែលចំណាស់ៗខ្ញុំសព្វថ្ងៃនេះណ៎ា គាត់ថា "ខ្ញុំបើគេមិនឲ្យសម្លាប់ ខ្ញុំមិនបានស៊ីទេ មិនបានពិសា បានស៊ីទេ"។ ខ្ញុំក៏ប្រាប់មេក្រុមទាំងអស់ថា កុំធ្វើបាបគាត់ឲ្យសម្លាប់ គាត់ចាស់ហើយ ខ្លាចបាប។ គាត់និយាយម្តងទៀត គាត់ថាអត់បាបទេ។ បានបុណ្យទេ។ ក៏ដល់គាត់អង្វរ គាត់ខ្លាចវាមិនស៊ីថ្ងៃហ្នឹង គេថាសម្រាក១០ថ្ងៃសម្រាកម្តង តែវាត្រូវធ្វើគោមួយចែកគ្នាស៊ីមួយភូមិហ្នឹង ក៏ឲ្យសម្លាប់ទៅ។ គាត់យកចៅគាត់ពីរនាក់ ចៅហ្នឹងសព្វថ្ងៃគេទៅរៀននៅឯណាទេ ខ្ញុំជួបម្តងដែរ។ ប៉ុន្តែចៅហ្នឹងអ្នកទះដៃសើច ហើយតាហ្នឹងអ្នកអារ-កគោ។ អើវារបស់គាត់ ខ្ញុំវាមិនដឹងទេ

មើលតែចម្ងាយទៅ។ អាថៅទះដៃសើចទៅ តានោះក៏ធម៍នោះ មិនធម៍អីគាត់ទេណ៎ា ចេះតែសូត្រទៅ។ គាត់ថាដល់ធ្វើរួចទៅគាត់ថា "ប៉ុណ្ណេះខ្ញុំបានស៊ីហើយប៉ុណ្ណេះ ខ្ញុំបានស៊ី"។ គាត់ពិសាមែន ហ្នឹងធ្វើគោ ប៉ុនបើជ្រូកគាត់មិនពិសាទេ។ ប៉ុនបើយើងធ្វើជ្រូក គាត់មិនពិសា ប្រហុកឲ្យគាត់ពិសាទៅ ប្រហុកយើងមានតើ។

**ស៖** បាទទាក់ទងទៅនឹងសត្វដដែលនេះ លោកបានឆ្លើយថា យើងអាចសម្លាប់សត្វរាល់១០ថ្ងៃម្ដង។ តើធ្វើជាញឹកញាប់ទេនៅក្នុងភូមិលោកហ្នឹង?

**ឆ៖** មិនញឹកញាប់ទេទាន ជួនកាលមួយឆ្នាំបានម្ដងទេទាន។ វាមិនបាន១០ថ្ងៃម្ដងទេ វាមួយឆ្នាំម្ដង។ បើជ្រូកអីវាបានញឹក បានបីខែអីម្ដងអ៊ីចឹងទៅ។ ប៉ុន្តែជ្រូកមួយស៊ីមួយភូមិទាន មិនស៊ីតែឯងណា។ មិនដូចយើងពិសាសព្វថ្ងៃទេទាន វាបានគ្រាន់តែបានសាច់ជ្រូកហ្នឹងឯង បើសាច់គោវាគ្រាន់តែបានថាសាច់គោហ្នឹងឯងវា អើវាបានបន្តិចៗម្នាក់ដែរទេ។

[១៤:០៧:៣៤]

**ស៖** លោកក៏បាននិយាយផងដែរពីលទ្ធភាពរកត្រី។ អ៊ីចឹងសំណួរខ្ញុំសួរថាតើមានក្រុមពិសេសមួយដែលទទួលបន្ទុករកត្រីដែរឬទេ ឬក៏គ្រួសារមួយៗហ្នឹងរកត្រីដោយខ្លួនឯង?

**ឆ៖** ដំណើរហ្នឹងអ៊ីចេះទេទាន យើងធ្វើការចេញពីផ្ទះទៅម៉ោងភ្លឺឡើង វាគ្មានម៉ោងគ្មានអីទេ តែភ្លឺឡើងទៅពីងងឹតបន្តិចទៅៗធ្វើការ ដល់ធ្វើការរួច ដល់ពេលបាយមកស៊ីផ្ទះហ្នឹង ក៏គេចុះងូតទឹកតាមប្រឡាយទៅ។ ហើយពួកគេហ្នឹង គេពូកែណាស់ទាន ពូកែចាប់ត្រីណាស់។ ចាប់ត្រីក្នុងទឹក អត់មានរបស់របរទេ គេស្ទាបថ្មទៅគេចាប់ត្រីបានមួយត្រណោតៗទៅ។ ហើយគេមក គេអាំងទៅ គេចែកគ្នាស៊ីទៅ មួយក្រុមគេដែលមួយតុគេហ្នឹង គេចែកគ្នាស៊ី អ្នកណាបានអីក៏ស៊ីហ្នឹងទៅ។ ហើយសម្លរោងបាយហ្នឹងក៏វាគេដាក់មកឲ្យថែមទៀតទៅ។ បើស្ដាប់ លោកស្ដាប់ខ្ញុំនិយាយហ្នឹង ថាដូចជាសម្បូរពោរពាសណាស់។ មិនជាសម្បូរទេទាន។ ហើយចំពោះភូមិដែលទៅរកត្រីនោះចាត់គ្នារកមែនទាន។ វាមានទៅទន្លេសាប ទៅតាមស្ទឹង ប៉ុនបានក្រៃល ព្រោះកន្លែងខ្ញុំហ្នឹងវាសម្បូរៗហ្នឹងគេធ្វើស្ពានរួចៗ ត្រីវាមកកកនៅស្ពានហ្នឹងឯង ហើយសុំល្អបដែលថែរក្សាស្ពានហ្នឹងអូស តែមួយមុងទៅបានមួយកញ្ជេជាង ហើយយកត្រីទាំងហ្នឹងមកៗហូបទៅ។

**ស៖** ចំណុចមួយទៀតទាក់ទងទៅនឹងពេលដែលលោកធ្វើការនៅក្នុងភូមិលោកនោះ លោកបាននិយាយថាលោកបាន -- ខ្ញុំដកស្រង់ចម្លើយរបស់លោក គឺឯកសារ E3/5255, ERN ជាភាសាបារាំងគឺ

00277229, ជាភាសាអង់គ្លេសគឺ 00250047, ជាភាសាខ្មែរគឺ 00229911 លោកបាននិយាយកាលពីម្សិលមិញនេះ ខ្ញុំឮដូចជាលោកនិយាយអ៊ីចឹង។ អង្កាល់នោះ សហព្រះរាជអាជ្ញាសួរលោកនិយាយថា “ពីឆ្នាំ១៩៧៥ ដល់ ៧៧ គេមិនអនុញ្ញាតឲ្យរៀបការ ក៏ប៉ុន្តែអាចចាប់ពី៧៧ទៅហ្នឹងគេអនុញ្ញាតឲ្យរៀបការបាន” សូមបញ្ចប់ការដកស្រង់។ បើតាមលោកឆ្លើយកាលពីម្សិលមិញ លោកឆ្លើយទៅសហព្រះរាជអាជ្ញានេះ នាងខ្ញុំដូចជាយល់ឃើញថា លោកនិយាយថាមិនមានការអនុញ្ញាតឲ្យរៀបការទេ ពីព្រោះថាកាលណោះនៅសម័យសង្គ្រាម។ អ៊ីចឹង ខ្ញុំសួរលោកបញ្ជាក់ឡើងវិញថា កាលបរិច្ឆេទហ្នឹងត្រឹមត្រូវដែរឬទេដែលលោកឲ្យនេះ គឺថាគេអនុញ្ញាតឲ្យរៀបការពី៧៥ ដល់ ៧៧ ឬក៏ក្រោយពី៧៧ហើយ ឬក៏ហាមឃាត់នោះមុនឆ្នាំ៧៥ទេ?

[១៤:១១:២៤]

**ឆ៖** អ៊ីចេះទាន ការដែលនៅក្នុងសង្គ្រាម យុវជន យុវនារីមិនរៀបការទេ។ ហើយបើរៀបការក៏យើងរៀបការឲ្យពួកពិការដែលគ្នាកំបុតដៃកំបុតជើង ខំតស៊ូដើម្បីការពារជាតិនោះ ហ្នឹងគេការមែន។ ប៉ុន្តែចំពោះអ្នកដែលពិការទេ ឯចំពោះអ្នកដៃជាស្មារឹងនោះទុកធ្វើទ័ពសិន ហ្នឹងមុនឆ្នាំ១៩៧៥ ទាន។ ដល់ឆ្នាំ១៩៧៥ អត់ទាន់មានការទេ ដល់ទៅឆ្នាំ១៩៧៧ បានការ។

**ស៖** អ៊ីចឹងចន្លោះឆ្នាំ១៩៧៥ ដល់ ៧៧ នេះ លោកមិនបានរៀបចំពិធីការណាមួយទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** មិនបានរៀបចំទេទាន។ បន្ទាប់មកទៀត លោកបានឆ្លើយថា លោកបានរៀបចំពិធីការជូនកាលនោះសម្រាប់ ៣០ ទៅ ៤០គូ ឯណោះ។ អ៊ីចឹងសំណួរខ្ញុំចន្លោះខែកញ្ញា ឆ្នាំ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ នៅពេលដែលលោកលែងជាមេភូមិហើយហ្នឹង។ តើលោកបានរៀបចំពិធីរៀបការហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** នៅឆ្នាំ១៩៧៧ ហ្នឹងការបីដង ពីខែ៧ ឆ្នាំ១៩៧៧មក ការបីដង។ មួយភូមិៗចង់អស់ដែរការ។

**ស៖** សូមអភ័យទោស ខ្ញុំស្តាប់ចម្លើយចុងក្រោយមិនឮ លោកនិយាយថា ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៧ហ្នឹងគឺមានការតែបីគូទេ លោកនិយាយ-- តែបីដងទេ (សូមទោស) ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ឆ្នាំ១៩៧៧ដល់ខ្ញុំឈប់ វាដល់៧៨ហ្នឹង ការបានតែបីដងទេទាន។ ការ -- ប៉ុន្តែការបីដងម្តង៣០គូ ម្តង៤០គូទៅណ៎ាទាន។ ម្តងៗការច្រើន។

[១៤:១៤:៤៥]

**ស៖** ហើយចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៨ រហូតដល់ពេលវៀតណាមចូលនោះ តើលោកចាំដែរឬទេថា មានការរៀបការប៉ុន្មានដងដែរ បើសិនជាមាននោះ?

**ឆ៖** ខ្ញុំដល់ដំណាក់ហ្នឹង ខ្ញុំលែងដឹងហើយទាន ព្រោះខ្ញុំទៅជាប្រជាជនសាមញ្ញហើយ គេមិនប្រាប់ទេ ការងារទាល់តែគេអ្នកមុខអ្នកការ មេភូមិ មេអី បានគេហៅទៅ។

**ស៖** បើសិនជាខ្ញុំមិនច្រឡំទេ គឺលោកនៅក្នុងភូមិដដែល គឺភូមិដែលអង្គាល់លោកធ្វើជាប្រធានភូមិនោះ តើអ៊ីចឹងមែនទេ លោកនៅតែរស់នៅក្នុងភូមិហ្នឹងដដែល?

**ឆ៖** បាទ ខ្ញុំរស់នៅដដែល ប៉ុនដែលការ មិនៗមែនការនឹងភូមិខ្ញុំទេណាទាន ដែលការនៅភូមិគេដទៃទេ យើងបណ្ដើរគ្នាទៅបានៗច្រើន ភូមិយើងទៅ បើថាប្រាំគូភូមិយើង បណ្ដើរគ្នាទាំងប្រាំគូទៅការទៅ ហើយភូមិគេប៉ុន្មានគូ គេមកទៅ បានវាច្រើននោះ វាអ៊ីចឹងទេទាន។ ការរួមគ្នា--

**ស៖** សូមទោសលោកៗសាក្សី ប្រហែលជាលោកមិនយល់សំណួរខ្ញុំ។ ខ្ញុំសួរថា តើសព្វថ្ងៃហ្នឹងតើលោកនៅតែរស់នៅភូមិដដែលទេ ខ្ញុំចង់សំដៅដល់មកទល់នឹងសព្វថ្ងៃនេះ? ខ្ញុំអត់និយាយពីការរៀបការទៀតទេ ខ្ញុំចង់ដឹងថាសព្វថ្ងៃហ្នឹង លោកនៅភូមិហ្នឹងដដែល ឬក៏យ៉ាងម៉េច?

**ឆ៖** សព្វថ្ងៃ ខ្ញុំមកនៅខាងភូមិប្រពន្ធខ្ញុំ ខាងភូមិទួលសាលា ឃុំចុងដូង ស្រុកបារាយណ៍។ ការដែលខ្ញុំធ្វើប្រធានភូមិ នៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្ក ស្រុកបារាយណ៍។ នៅឆ្នាំ១៩៧៥ ខ្ញុំមកនៅឯព្រៃស្រង៉ែឯណោះទេទាន អ៎! មកនៅឯទួលសាលាអីណោះទេ ៨៥។

**ស៖** តើលោកមានបានឃើញអ្នកដែលស្ថិតនៅក្នុងក្រុមកម្មករ១០០នាក់ ដែលបានធ្វើការនៅការដ្ឋានទំនប់១មករា ហ្នឹងឡើងវិញទេ តាំងពី៧៩មកនោះ លោកធ្លាប់ជួបអ្នកណាខ្លះទេ ក្នុងចំណោមអ្នកទាំង១០០នាក់ហ្នឹង ហើយអ្នកណាខ្លះនៅរស់?

[១៤:១៧:៣៨]

**ឆ៖** នៅគរគោកទាន។ នៅភ្នំពេញហ្នឹងក៏មាននៅដែរ ខេត្តសៀមរាប នៅភ្នំពេញតាមទៅ គេតាម គេទៅនៅកន្លែងគេធ្លាប់រស់នៅ ព្រោះកាលដាច់ ប៉ុល ពត មក គេក៏ត្រឡប់មកនៅតាមកន្លែងដែលគេស្ម័គ្រចិត្តនៅ។

**ស៖** សំណួរចុងក្រោយ។ តើលោកនៅចាំឈ្មោះកម្មករដែលនៅរស់ទេ? លោកអាចផ្ដល់ឈ្មោះអ្នកទាំងអស់នោះបានទេ?

**ឆ៖** ន៎ែ គាត់នៅទាន នៅទេនៅនឹងភ្នំពេញហ្នឹងឯង ដូចជាបងរឹង ដូចជាបងអ៊ិតបងអី គាត់នៅ

ភ្នំពេញតើ ហើយនិងសមមិត្ត បងៗសាយ, លោក ស៊ុន អស់ភ្លេចឈ្មោះខ្លះទាន ប៉ុន្តែចាំមុខ ហើយខ្ញុំជួបតែញយទេ មកលេងនឹងគេដែរ ជួនកាលគេទៅលេងនឹងខ្ញុំនឹងដែរ។

**ស៖** សូមអរគុណលោកសាក្សីដែលបានឆ្លើយបំភ្លឺ។

[១៤:១៩:១៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខាងមេធាវីការពារក្តីលោក ខៀវ សំផន អស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងពីរសែបសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសវនាការជាបន្តនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-909 តាមប្រព័ន្ធសោតទស្សន៍ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណលោក ឱ ហូ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរការពិតក្នុងរឿងក្តីនេះ។ សក្ខីកម្មរបស់លោកដល់ពេលនេះបានដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកនៅអ.វ.ត.កនេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ សូមលោកមានសុខភាពល្អ សំណាងល្អ ហើយនិងវិលត្រឡប់ទៅលំនៅដ្ឋានប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពការពារក្តី និងអ្នកជំនាញជូនលោក ឱ ហូ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២០ នាទី ដល់ម៉ោង ១៤:៤១ នាទី)*

[១៤:៤១:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ ហើយតទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-909។

*(សាក្សីចូលក្នុងបន្ទប់ផ្តល់សក្ខីកម្ម)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តី លោកសាក្សី។ តើលោកបានត្រៀមខ្លួនរួចហើយឬនៅ?

**លោក ប៉ិច សុខា៖**

**ឆ៖** ជម្រាបសួរលោកប្រធាន ខ្ញុំកំពុងតែអង្គុយរង់ចាំ បាទ។

**ស៖** អូ បាទ អរគុណ។ ហើយលោកសាក្សី តើលោកឈ្មោះអ្វី?

**ឆ៖** ខ្ញុំបាទ ឈ្មោះ ប៉ិច សុខា។

**ស៖** អរគុណ លោក ប៉ិច សុខា តើលោកកើតនៅថ្ងៃ ខែ ឆ្នាំណា?

**ឆ៖** កើតនៅថ្ងៃទី ១០ ខែ១១ ១៩៦០។

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃនេះ លោកមានទីលំនៅនៅទីកន្លែងណា?

**ឆ៖** បច្ចុប្បន្នខ្ញុំនៅភូមិស្វាយចេក ឃុំថ្កាត ស្រុកអន្លង់វែង។

**ស៖** បាទ អរគុណ ហើយលោក ប៉ិច សុខា តើលោកប្រកបមុខរបរធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** បច្ចុប្បន្នខ្ញុំធ្វើជាពេទ្យរបស់រដ្ឋ។

**ស៖** បាទ អរគុណ ចុះឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ប៉ិច អុន។ ម្តាយ ឈ្មោះ ហៀក។ តែគាត់បានស្លាប់អស់ហើយ។

**ស៖** បាទ អរគុណ។ ហើយភរិយារបស់លោកឈ្មោះអី? តើលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ភរិយារបស់ខ្ញុំឈ្មោះ ឃុត យេតនិត្យ។ ខ្ញុំមានកូនបួននាក់។

[១៤:៤៤:១៨]

**សៈ** បាទ អរគុណលោក ប៊ិច សុខា។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ កាលពីព្រឹកមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ។ តើពិតមែនដែរឬទេ?

**ផៈ** ពិតហើយលោកប្រធាន ខ្ញុំអត់ដែលស្គាល់ផង គ្មានសាច់ញាតិសន្តានអ្វីទេ។

**សៈ** បាទ ហើយលោកមុននឹងផ្តល់សក្ខីកម្មនេះ តើលោកបាន -- ថាលោកបានស្បថរួចហើយតាមជំនឿរបស់លោក។ តើត្រឹមត្រូវដែរឬទេ?

**ផៈ** ត្រឹមត្រូវលោកប្រធាន ខ្ញុំស្បថរួចហើយ។

**សៈ** បាទ អរគុណ។ តទៅនេះ យើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចក្នុងនាមលោកជាសាក្សីដែលត្រូវឆ្លើយផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះ។ លោក ប៊ិច សុខា ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអំណះអំណាងណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ករណីយកិច្ចលោក ប៊ិច សុខា ក្នុងនាមលោកជាសាក្សីត្រូវតែផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនៅចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយ ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់សាក្សីរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងនាមលោកជាសាក្សី ត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនេះដែរឬទេ?

**ផៈ** យល់ លោកប្រធាន។

[១៤:៤៦:២៤]

**សៈ** បាទ អរគុណ។ ហើយលោក ប៊ិច សុខា តើលោកធ្លាប់ផ្តល់សក្ខីកម្មឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ នៅក្នុងរយៈពេលកន្លងមក ហើយបើសិនជាធ្វើ ធ្វើប៉ុន្មានដង? ហើយធ្វើនៅទីកន្លែងណា? នៅពេលណា?

**ផៈ** ខ្ញុំធ្លាប់ផ្តល់សម្ភាសន៍ម្តងតែរយៈពេលយូរ ខ្ញុំចាំមិនបាន ខ្ញុំភ្លេចហើយ។ នៅហ្នឹងកន្លែងមន្ទីរ

ពេទ្យអន្តង់វែង។

**ស៖** បាទ អរគុណលោក ប៊ុច សុខា។ ហើយមុនពេលអង្គុយផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលបានផ្តល់សក្ខីកម្មកាលពីលើកមុនធ្វើជាមួយអ្នកស៊ើបអង្កេតដែលលោកអះអាងថា ធ្វើនៅអន្តង់វែងនេះ ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំឱ្យកូនចៅខ្ញុំអានឱ្យស្តាប់ដែរ ប៉ុនគ្រាន់តែឥឡូវហ្នឹង ការចងចាំរបស់ខ្ញុំមានកម្រិតខ្សោយ វាទាក់ទងទៅនឹងការព្យាបាលជំងឺមកហ្នឹង ដូចជាវង្វេងវង្វាន់ខ្លះហើយ។ ថ្នាំវាធ្វើទុក្ខ ឥឡូវកំពុងតែធ្វើទុក្ខផង។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកអាចដឹង ហើយចងចាំ តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលលោកបានឱ្យកូនចៅរបស់លោកអានឱ្យស្តាប់ដើម្បីរំឭកការចងចាំនោះ ពិតជាត្រឹមត្រូវ ឬក៏ស៊ីសង្វាក់ស្របគ្នាទៅនឹងចម្លើយដែលលោកបានធ្វើផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

អាឡូ លោក ប៊ុច សុខា! អាឡូ!

មន្ត្រីរដ្ឋបាលតុលាការទំនងជាមានបញ្ហាបច្ចេកទេស សោតទស្សន៍ហើយ។

*(មានបញ្ហាបច្ចេកទេស)*

[១៤:៤៩:៣១]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ប៊ុច សុខា តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានឱ្យកូនចៅអានឱ្យលោកស្តាប់ដើម្បីរំឭកការចងចាំនោះ តើពិតជាត្រឹមត្រូវ ឬក៏ស៊ីចង្វាក់ស្របគ្នាទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតដែលធ្វើការពីពេលមុននោះដែរឬទេ?

**លោក ប៊ុច សុខា៖**

**ឆ៖** ស្របគ្នាហើយលោកប្រធានតាមស្តាប់មើលក្នុងរបាយការណ៍ហ្នឹង។

**ស៖** បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបលោក ប៊ុច សុខា ថាដោយសារលោកមានបញ្ហាសុខភាព ហើយប្រសិនបើលោកត្រូវការទៅបន្ទប់ទឹកនោះ លោកកុំខ្លាចរអែងអីនៅក្នុងអំឡុងពេលដំណើរការស្តាប់សក្ខីកម្មរបស់លោកនេះ លោកអាចប្រាប់ពួកយើង ដើម្បីយើងអនុញ្ញាតឱ្យយើង

ទៅបន្ទប់ទឹកបានប្រសិនបើលោកត្រូវទៅណ៎ះ?

**លោក ប៊ុច សុខា៖**

**ឆ៖** បាទៗ។

**ប្រធានអង្គជំនុំ៖**

បាទ ចំពោះកិច្ចសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ប៊ុច សុខា មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលបីវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

[១៤:៥១:០៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** សូមជម្រាបសួរលោក ប៊ុច សុខា ខ្ញុំសូមចាប់ផ្តើមដោយសួរអំពីការសិក្សា វគ្គសិក្សារបស់លោកនៅទីក្រុងភ្នំពេញដែលលោកបានពិភាក្សានៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ហើយនៅក្នុងកំណត់ហេតុនោះ គឺលោកនិយាយថាគេបញ្ជូនលោកមកឆ្នាំ៧៦ ដោយមនុស្សម្នាក់ឈ្មោះ ស្រេង ដែលជាគណៈស្រុក ហើយជាមិត្តភ័ក្តឪពុករបស់លោក។ ដូច្នេះ ខ្ញុំចង់ដឹងថាហេតុអ្វីបានជា ស្រេង បញ្ជូនលោកមកសាលានោះ?

**លោក ប៊ុច សុខា៖**

**ឆ៖** ទាក់ទងនឹងការងារនេះ គឺខ្ញុំក៏មិនដឹងថាហេតុអីដែរ ព្រោះកាលណោះខ្ញុំនៅក្មេង គេឲ្យខ្ញុំមករៀន ក៏មករៀនមក។

**ស៖** ថាតើលោកដឹងថា ស្រេង ហ្នឹងជាឈ្មោះហៅក្រៅ ឬក៏ជាឈ្មោះបដិវត្តន៍ ឬក៏ជាឈ្មោះពិតប្រាកដរបស់គាត់?

**ឆ៖** ខ្ញុំមិនដឹងថាជាឈ្មោះពីដើម ឬក៏ឈ្មោះអីទេ ប៉ុន្តែខ្ញុំស្គាល់ថាគាត់ឈ្មោះ ស្រេង តែប៉ុណ្ណឹង។

**ស៖** តើលោកចាំឈ្មោះ ឆាំ ដែរឬទេ? តើលោកស្គាល់ឈ្មោះនេះទេ?

**ឆ៖** ស្គាល់ឈ្មោះ ឆាំ ហ្នឹងគាត់ជាមេក្រុមខ្ញុំនៅពេលនោះ។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ យើងនិយាយអំពីឈ្មោះ ស្រេង។ តើលោកអាចប្រាប់តុលាការបានទេថាមានអ្វីកើតឡើងចំពោះ ស្រេង?

**ឆ៖** ខ្ញុំមិនដឹងដែរលោកតុលាការព្រោះអីខ្ញុំគ្រាន់តែស្គាល់គាត់ ដល់ហេតុការណ៍អីផ្សេងទៀត ខ្ញុំអត់យល់ដែរ។

[១៤:៥៣:២៥]

**ស៖** ឥឡូវនេះ យើងនិយាយអំពីឈ្មោះ ឆាំ ដែលលោកទើបតែនិយាយ។ តើលោកអាចប្រាប់បានទេថា តើ ឆាំ ហ្នឹងគឺជានរណា? ហើយតើលោកស្គាល់ឈ្មោះ ឆាំ ហ្នឹងដោយរបៀបណា?

**ឆ៖** ឈ្មោះ ឆាំ ហ្នឹង ខ្ញុំស្គាល់នៅពេលខ្ញុំទៅរៀននៅភ្នំពេញជាមួយគាត់។ ពីមុនមកក៏មិនដែលស្គាល់ដែរ។

**ស៖** តើលោកដឹងទេ ហេតុអ្វីគេបញ្ជូនគាត់ហ្នឹងទៅសាលានៅឫស្សីកែវ ហើយអ្នកណាជាអ្នកបញ្ជូនគាត់ទៅឫស្សីកែវនោះ?

**ឆ៖** ខ្ញុំពេលនោះខ្ញុំអត់ដឹងទេ ដឹងតែខ្លួនឯងតែម្នាក់ ទៅដល់ហ្នឹងទៅឃើញគាត់នៅហ្នឹងដែរ។ ខ្ញុំមិនដឹងថាអ្នកណាបញ្ជូនទេ។

**ស៖** តើមុនពេលដែលគេបញ្ជូនគាត់ទៅសាលាហ្នឹង តើគាត់មានតួនាទីអ្វីដែរ ឬក៏គាត់មានការងារជាអ្វីដែរ?

**ឆ៖** ខ្ញុំអត់ដឹងដែរពីមុន។ ខ្ញុំស្គាល់តែត្រឹមទៅដល់សាលាហ្នឹងគឺស្គាល់គាត់ ហើយពេលហ្នឹងគាត់ធ្វើជាមេក្រុមខ្ញុំ តែប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកនិយាយថា គាត់ជាមេក្រុមហ្នឹង តើជាមេក្រុមនៅពេលណា? ហើយជាមេក្រុមលោកហ្នឹងនៅទីណាដែរ?

**ឆ៖** នៅពេលរៀនបច្ចេកទេសហ្នឹង ហើយនិងចប់ពីរៀនបច្ចេសមកធ្វើការវិញ គាត់នៅជាមេក្រុមដដែល។ តែប៉ុណ្ណឹង។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកនៅផ្នែកខាងក្រោម លោកនិយាយអំពីឈ្មោះ តាឆាំ ដែល

ជាប្រធានរបស់លោកនៅការដ្ឋានទំនប់១មករា។ ថាតើ ឆាំ ហ្នឹង គឺជា ឆាំ ដែលលោករៀនជាមួយលោកនៅសាលាឫស្សីកែវហ្នឹង ឬក៏ជា ឆាំ ផ្សេងទេ?

**ឆ៖** ឆាំ ដដែលហ្នឹង ខ្ញុំស្គាល់គាត់តែ ឆាំ មួយហ្នឹងឯង អត់មាន ឆាំ ផ្សេងទេ។

**ស៖** ហើយលោកក៏បានបញ្ជាក់នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយជាមួយអ្នកស៊ើបអង្កេតថា មិត្តភក្តិរបស់លោកឈ្មោះ ឡុង មកពីតំបន់៤២ និងម្នាក់ទៀតឈ្មោះ ហោ មកពីតំបន់៤៣។ តើលោកអាចប្រាប់បានទេថា ពួកគាត់ទាំងពីរនាក់ហ្នឹងជាអ្នកណាដែរ? ហើយហេតុអ្វីបានជាគេបញ្ជូនគាត់ទាំងពីរនាក់ហ្នឹងទៅសាលានៅឫស្សីកែវ?

[១៤:៥៦:៣៣]

**ឆ៖** បាទ លោកតុលាការការងារហ្នឹងមិនខុសពីដូចឈ្មោះ ឆាំ ខាងលើទេ ខ្ញុំមិនដឹងថាមូលហេតុគេបញ្ជូនទៅហ្នឹងដោយមានផលប្រយោជន៍អីៗ ខ្ញុំអត់ទេ ទៅស្គាល់គ្នានៅសាលាតែម្ដង។

**ស៖** នៅក្នុងកំណត់ហេតុក្រោយមកទៀត លោកបាននិយាយមនុស្សពីរនាក់ឈ្មោះ ឡុង ហើយនិង ហោ ដែលបាត់ខ្លួនពីការដ្ឋានទំនប់១មករា។ ថាតើឈ្មោះ ឡុង និងឈ្មោះ ហោ នៅផ្នែកខាងក្រោយហ្នឹង គឺជាឈ្មោះ ឡុង ហើយនិង ហោ ដែលលោកជួបរៀនជាមួយគ្នានៅសាលាឫស្សីហ្នឹងមែនទេ?

**ឆ៖** បាទ ឈ្មោះគាត់ហ្នឹងខ្ញុំស្គាល់នៅសាលាឫស្សីកែវ ហើយក្រោយមកធ្វើការជាមួយគ្នា គឺឈ្មោះគាត់ហ្នឹងដែរ។

**ស៖** ក្រៅពីមនុស្សទាំងបីនាក់ គឺឆាំ, ឡុង ហើយនិង ហោ តើលោកចាំមិត្តភក្តិដទៃទៀតដែលរៀនជាមួយលោកនៅសាលាឫស្សីកែវដែរទេ?

**ឆ៖** ឱ! លោកតុលាការ ខ្ញុំភ្លេចហើយ មិនបានចាំទេ ព្រោះក្រៅពីបួននាក់ហ្នឹង ដូចជាមិនមានភាពស្និទ្ធស្នាលណាផ្សេងទៀត អត់មានទេ។

**ស៖** លោកក៏បាននិយាយថាក្នុងពេលដែលលោកសិក្សានៅសាលា គឺលោក គឺថាលោកមានការ -- ត្រូវបានលត់ដំយ៉ាងធ្ងន់ធ្ងរ។ តើលោកចង់មានន័យយ៉ាងម៉េចនៅពេលលោកថា លត់ដំយ៉ាងធ្ងន់ធ្ងរនៅសាលានោះ?

**ឆ៖** កាលលត់ដំយ៉ាងធ្ងនធ្ងរហ្នឹងគឺវាទាក់ទងនឹងការរៀនសូត្រ ទាក់ទងនឹងការហូបចុក វាមិនមែនធ្ងន់ធ្ងរដល់គេវ៉ៃដំអីទេ។

[១៤:៥៨:៥០]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកសហព្រះរាចអាជ្ញារង។ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំគ្រាន់ចោទសំណួរទាក់ទងនឹងវិធីសាស្ត្រសួរទេ។ លោកសហព្រះរាជអាជ្ញាអន្តរជាតិហ្នឹង គាត់បានដកស្រង់ផ្នែកមួយចំនួននៃចម្លើយរបស់គាត់ ដោយមិនឱ្យលេខ ERN នោះទេ។ គាត់គ្រាន់ឈ្មោះនោះមិនជាបញ្ហាទេ បើសិនជាមានផ្នែកដែលមួយចំនួននៃចម្លើយចាស់ៗរបស់សាក្សីដែលបានឆ្លើយពីមុនមកនោះ សូមឱ្យលោកសហព្រះរាជអាជ្ញាគាត់ផ្តល់លេខឯកសារ លេខ ERN ផងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ សូមលោកសហព្រះរាជអាជ្ញារងអន្តរជាតិធ្វើដូចតាមសំណើសុំរបស់មេធាវី ព្រោះនីតិវិធីយើងបានធ្វើដូច្នេះជាយូរមកហើយ។

[១៤:៥៩:៥៥]

**លោក ត្រាវិស៖**

លោកប្រធាន ខ្ញុំនឹងគោរពតាម។

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរអំពីការចាត់តាំងលោកទៅការដ្ឋានទំនប់១មករា។ លោកបាននិយាយថា លោកបានទទួលការចាត់តាំងនេះ គឺនៅក្នុងខ្មែរមានលេខ 00389522, អង់គ្លេសមានលេខ 00403003 និងបារាំងលេខ 00422237។ គឺលោកបាននិយាយថា នៅដើមឆ្នាំ៧៧ ពួកគេបានជ្រើសរើសទាំងបួននាក់ដើម្បីមកកសាងទំនប់១មករា ហើយលោកគឺជាអ្នកបច្ចេកទេស។ តើលោកអាចប្រាប់បានទេថា អ្នកណាគេជាមនុស្សបួននាក់ទៀត ដែលគេជ្រើសរើសក្រៅពីលោកផ្ទាល់នោះ?

**លោក ប៊ិច សុខា៖**

**ឆ៖** ទាក់ទងនឹងសមាសភាពបួននាក់ហ្នឹង គឺមាន ឆាំ, ហោ, ឡុង និងខ្ញុំ មានតែប៉ុណ្ណឹង អ្នកទៅរៀនសាលារួមគ្នានៅភ្នំពេញ ហើយមកធ្វើការជាមួយគ្នានៅទំនប់ ១មករា។

**ស៖** តើអ្នកណាជាអ្នកចាត់តាំងលោកឱ្យមកធ្វើការនៅទំនប់ ១មករា ហើយតើលោកទទួលការចាត់តាំងហ្នឹងដោយរបៀបណា?

**ឆ៖** ពេលចេញពីសាលាមកវិញ គេបានបង្គាប់ថាឲ្យទៅប្រមូលគ្នាទៅធ្វើការនៅទំនប់ ១មករា ហើយត្រង់អ្នកណាអ្នកបង្គាប់ពីណាពីណីទៀត យើងអត់ដឹងដែរ។

**ស៖** អ្នកណាជាអ្នកប្រាប់លោកដោយផ្ទាល់អំពីការចាត់តាំងដោយផ្ទាល់ទៅធ្វើការនៅទំនប់ ១មករានោះ?

**ឆ៖** គឺមេក្រុមខ្ញុំហ្នឹង បងឆាំ ហ្នឹងឯង គាត់រៀបរយ អ្នកប្រាប់មក។

**ស៖** ថាតើលោកមានជម្រើសដែរឬទេក្នុងការជ្រើសរើសការងារហ្នឹង។ គឺខ្ញុំចង់សួរថាតើលោកអាចបដិសេធបានទេ ប្រសិនបើលោកមិនចង់ធ្វើ?

**ឆ៖** អ៊ូ បើនិយាយពីរឿងបដិសេធអីនោះ ខ្ញុំមិនមានជម្រើសទេ គេឲ្យទៅធ្វើ ក៏ទៅទៅ មានតែប៉ុណ្ណឹង។

**ស៖** ហេតុអ្វីបានជាលោកមិនមានជម្រើសបែបនោះ?

[១៥:០២:៥៧]

**ឆ៖** ព្រោះពេលនោះយើងមិនអាចនិយាយថាយ៉ាងម៉េច ប៉ុនគ្រាន់ថាគេចាត់តាំងឲ្យទៅហើយ គឺត្រូវតែទៅធ្វើអីចឹងទៅ។

**ស៖** ប្រសិនបើលោកមិនគោរពតាមការចាត់តាំងទេ លោកគិតថានឹងមានអ្វីកើតឡើងចំពោះលោកដែរ?

**ប្រធានអង្គជំនុំ៖**

បាទ លោកមេធាវីមិនគប្បីប្រើពាក្យសំណួរឧបមានវិធីទេ។ បើសិនបើទេ មិនឲ្យសាក្សីឆ្លើយស្មានៗទេ។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

លោកសហព្រះរាជអាជ្ញារង រៀបចំសម្រួលសំណួរឡើងវិញ។

**លោក ត្រាវិស ហ្សារ៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងបន្តទៅសំណួរបន្ទាប់។

**សួរដោយលោក ត្រាវិស ហ្សារ៖**

**ស៖** តើលោកអាចប្រាប់បានទេ ថានៅពេលដែលលោកមកដល់ទំនប់១មករា ថាតើលោកស្នាក់នៅ ធ្វើការទីនោះ អស់រយៈពេលប៉ុន្មានដែរ?

**លោក ប៉ិច សុខា៖**

**ឆ៖** ខ្ញុំចាំបានថា ចាប់ពីដើមមកដល់ទំនប់១មករា និងដល់ដែលបញ្ចប់ហ្នឹង ខ្ញុំធ្វើការបានប្រហែលមួយឆ្នាំជាង តិចតែប៉ុណ្ណឹងទេ។

**ស៖** តើលោកចាំថា លោកមកដល់ការដ្ឋានហ្នឹងនៅថ្ងៃណាទេ ឬក៏ប្រហែលថានៅថ្ងៃ ខែ ឆ្នាំណាទេ?

**ឆ៖** ខ្ញុំចាំបាន ថាដូចជាឆ្នាំ៧៧ ប៉ុន្តែថ្ងៃខែ មិនបានចាំល្អិតល្អន់ទេ។

**ស៖** ក្នុងក្រុមលោកដែលជាអ្នកបច្ចេកទេសវាស់ស្ទង់ តើលោកធ្វើការរួមជាមួយនឹងកម្មករដទៃទៀតដែរឬទេ ឬមួយក៏លោកធ្វើការដាច់តែឯង គឺធ្វើការតែក្នុងក្រុមអ្នកបច្ចេកទេសវាស់ស្ទង់នោះទេ?

**ឆ៖** ខ្ញុំធ្វើការតែក្រុមការងារវាស់ស្ទង់បច្ចេកទេស ពួកខ្ញុំបួននាក់ប៉ុណ្ណឹងឯង។

**ស៖** តើលោកធ្លាប់ជួយការងារពលកម្មដូចជាការជីកដី រែកដី អ្វីដែរឬទេនៅការដ្ឋាននោះ?

**ឆ៖** អាការងារហ្នឹងវាម្ដងម្កាល ពេលថ្ងៃណាដែលយើងមិនមានការចុះស្ទង់ដីអី ដូចជាពេលយប់អី យើងត្រូវ គេឲ្យយើងទៅជួយលើកដី លើកទំនប់ហ្នឹងដែរ។

**ស៖** តើលោកអាចប៉ាន់ប្រមាណទេ ថាតើលោកជួយការងារពលកម្មដូចជា រែកដី ជីកដី ហ្នឹងប៉ុន្មានដងដែរនៅពេលដែលលោកធ្វើការនៅកាដ្ឋាននោះ?

**ឆ៖** ឲ្យទៅចាំដង មកដល់ពេលនេះវាភ្លេចហើយ ព្រោះវាមិនមែនជាការងារស្នូលរបស់ខ្ញុំទេនោះ។

[១៥:០៦:៤៧]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់សួរអំពីប្លង់ការដ្ឋាននោះ ដែលលោកបាននិយាយផងដែរនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺនៅទំព័រ ខ្មែរមានលេខ 00389522 ទៅដល់ 23, អង់គ្លេសមានលេខ 00403004 និងបារាំងមានលេខ 00422239។ លោកបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ខ្ញុំបានទទួលប្លង់ពីអង្គការលើ”។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកទទួលបានប្លង់ផែនការពីថ្នាក់លើហ្នឹងគេ -- តើលោកចង់និយាយមានន័យយ៉ាងម៉េច?

**ឆ៖** ខ្ញុំចង់និយាយថា ប្លង់នេះមិនមែនជាពួកខ្ញុំអ្នកផលិតទេ ថ្នាក់លើ តែក៏មិនដឹងអ្នកណាដែរ តែខ្ញុំទទួលបានពីមេក្រុមខ្ញុំគាត់យកមកបង្ហាញ ហើយពិភាក្សាគ្នាធ្វើតាមប្លង់ហ្នឹង ប៉ុនដឹងថាប្លង់ហ្នឹងមកពីអង្គការថ្នាក់លើ ប៉ុន្តែមិនដឹងអ្នកណាជាអ្នកផលិត អ្នកអី ខ្ញុំក៏មិនដឹងដែរ។

**ស៖** នៅពេលដែលលោកនិយាយថាមេក្រុមរបស់លោក គឺលោកចង់និយាយទៅលើ ឆាំ ដែល

យើងពិភាក្សាមុននេះ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកដឹងទេ ថាតើឈ្មោះ ឆាំ ដែលជាមេក្រុមរបស់លោកនេះទទួលបានប្លង់ហ្នឹងពីៗ អ្នកណាមក?

**ឆ៖** ត្រង់ហ្នឹងឯងដែលខ្ញុំនិយាយអំមិញជម្រាបលោកតុលាការថាខ្ញុំមិនដឹងទេ ព្រោះខ្ញុំដឹង គឺនៅក្រោមបញ្ជារបស់គាត់ប៉ុណ្ណឹង។

**ស៖** ដូច្នេះតើមូលហេតុអ្វីទើបលោកនិយាយ ឬក៏លោកដឹងថាប្លង់ហ្នឹងបានមកពីថ្នាក់លើ? ហើយតើលោកនិយាយថាថ្នាក់លើហ្នឹង ក្នុងបរិបទហ្នឹង តើលោកចង់សំដៅទៅលើអ្វី?

[១៥:០៩:១៤]

**ឆ៖** ថ្នាក់លើហ្នឹង បានន័យថាយើងសំដៅភាសាសម័យនោះ គេថាអង្គការៗ ពាក្យថាអង្គការហ្នឹង មិនដឹងអ្នកណាផងទេ។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើប្លង់ទំនប់ហ្នឹងវាមានលក្ខណៈបែបណាដែរ? តើជាការគូសប្លង់របៀបបច្ចេកទេសនៅលើក្រដាស ឬមួយក៏ជាគំរូទំនប់ ឬក៏យ៉ាងម៉េចដែរ? ខ្ញុំចង់ដឹងថាតើលោកទទួលបានប្លង់ហ្នឹង ជាប្លង់ដែលមានលក្ខណៈបែបណាដែរ?

**ឆ៖** ប្លង់នេះមិនមែនជារូបភាពថត ដូចជាកាសែតអីទេ គឺប្លង់គូរជាប្លង់ក្រដាស។

**ស៖** អ៊ីចឹងវាប្លង់ហ្នឹងគឺនៅលើក្រដាសតែមួយសន្លឹកទេ តើអ៊ីចឹងមែនទេ? ហើយក្រដាសហ្នឹងវាធំ មានទំហំប៉ុនណាដែរ?

**ឆ៖** ក្រដាសហ្នឹង ជាទទឹងប្រហែលជាប៉ុន្នាន តាមស្មានមកដល់ឥឡូវថាប្រហែល ទទឹងវាប្រហែលជា ៦០ គុណនឹង ៨០ ប៉ុណ្ណឹងទេ មួយសន្លឹក។

**ស៖** តើលោកស្គាល់ឈ្មោះ សោ ថាតើឈ្មោះ សោ ហ្នឹងបានចូលរួមនៅក្នុងទំនប់ ១មករា ឬក៏នៅក្នុងការគូសប្លង់នោះដែរឬទេ?

**ឆ៖** អត់ដែលស្គាល់ផង ឈ្មោះ សោ ណាដូចអត់ដែលឮ។

**ស៖** ខ្ញុំសូមអានឈ្មោះម្តងទៀត គាត់ឈ្មោះ សៅ។

**ឆ៖** ឈ្មោះ សៅ ក៏អត់ដែលស្គាល់។

[១៥:១១:៤៧]

**លោក សេង លាង៖**

ដោយសារសហព្រះរាជអាជ្ញារងអន្តរជាតិគាត់អានឈ្មោះមិនៗសូវច្បាស់ តាមពិតឈ្មោះហ្នឹង គឺឈ្មោះ សៅ។ សូមអ្នកបកប្រែឱ្យ -- នេះ ឈ្មោះ សៅ។

**លោក ប៊ុច សុខា៖**

**ឆ៖** ឈ្មោះ សៅ ណាខ្ញុំអត់ស្គាល់ទេ។

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** តើលោកអាចរៀបរាប់ជាទូទៅបានទេថា ទំនប់ ១មករាហ្នឹងវាមានលក្ខណៈបែបណាដែរ? ហើយតើទំនប់ ១មករាហ្នឹង មានគោលដៅដើម្បីធ្វើអ្វីដែរ? សូមលោករៀបរាប់ជាលក្ខណៈទូទៅ។

**ឆ៖** លក្ខណៈទូទៅទំនប់១មករាហ្នឹង ធ្វើមកដើម្បីបម្រើដល់ផ្នែកកសិកម្ម យកទឹកដើម្បីធ្វើស្រែ ឱ្យប្រជាជនធ្វើ។ នេះជាហេតុផលដែលឃើញ តែត្រង់អត្ថន័យបង្កប់យ៉ាងម៉េចទៀត ខ្ញុំមិនដឹងដែរទេ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេត គឺខ្មែរមានលេខ 00389526, អង់គ្លេសមានលេខ 0040300 ដល់ 6 ដល់ 8 និងបារាំង មានលេខ 00422238។ គេសួរលោកថា៖ “តើទំនប់ ១មករាហ្នឹង មានចម្ងាយ ៦០គីឡូម៉ែត្រដែរឬទេ?” ហើយលោកនិយាយថា៖ “៦០គីឡូម៉ែត្រ មិនត្រឹមតែទំនប់ ១មករាតែមួយទេ តែ៦០គីឡូម៉ែត្រធ្លាយទៅទំនប់ ៦មករាទៀត”។ សូមបញ្ចប់ការដកស្រង់។ តើលោកអាចផ្តល់ព័ត៌មានបន្ថែមបានដែរឬទេ ថាតើគម្រោងទំនប់ទាំងពីរហ្នឹងភ្ជាប់ទំនាក់ទំនងជាមួយគ្នាដោយរបៀបណាដែរ?

[១៥:១៤:០៥]

**ឆ៖** បាទ មិនខុសពីខ្ញុំជូនព័ត៌មានពេលមកសម្ភាសន៍មុនទេ វា៦០គីឡូម៉ែត្រជាងហ្នឹង ទំនប់ពីរហ្នឹងវាភ្ជាប់គ្នាដែលមានចម្ងាយរយៈពេលប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេថាតើវាមានគោលដៅ ឬក៏គោលបំណងអ្វីដែលទំនប់ទាំងពីរនោះភ្ជាប់ជាមួយគ្នាហើយ តើទំនប់ទាំងពីរនោះភ្ជាប់ជាមួយគ្នាដោយរបៀបណាដែរ?

**ឆ៖** គោលដៅ គោលបំណង អត្ថន័យវាអី ខ្ញុំមិនដឹងថាយ៉ាងម៉េចទេព្រោះធ្វើទៅតាមបង្គាប់របស់ថ្នាក់លើ ប៉ុន្តែគ្រាន់តែទំនប់ ១មករា វាធ្វើមុន, ៦មករា វាធ្វើភ្ជាប់ក្រោយមក។ មានតែប៉ុណ្ណឹង។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកអំពី កែ ពក ដែលមកមើលការដ្ឋានហ្នឹងដែលលោកបានរៀបរាប់នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយសហចៅក្រមស៊ើបអង្កេតគឺទំព័រ ខ្មែរមានលេខ 00389525

ដល់26, អង់គ្លេសមានលេខ 00403007 និងបារាំងមានលេខ 00422242។ លោកនិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “កែ ពក ចុះមកត្រួតពិនិត្យផ្ទាល់ស្ទើរតែរៀងរាល់ថ្ងៃដោយជិះឡានហ្សីប និងមានកងការពាររបស់គាត់។ ដូច្នេះយើងមិនចាំបាច់រាយការណ៍ទៅថ្នាក់លើទេ។ ប៉ុន្តែខ្ញុំមិនដឹងថា កែ ពក រាយការណ៍ទៅលើបន្តទៀត ឬក៏អត់ទេ? តាពក គាត់មិនដែលស្ដីបន្ទោសទេ។ ពេលមក គាត់តែងតែណែនាំយើងឲ្យធ្វើអ្វីៗឲ្យត្រូវទៅតាមប្លង់ ឲ្យបានត្រឹមត្រូវ មិនឲ្យខុសប្លង់ទេ។ ពួកយើងមិនដែលធ្វើឲ្យខុសពីប្លង់ទេ។ ពេលនោះ ឆាំ ជាប្រធានក្រុមរបស់ខ្ញុំព្រោះគាត់ចាស់ជាងខ្ញុំ”។ សូមបញ្ចប់ការដកស្រង់។

**ឆ៖** គឺត្រូវតាមអ្វីដែលអានអំមិញហ្នឹងហើយ។

**ស៖** សូមអរគុណ។ តើលោកអាចប្រាប់អំពីហេតុការណ៍ដែល កែ ពក ចុះមកប្រាប់ពួកលោកឲ្យធ្វើតាមប្លង់ឲ្យបានត្រឹមត្រូវ។ តើលោកអាចប្រាប់បានទេ ថាតើគាត់ប្រាប់លោកហ្នឹងនៅកន្លែងណា? ហើយអ្នកណាខ្លះនៅជាមួយលោក ពេលគាត់ប្រាប់បែបនេះ?

[១៥:១៧:០៥]

**ឆ៖** គាត់ប្រាប់នៅកន្លែងសំណង់យើងធ្វើការ ក្រុមយើងបួននាក់ហ្នឹង។ “ឲ្យទៅធ្វើអី ទៅធ្វើតាមប្លង់ ថាកុំឲ្យធ្វើខុស” គឺគាត់និយាយតែប៉ុណ្ណឹង។

**ស៖** តើលោកនៅកន្លែងណាដែរនៅការដ្ឋាន? តើលោកនៅកន្លែងសាធារណៈ ឬក៏លោកនៅទីណាមួយដែលនៅក្នុងការដ្ឋាននោះ?

**ឆ៖** នៅជាមួយនឹងប្រជាជនទូទៅ ប៉ុនគ្រាន់តែយើងមានរោងមួយក្រុមបច្ចេកទេសៗ យើងមានរោងមួយដោយឡែកតែប៉ុណ្ណឹង។

**ស៖** លោកបាននិយាយថា គាត់មកសឹងតែរៀងរាល់ថ្ងៃ។ ហើយពួកគាត់ចុះមកមើលហ្នឹង តើគាត់មកមើលក្រុមលោកសឹងតែរាល់ថ្ងៃដែរឬទេ?

**ឆ៖** មិនទេ ការពិតមកមើលក្រុមបច្ចេកទេសមិនមែនរាល់ថ្ងៃ ប៉ុន្តែការមកត្រួតពិនិត្យការដ្ឋានគាត់មកជាញឹកញាប់។

**ស៖** នៅពេលដែលគាត់មកជួបជជែកជាមួយក្រុមរបស់លោក តើសមាជិកក្រុមរបស់លោកមានផ្ដល់ព័ត៌មានលម្អិតអំពីការងារវិវត្តន៍ប្រាប់ទៅ កែ ពក ដែរឬទេ?

**ឆ៖** បើគាត់សួរអី យើងឆ្លើយហ្នឹងទៅ បើគាត់មិនសួរ យើងក៏មិននិយាយអីដែរ។

**ស៖** តើលោកចាំទេថាតើ កែ ពក សួរសំណួរអ្វីខ្លះមកក្រុមលោក?

**ឆ៖** គាត់សួរ មានសួរអីខុសពីប្លង់ហ្នឹងទេ ថាធ្វើយ៉ាងម៉េច អីយ៉ាងម៉េចអ៊ីចឹង។ អត់មានសួរអីវែងឆ្ងាយហួសពីហ្នឹងទេ។

**ស៖** តើមេក្រុមរបស់លោកគឺ ឆាំ ហ្នឹងធ្លាប់ប្រាប់លោកអ្វីអំពី កែ ពក ដែរឬទេ? ថាតើលោកដឹងថា ឆាំ ហើយនិង កែ ពក ហ្នឹងគាត់មានទំនាក់ទំនងអ្វីដែរ?

[១៥:១៩:៤៩]

**ឆ៖** អ៊ូ! ខ្ញុំអត់ដឹង ដូចខ្ញុំជម្រាបលោកតុលាការ ខ្ញុំស្គាល់តែត្រឹមទៅរៀនហ្នឹង តែប៉ុណ្ណឹងទេពីមុនមកមិនដែលស្គាល់គ្នាផង។

**ស៖** នៅក្នុងចម្លើយដដែលហ្នឹង ក៏លោកបានរៀបរាប់ផងដែរថា កែ ពក គឺជាគណៈភូមិភាគកណ្តាល និងជាប្រធានគណៈកម្មាធិការសាងសង់ទំនប់។ តើលោកធ្វើយ៉ាងណាដឹងថា កែ ពក គឺជាប្រធានក្តាប់រួមទៅលើការដ្ឋានទំនប់នេះ?

**ឆ៖** អ៊ូ! ពេលនោះ គេចាក់មីក្រូមុនគេបើកការដ្ឋាន។ គេចាក់មីក្រូ គេប្រកាសអ៊ីចឹង យើងចាំបានត្រង់ហ្នឹងឯង។

**ស៖** តើលោកដឹងថា កែ ពក ជាគណៈភូមិភាគកណ្តាលហ្នឹងដោយរបៀបណា?

**ឆ៖** ដឹងដូចខ្ញុំជម្រាបអំមិញអ៊ីចឹង ដូចជូនដំណឹងអំមិញទៅលោកតុលាការហ្នឹង។ ដឹងតាមគេផ្សាយនៅពេលគេបើការដ្ឋានហ្នឹង។ រឿងស្គាល់គ្នាពីមុនមក ក៏មិនដែលស្គាល់ដែរទេ។

**ស៖** ពេលដែលគាត់ចុះមកពិនិត្យការដ្ឋានទំនប់ដើម្បីពិនិត្យមើលការងារហ្នឹង តើគាត់នៅការដ្ឋានហ្នឹងរយៈពេលប្រហែលប៉ុន្មានម៉ោង ប៉ុន្មាននាទីអ្វីដែរ? លោកចាំទេ?

**ឆ៖** ខ្ញុំមិនបានចាំទេ។ ពេលឃើញក៏ជួនណាក៏ឃើញទៅ ហើយត្រង់ទៅវិញថ្មើរណាយើងក៏មិនដឹងដែរ ព្រោះការងារខ្ញុំមិននៅនឹងកន្លែងហ្នឹងទេ ខ្ញុំដើរចល័ត ស្ទង់ដី។

[១៥:២២:០៨]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់សួរពីអ្វីដែលលោកទើបតែនិយាយទាក់ទងទៅនឹងពិធីបើកការដ្ឋានសាងសង់ទំនប់។ នៅក្នុងកិច្ចសម្ភាសន៍របស់លោក លោកបានរៀបរាប់នៅខ្មែរទំព័រលេខ 00389527, អង់គ្លេសមានលេខ 00403008, និងបារាំងមានលេខ 00422243។ លោកបាននិយាយដូចតទៅនេះ ខ្ញុំសុំដកស្រង់៖ “តាមខ្ញុំចាំមានពិធីបើកការដ្ឋាននៃការសាងសង់ទំនប់នោះ ដែលមានមេភូមិភាគ និងប្រធានតំបន់ចូលរួម។ ចំណែកមេដឹកនាំធំៗពីមជ្ឈិម ខ្ញុំមិនបានឃើញមានការចូល

រួមទេ។ ក្នុងការបើកការដ្ឋានហ្នឹង ខ្ញុំទាំងបួននាក់ក៏បានចូលរួមស្តាប់ជាមួយប្រជាជនដែរ។" បញ្ចប់ការដកស្រង់។

**ឆ៖** ដែលឆ្លើយរបស់ខ្ញុំហ្នឹង គឺប៉ុណ្ណឹង។ ខ្ញុំបានឃើញតែប៉ុណ្ណឹងដែរ។

**ស៖** នៅពេលដែលលោកនិយាយអំពីមេភូមិភាគហ្នឹង ឬក៏គណៈភូមិភាគហ្នឹង លោកចង់សំដៅទៅលើ កែ ពក។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ។

**ស៖** តើលោកអាចប្រាប់ឈ្មោះប្រធានតំបន់ដែលចូលរួមនៅក្នុងពិធីបើកការដ្ឋានដែលលោកចាំទេថា ប្រធានតំបន់ណាចូលរួមខ្លះ?

**ឆ៖** ពេលនោះវា គេបង្ហាញតាមមីក្រូដែលយើងចូលរួមស្តាប់ហ្នឹងមានតំបន់៤៣ និង ៤២ មានតែប៉ុណ្ណឹង។

**ស៖** តើលោកមានស្តាប់ឮការប្រកាសឈ្មោះប្រធានតំបន់ដែលចូលរួមទេ?

**ឆ៖** ដូចជាម៉េចទេ ដូចភ្លេចហើយត្រង់ហ្នឹង។

[១៥:២៤:៤៨]

**ស៖** តាមដែលលោកចាំ អំពី -- តើលោកអាចប្រាប់បានទេថាតើគេនិយាយអ្វីខ្លះនៅក្នុងពិធីបើកការដ្ឋាននោះ?

**ឆ៖** តាមចាំបាន ទី១ គេនិយាយអំពីថ្ងៃបើកការដ្ឋាន ហើយឲ្យយើងប្រឹងប្រែងធ្វើដើម្បីសម្រេចឲ្យបានតែប៉ុណ្ណឹង។

**ស៖** តើគេមាននិយាយអំពីសារៈសំខាន់នៃគម្រោងសាងសង់ ឬក៏រយៈពេលដែលគេត្រូវសាងសង់បញ្ចប់ការដ្ឋាននោះដែរទេ?

**ឆ៖** ខ្ញុំដូចជាភ្លេចហើយលោកតុលាការ។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកអំពីដំណើរទស្សនកិច្ចរបស់ប្រតិភូបរទេសដែលបានមកទីនោះ គឺលោកនិយាយនៅទំព័រខ្មែរមានលេខ 00389527, អង់គ្លេសមានលេខ 00403008 ដល់ 09 និងបារាំងមានលេខ 00422244។ ហើយលោកបាននិយាយដូចតទៅនេះ៖ ខ្ញុំឃើញភ្ញៀវចិននិងភ្ញៀវមកូរ៉េមកថតរូបនៅទីនេះ ហើយគេ ហើយខ្ញុំមិនដែលឃើញពួកគេត្រឡប់មកវិញទេ។ ហើយនៅពេលដែលគេ -- ហើយសួរអ្នកណាជាអ្នកតាមជាមួយនោះ គឺលោកនិយាយថាគឺខាងគណៈភូមិភាគ។ ដូច្នេះខ្ញុំចង់សួរថា

តើលោកនិយាយថាគណៈភូមិភាគហ្នឹងទៅសំដៅទៅលើ កែ ពក តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ្វីដែលខ្ញុំនិយាយហ្នឹងគឺមានន័យក្តោបប៉ុណ្ណឹងឯង។

[១៥:២៧:០៥]

**ស៖** តើលោកដឹងអំពីឈ្មោះ ឬក៏អត្តសញ្ញាណរបស់ភ្ញៀវចិន ឬក៏ភ្ញៀវកូរ៉េ ដែលមកមើលការដ្ឋាននោះដែរឬទេ?

**ឆ៖** អូ៎! អត់ដឹងទេលោក។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីជោគវាសនានៃមិត្តភក្តិរបស់លោកដែលរៀននៅសាលាឫស្សីកែវក្នុងទីក្រុងភ្នំពេញនេះ គឺឈ្មោះ ឡុង ហើយនិងឈ្មោះ ហោ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកនៅទំព័រ 00389524 ដល់ 25 ជាភាសាខ្មែរ, 00403006 អង់គ្លេស និងទំព័រ 00422241 ជាភាសាបារាំង។ គេសួរលោកអំពីការចាប់ខ្លួនមនុស្សដែលត្រូវបានចោទថាជាខ្មាំង។ ហើយលោកបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់ "ចំពោះខ្លួនខ្ញុំផ្ទាល់ខ្ញុំមិនដែលជួបប្រទះទេ ប៉ុន្តែនៅក្នុងក្រុមរបស់ខ្ញុំមានបាត់ខ្លួនមនុស្សពីរនាក់ឈ្មោះ ឡុង និង ហោ។ គាត់ទាំងពីរត្រូវអង្គការតំបន់របស់គាត់ហៅគាត់ឲ្យត្រឡប់ទៅវិញ។ គាត់ទាំងពីរបានយកសំបុត្រមកបង្ហាញខ្ញុំ ហើយលាខ្ញុំទៅស្រុកវិញ។ សំបុត្រនោះសរសេរដោយដៃ។ គាត់ទាំងពីរមានចំណេះដឹងខ្ពង់ខ្ពស់។ ខ្ញុំបានរៀនសូត្រពីគាត់ទាំងពីរនាក់មិនតិចទេ។ ខ្ញុំទើបតែដឹងថាគាត់ទាំងពីរត្រូវបានចាប់ខ្លួន និងសម្លាប់ក្រោយពេលសមាហរណកម្មនេះ"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់ៗដឹងថាតើលោកដឹងដោយរបៀបណាថា ឡុង ហើយនិង ហោ ត្រូវបានគេចាប់ខ្លួន ហើយសម្លាប់?

[១៥:២៩:០៨]

**ឆ៖** បញ្ហាហ្នឹងពីមុនមកក៏ខ្ញុំមិនដឹងដែរ តែក្រោយមក ខ្ញុំគិតថាអ្នកទាំងអស់គ្នាហ្នឹងបើសិនជានៅឮឈ្មោះហើយ ព្រោះជាមិត្តភក្តិ។ ខ្ញុំយល់ថាគាត់ស្លាប់ហើយ។

**ស៖** ហើយលោកបានផ្តល់ចម្លើយទាក់ទងទៅនឹងអ្នកចាប់ខ្មាំង។ តើលោកដឹងទេថា វាអាចដែលឬទេដែលថា ឡុង ហើយនិង ហោ ត្រូវបានគេចោទថាជាខ្មាំងនោះ?

**ឆ៖** ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង ពីមុននេះដែលគាត់លាខ្ញុំទៅ យើងមិនដឹងថាគាត់ទៅណា ប៉ុន្តែដឹងថាគាត់ទៅកន្លែងដើមវិញ។ តែរឿងខ្ញុំគិតថាគាត់ស្លាប់នេះ មកពីការមិនឃើញ មកដល់ថ្ងៃនេះវាមិនដែលឃើញ។

**ស៖** លោកបាននិយាយថា ពួកគេទទួលបានលិខិតសរសេរជា ដោយផ្ទាល់ដៃ ហើយមុនពេលពួកគាត់ទៅ គាត់បានយកលិខិតមកបង្ហាញ។ តើលោកចាំទេ ថាលិខិតហ្នឹងគេសរសេរអំពីអ្វីដែរ?

**ឆ៖** ខ្ញុំមិនចាំ ប៉ុនគ្រាន់តែគាត់បង្ហាញថានេះលិខិតមកហ្នឹង គេឲ្យខ្ញុំទៅកន្លែងដើមវិញ តែប៉ុណ្ណឹងហើយខ្ញុំក៏សូមជូនគាត់ឲ្យទៅឲ្យបានសុខ។ គាត់ក៏ផ្តាំយើងថា ខំធ្វើការតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមចូលទៅផ្នែកផ្សេងទៀតនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក ខ្ញុំនឹងដកស្រង់នូវទំព័រជាភាសាខ្មែរ 00389527, ជាភាសាអង់គ្លេស 00403008, ជាភាសាបារាំង 00422243 ដល់ 44។ នេះគឺជាអ្វីដែលលោកបានឆ្លើយនៅពេលនោះ "ជារៀងរាល់ថ្ងៃ គេចាក់ចម្រៀងបដិវត្តន៍ គឺថាមើលទៅដូចជាសប្បាយណាស់។ កន្លែងណាក៏មានចាក់ចម្រៀងដែរ តែតាមពិតមានការលំបាកណាស់ ទាំងការហូបចុក ទាំងការស្នាក់នៅ និងបញ្ហាសុខភាព ប៉ុន្តែគ្មានអ្នកណាម្នាក់ហ៊ាននិយាយទេ។ ឥឡូវ បើខ្ញុំមើលទៅក្រោយវិញ គួរឲ្យរន្ធត់ចិត្តណាស់ មិនសមថាខ្ញុំបានរស់មកដល់ពេលនេះទេ"។ លោកបាននិយាយថា "វាគួរឲ្យរន្ធត់ចិត្ត" អ៊ីចឹងតើម៉េចបានជាលោកនិយាយបែបហ្នឹង?

[១៥:៣២:១៣]

**ឆ៖** ការនិយាយបែបហ្នឹង មិនខុសពីអ្វីដែលខ្ញុំជម្រាបខាងដើម។ យើងមើលទៅរូបភាពហាក់ដូចជាសប្បាយគគ្រឹកគគ្រេងមីក្រូ ប៉ុន្តែការលំបាក វាលំបាក ដូចខ្ញុំជម្រាបអ៊ីចឹង វាហូបចុកមិនគ្រប់គ្រាន់ ទាក់ទងនឹងបញ្ហាសុខភាព ការងារពលកម្មវាធ្ងន់ ហ្នឹងហើយគួរឲ្យរន្ធត់។

**ស៖** ក្រៅពីការងារពលកម្មហ្នឹង តើមានចំណុចណាផ្សេងទៀតទេដែលលោកនិយាយថា វាគួរឲ្យរន្ធត់ចិត្តហ្នឹង?

**ឆ៖** មិនមានអីផ្សេងក្រៅប៉ុណ្ណឹង ព្រោះខ្ញុំដឹង សម្រាប់ខ្ញុំគិតប៉ុណ្ណឹង ព្រោះពេលនោះខ្ញុំដឹងតែត្រឹមប៉ុណ្ណឹងដែរ។

**ស៖** លោកនិយាយថា លោកមិនសមបានរស់ទេ។ ក្នុងចម្លើយរបស់លោកនោះលោកថា "មិនសមថាខ្ញុំបានរស់ទេ មកដល់ពេលនេះ"។ ហេតុអីបានជាលោកនិយាយថាលោកមិនសមបានរស់ពីទំនប់១មករាហ្នឹង?

**ឆ៖** ហេតុផលត្រង់ហ្នឹងគឺទាក់ទងនឹងការងារពលកម្ម។ បើថ្ងៃក៏ធ្វើការ យប់ក៏ធ្វើការ ហូបចុកមិនគ្រប់គ្រាន់ វាមិនសមបានរស់មកដល់ថ្ងៃនេះទេ។ ន័យត្រង់ហ្នឹង។

[១៥:៣៤:១២]

**ស៖** លោកបានឆ្លើយថា គ្មានអ្នកណាម្នាក់ហ៊ាននិយាយទេ។ អ៊ីចឹងខ្ញុំ ឥឡូវខ្ញុំសំដៅទៅលើលោកតែម្តង។ ហេតុអីបានជាលោកមិនហ៊ានរអ៊ូរទាំអំពី ឧទាហរណ៍ដូចជា ការហូបចុកមិនគ្រប់គ្រាន់ ហើយនិងធ្វើការលំបាកលំបិននោះ?

**ឆ៖** ហ្នឹងគឺវាមិនអាចនិយាយបានទេ នៅសម័យនោះនោះ មែនដូចសម័យឥឡូវណា។ ធ្វើម៉េចតែឲ្យសុខៗ រស់ៗទៅ។

**ស៖** នេះប្រហែលជាប្រៀបធៀបដ៏ល្អមួយ។ លោកបាននិយាយថា លោកមិនអាចរអ៊ូរទាំដូចឥឡូវទេ។ អ៊ីចឹងតើសម័យនុ៎ងយ៉ាងម៉េចដែរ បានជាលោកមិនអាចមានសិទ្ធិសេរីរអ៊ូរទាំ ឬក៏តវ៉ាដូចដែលសព្វថ្ងៃហ្នឹង?

**ឆ៖** កាលសម័យហ្នឹង ខ្ញុំមានគ្នាតែបួននាក់ទេ ការងារធ្វើការងារតែបួននាក់ហ្នឹងទេ អ្វីដែលឲ្យធ្វើ ខ្ញុំធ្វើប៉ុណ្ណឹងទៅ ហើយបើឃើញប្រជាជនគេៗធ្វើអ៊ីចឹងដូចខ្ញុំដែរហ្នឹង នៅតវ៉ាឯណា។

**ស៖** អ្នកផ្សេងទៀតនោះមានដែលបានប្រាប់លោកទេថាហេតុអ្វីបានជាពួកគេមិនហ៊ានតវ៉ានោះ?

**ឆ៖** អ៊ូ! កាន់តែឆ្ងាយទៀតហើយពីរឿងទៅនិយាយស្តីអីផ្សេងទៀត ខ្ញុំមិនដឹងទេ។ ខ្ញុំដឹងតែការងារក្រុមខ្ញុំបួននាក់តែប៉ុណ្ណឹងឯង។

**ស៖** បើសិនជាលោកខ្លាចនោះ លោកប្រាកដទៅ លោកខ្លាចអ្វីដែរនៅពេលនោះ?

**ឆ៖** ទេ វាមិនដឹងថាខ្លាចពីរឿងអី ប៉ុនមិនដឹងថាវាមិនមានការងារអីក្រៅពីធ្វើការតែប៉ុណ្ណឹងទេ។

[១៥:៣៦:៤១]

**ស៖** ខ្ញុំនឹងអានសម្រង់ផ្សេងទៀត ជាភាសាខ្មែរគឺ 00389525, ជាភាសាអង់គ្លេស 00403006ទៅដល់ 07, ជាភាសាបារាំង 00422241។ លោកបានឆ្លើយនៅពេលនោះថា ខ្ញុំសូមដកស្រង់៖ “ខ្ញុំ ហោ និង ឡុង មិនដែលបានចូលរួមប្រជុំអីទេ ឬមិនហ៊ានពិភាក្សាគ្នាទេ គ្រាន់តែនិយាយលេងប៉ុណ្ណោះ ពេលនោះ ខ្ញុំមានអារម្មណ៍វេទនាដែរ ប៉ុន្តែមិនដឹងធ្វើម៉េច។ យើងមិនហ៊ាននិយាយទេ គឺយើងធ្វើគ ធ្វើថ្លង់ ដាំដើមគប្រសើរជាង។ គ្មានចង់បានអ្វី គឺចង់បានតែរស់”។ នៅពេលដែលលោកនិយាយថាលោកធ្វើគ ធ្វើថ្លង់ ដាំដើមគហ្នឹង លោកចង់មានន័យថាម៉េច ហេតុអីបានជាចាំបាច់ត្រូវតែធ្វើគ ធ្វើថ្លង់នោះ?

**ឆ៖** អាហ្នឹង ភាសាហ្នឹងខ្ញុំចាំពីលោកគ្រូខ្ញុំផ្តាំ ព្រោះខ្ញុំពេលនោះក្មេង ខ្ញុំអត់ដឹងថាយ៉ាងម៉េចទេ ខ្ញុំសួរថា “ម៉េចទេ គេហៅរបបហ្នឹងគេធ្វើម៉េចខ្លះ?” គាត់ថាគាត់ផ្តាំសិស្សទៅវិញ “ប្អូនទៅវិញ គឺគ្មានអីជាជាងដើមគទេ ធ្វើគ ធ្វើថ្លង់ ធ្វើម៉េចឲ្យតែរស់ទៅ”។ គាត់ផ្តាំអ៊ីចឹង បានជាខ្ញុំចងចាំមក ព្រោះពេល

នោះ ខ្ញុំមិនបានជ្រៅថារឿងនយោបាយហ្នឹងយ៉ាងម៉េច អីយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ។

**ស៖** នេះជាអ្វីដែលខ្ញុំចង់សួរលោក។ ខ្ញុំនឹងអាននូវសំណួរ-ចម្លើយ។ សំណួរដែលគេសួរលោកហ្នឹង គឺគេសួរលោកដូចតទៅ។ លោកមានប្រសាសន៍ថា មិនបានពិភាក្សា -- ប្រជុំពិភាក្សាអី។ "ដូច្នេះ តើលោកដឹងថាមានការយកមនុស្សទៅសម្លាប់ដែរឬទេ? លោកឆ្លើយថា៖ លោកគ្រូផ្តាំខ្ញុំថាកុម្មុយនីស្តគេឲ្យធ្វើអី ធ្វើហ្នឹងទៅកុំតតាំងជាមួយគេ ប្អូនឯងត្រូវដាំដើមគដើម្បីរស់។ ប្រសិនបើយើងមានគំនិតចង់កែប្រែ ឬផ្តល់ជាគំនិត ប្រាកដជាយ៉ាប់ខ្លួនហើយ"។ ហើយអម្បាញ់មិញនេះ លោកទើបតែនិយាយឡើងវិញអំពីអ្វីដែលគ្រូរបស់លោកផ្តាំ។ អ៊ីចឹង តើលោកអាចជម្រាបបានទេថា ពេលនោះគ្រូរបស់លោកហ្នឹងគាត់ពិតជាផ្តាំលោក គាត់ពិតជាផ្តាំលោកថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ ព្រោះខ្ញុំឧស្សាហ៍សុំរៀននៅផ្ទះគាត់ ព្រោះខ្ញុំមនុស្សវាអត់សូវចេះអីប៉ុន្មានទេ ខ្ញុំក្មេងផង ខ្ញុំឧស្សាហ៍ទៅរៀននឹងគាត់ៗផ្តាំថា "បើចង់ចេះ ឲ្យប្រឹងរៀន"។ គាត់ស្រឡាញ់ខ្ញុំដែរព្រោះខ្ញុំឧស្សាហ៍ទៅសួរនាំគាត់។ ហើយគាត់ណែនាំហ្នឹង ពាក្យហ្នឹងដែលខ្ញុំចងចាំ។

[១៥:៤០:២០]

**ស៖** តើលោកយល់ថា ការផ្តាំផ្ញើគាត់ហ្នឹងជាដំបូន្មាន ឬក៏ជាការគំរាមប្រាប់លោកជាមុន?

**ឆ៖** ទេ ខ្ញុំគិតថានេះជាការដំបូន្មានដែលគាត់ផ្តាំដើម្បីយើងបានសុខ ព្រោះខ្ញុំក្មេង ពេលនោះខ្ញុំមិនយល់ មិនសូវដឹងអ្វីផងដែរ។

**ស៖** មូលហេតុដែលខ្ញុំអានសំណួរឲ្យលោកស្តាប់ហ្នឹង គឺថាខ្ញុំចង់សួរលោកថា ហេតុអ្វីបានជាលោកឆ្លើយ -- ជ្រើសរើសឆ្លើយចម្លើយបែបហ្នឹងទៅនឹងសំណួរហ្នឹង ព្រោះថាគេសួរលោកៗថាតើលោកមានដឹងអំពីការយកមនុស្សទៅសម្លាប់ទេ ក៏ប៉ុន្តែលោកទៅឆ្លើយទៅវិញថា គ្រូរបស់លោកហ្នឹងផ្តាំថា "កុំឲ្យតតាំងជាមួយគេ"។ ហេតុអ្វីបានជាលោកឆ្លើយចម្លើយបែបហ្នឹងទៅនឹងសំណួរដែលគេសួរលោកអំពីការសម្លាប់មនុស្សទេ?

**ឆ៖** ព្រោះការសម្លាប់មនុស្សខ្ញុំមិនបានឃើញនឹងភ្នែក ហើយក៏មិនបានដឹងដែរ ទើបនឹងដឹងយើងសម័យនេះទេ ពីកាលនោះមិនដឹងទេ ព្រោះយើងមិនមានប្រព័ន្ធទាក់ទងអី ដើរឆ្វេចឆ្វាចអីបានទេ។ ហើយខ្ញុំចាំ គឺចាំពាក្យលោកគ្រូផ្តាំអ៊ីចឹង ក៏ខ្ញុំចាំក្នុងចិត្តមក។

**ស៖** អ៊ីចឹងខ្ញុំអាចនិយាយបានទេថា លោកព្យាយាមមិនចង់ដឹងអំពីរឿងរ៉ាវទាំងអស់ហ្នឹងទេ។ លោកព្យាយាមគេចវេះ មិនចង់ដឹងឮមែនទេ?

[១៥:៤២:៣២]

**ឆ៖** ការពិតមិនមែនព្យាយាមទេ គេចវេះ វាមិនដឹងតែម្តង។

**ស៖** ចំណុចចុងក្រោយដែលលោកនិយាយអំពីគ្រូរបស់លោកហ្នឹង លោកនិយាយថា "ប្រសិនបើយើងមានគំនិតចង់កែប្រែ ឬផ្តល់ជាគំនិតនោះ ប្រាកដជាយ៉ាប់ខ្លួនហើយ"។ នៅពេលដែលគ្រូនិយាយបែបហ្នឹង តើលោកយល់យ៉ាងម៉េចដែរនៅពេលដែលគាត់ប្រាប់ គាត់ថាប្រសិនបើមានគំនិតចង់កែប្រែ ឬផ្តល់ជាគំនិតហ្នឹង លោកប្រាកដជាយ៉ាប់ខ្លួនហើយ។ ពេលដែលគាត់ប្រាប់លោកអ៊ីចឹងហ្នឹង លោកយល់យ៉ាងម៉េចដែរនៅពេលនុ៎ង?

**ឆ៖** ខ្ញុំយល់ថាអ្វីៗទាំងអស់ មិនគួរធ្វើអ្វី មិនគួរនិយាយអ្វីទេ ខ្ញុំគិតថា ពាក្យថាដើមគ គឺថាឲ្យស្ងាត់ហើយ។ ដូច្នេះ គេឲ្យធ្វើអ្វីធ្វើហ្នឹងទៅ ធ្វើម៉េចឲ្យតែរស់។ ខ្ញុំយល់តែប៉ុណ្ណឹង។

**ស៖** លោកចង់ៗនិយាយអំពីបញ្ហាអ្វី នៅពេលដែលលោកនិយាយពីរឿងដាំដើមគហ្នឹង លោកចង់និយាយពីរឿងបញ្ហានយោបាយ ឬក៏បញ្ហាអ្វីដែលយើងត្រូវដាំដើមគហ្នឹង?

**ឆ៖** ពាក្យថា "ដើមគ"ហ្នឹង វាមិនដឹង វាមិនឮអីទាំងអស់ហ្នឹង។ ដឹងតែអ្វីដែលគេឲ្យយើងធ្វើៗហ្នឹងទៅ ក្រៅពីអ្វីដែលគេឲ្យយើងធ្វើយើងមិន -- យើងវាមិនដឹងផង ព្រោះគ្មានការងារក្រៅពីការងារបច្ចេកទេសហ្នឹងទេ តែប្អូននាក់ហ្នឹងឯង។

**ស៖** នៅថ្ងៃនេះ លោកនិយាយថាលោកហូបចុក មិនគ្រប់គ្រាន់ ហើយលោកគិតថា លក្ខខណ្ឌការងារហ្នឹងគួរឲ្យរន្ធត់ ការងារលំបាក។ តើលោកមានព្យាយាមចង់ចាកចេញពីទំនប់ ១មករាទេ? ហើយប្រសិនបើលោកចាកចេញហ្នឹង តើនឹងមានរឿងអ្វីកើតឡើង? ហើយហេតុអ្វីបានជាលោកមិនព្យាយាមចាកចេញពីទំនប់ហ្នឹង?

[១៥:៤៥:០០]

**ឆ៖** ន័យត្រង់ហ្នឹង ខ្ញុំពិបាកហ្នឹងឆ្លើយណាស់ បើសិនជាលោកជាខ្ញុំវិញ ប្រហែលជាខ្លាចជាងខ្ញុំផង។

**ស៖** ហេតុអីបានជាលោកភ័យខ្លាចមិនប៊ានរត់ចេញពីការដ្ឋានការងារហ្នឹង?

**ឆ៖** មិនដឹងជារត់ទៅណា? ពេលនោះ ខ្ញុំក្មេងផង ហើយភូមិសាស្ត្រស្រុកខ្មែរ នៅពេលនោះខ្ញុំមិនសូវស្គាល់ច្រើនផង មកតែមួយកន្លែងគេឲ្យធ្វើអី ធ្វើតែប៉ុណ្ណឹងទៅ ទៅឯណាទៀតផង។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅសំណួរពាក់ព័ន្ធទៅនឹងទំហំកម្លាំងការងារ។ ហើយខ្ញុំនឹងអានសម្រង់

ចម្លើយរបស់លោក គឺ 00389523, ជាភាសាអង់គ្លេស 00403004 ទៅដល់ 05, ជាភាសាបារាំង គឺ 00422239។ នៅក្នុងកំណត់ហេតុនោះ គេសួរលោកថា តើកម្លាំងមនុស្សប៉ុន្មាននាក់ចូលរួមលើកទំនប់? លោកឆ្លើយថា៖ “តាមដែលខ្ញុំឮ តាមឧគ្ឃោសនសព្ទគេថា កម្លាំងចូលរួមនេះ មានប្រជាជនមកពីតំបន់ ៤២ ចំនួនមួយម៉ឺននាក់, កងចល័តមកពីតំបន់៤១ មានចំនួនមួយពាន់នាក់ និងប្រជាជនមកពីតំបន់៤៣ មានមួយម៉ឺននាក់។ ដូច្នេះកម្លាំងប្រជាជនទាំងអស់ មានជាងពីរម៉ឺននាក់”។ សូមបញ្ចប់ការដកស្រង់នូវចម្លើយរបស់លោក។ តើលោកស្តាប់ឮតាមឧគ្ឃោសនសព្ទហ្នឹង ឮតែម្តងទេ ឬក៏ធ្លាប់ឮគេប្រកាសតាមឧគ្ឃោសនសព្ទហ្នឹងច្រើនដងនៅការដ្ឋានធ្វើការនោះ?

**ឆ៖** ឮម្តង ដែលគេបើកការដ្ឋានហ្នឹងឯង។

**ស៖** ក្នុងឋានៈលោកជាអ្នកវាស់ស្ទង់ហ្នឹង តើលោកមានដឹងអំពីការរៀបចំរបស់ក្រុមផ្សេងទៀតទេ? មានន័យថាក្រុមផ្សេងទៀតហ្នឹងមានកម្លាំងប៉ុន្មាននាក់អី មានទំហំប៉ុនណាអីលោកដឹងទេ?

**ឆ៖** បាទ អត់ដឹងទេលោកតុលាការ។

**ស៖** សូមអរគុណលោកសាក្សី។

**លោក គ្រាវិស ហ្វារ៖**

លោកប្រធាន ឥឡូវនេះ ខ្ញុំសូមប្រគល់វេទិកានេះ ជូនសហព្រះរាជអាជ្ញារងជាតិ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី លោក ប៊ុច សុខា។ ខ្ញុំបាទ មានសំណួរមួយចំនួនពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ តាមរយៈឯកសារ E3/403 ដែលមានERN ជាភាសាខ្មែរ 00389524, ជាភាសាអង់គ្លេស 00403006, ជាភាសាបារាំង 00422240 លោកបានលើកឡើងនៅចំពោះមុខចៅក្រមស៊ើបសួរ ស៊ើបអង្កេតថា ការលើកទំនប់គឺមានបែងចែកទៅតាមតំបន់ តាមស្រុក តាមក្រុម និងតាមបុគ្គលដែលក្នុងម្នាក់ៗជីក ២ម៉ែត្រគូប ក្នុងមួយថ្ងៃ ហើយរែកយកទៅដាក់លើខ្នងទំនប់។ តើអ្នកណាជាអ្នកបែងចែកផែនការនេះ?

**លោក ប៊ិច សុខា៖**

**ឆ៖** អ្នកបែងចែកការងារនេះ ខ្ញុំក៏មិនដឹងដែរ ប៉ុន្តែជាការ--ជាទូទៅគេប្រកាសមីក្រូអ៊ីចឹងឯង។ ត្រង់ថាអ្នកណាអ្នកបែងចែក អ្នករៀបចំឱ្យ ខ្ញុំក៏មិនដឹងដែរទេ។

**ស៖** តាមដែលលោកឆ្លើយជម្រាបជូនតុលាការមុននេះ ថាលោកបានចូលរួមជាមួយនឹង-- ក្រៅពីការងារស្ទូលរបស់លោកក្នុងការស្ទង់ដីហ្នឹង លោកបានចូលរួមជាមួយនឹងពលករផ្សេងទៀតដែរ។ អ៊ីចឹង តើនៅពេលនោះ ការរែកៗដីពីកន្លែងជីកដីមកដល់ខ្នងទំនប់ហ្នឹងមានចម្ងាយប៉ុន្មានដែរ?

[១៥:៥០:១៤]

**ឆ៖** ចម្ងាយតាមមើល វាមិនជាឆ្ងាយប៉ុន្មានទេប្រហែលជា ៥០ម៉ែត្រអីប៉ុណ្ណឹងទេ។ លើកពីដីមកដាក់លើទំនប់ហ្នឹង។ ព្រោះគេជីកប្រឡាយយកមកដាក់លើខ្នងទំនប់ វាមិនឆ្ងាយទេ។

**ស៖** ចុះចំពោះស្ថានភាពដីនៅទីនោះ ដីហ្នឹងរឹង ឬក៏ទន់?

**ឆ៖** អាហ្នឹងវាមិនកំណត់ថាកន្លែងនោះស្រួលរហូត ហើយពិបាករហូត វាមានកន្លែងពិបាក និងកន្លែងស្រួល។ វាមិនថេរទេដី។

**ស៖** បើពិបាកវិញ ពិបាកដល់កម្រិតណាដែរ?

**ឆ៖** ពិបាកកន្លែងខ្លះក៏ប៉ះថ្មដែរហ្នឹងឯង វារឹង។

**ស៖** អ៊ីចឹង ក្នុងករណីដែលប៉ះថ្មហ្នឹង តើអាចបណ្តាលឱ្យប៉ះពាល់ដល់ផែនការ ២ម៉ែត្រគូបក្នុងមួយថ្ងៃហ្នឹងទេ បើតាមបទពិសោធន៍របស់លោក?

**ឆ៖** នៅពេលនោះ ខ្ញុំគិត ហើយខ្ញុំឃើញសកម្មភាពគេធ្វើកន្លែងដែលថ្ម គេក៏មិនឱ្យអ្នកជីកហ្នឹងខុសដែរ។ គេស៊ីរ៉េកន្លែងហ្នឹងឱ្យអ្នកកម្លាំងពលកម្មមនុស្សឱ្យទៅជីកដី ឯកន្លែងថ្មគេប្រើរំសេវចុចហើយ។

**ស៖** ចំពោះផែនការ ២ម៉ែត្រគូប ក្នុងមួយថ្ងៃនេះ តើការបែងចែកនេះគេបែងចែកទៅតាមអាយុ តាមភេទ ឬក៏សុខភាពរបស់ពលករហ្នឹង ឬក៏កិច្ចការហ្នឹងត្រូវបានបែងចែកស្មើៗគ្នាទាំងអស់?

**ឆ៖** រឿងបែងចែកលម្អិត ខ្ញុំមិនដឹងទេ ប៉ុន្តែដឹងថាជាទូទៅគឺ ២ម៉ែត្រគូប ប៉ុណ្ណឹង។

**ស៖** តើចំពោះផែនការដែលបានដាក់មកនេះ តើលោកធ្លាប់ឃើញមានអ្នកបដិសេធមិនទទួលយល់ព្រមចំពោះផែនការនេះទេ?

**ឆ៖** អូ៎! ការងារហ្នឹងខ្ញុំអត់ដឹង ព្រោះខ្ញុំចូលរួមម្តងម្កាល មិនអាចដឹងដល់លម្អិតអីទេ អត់ដឹងទេ។

[១៥:៥២:២៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវីការពារក្ដីលោក នួន ជា -- ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសុំរំឭក គឺថាសុំឱ្យបង្អង់បន្តិចពេលដែលសួរហើយហ្នឹង ពេលឆ្លើយបន្ថយ បង្អង់ពេលបន្តិច ព្រោះថាដល់ពេលមានបក *វីឡេ* ទៅបាត់។ ពេលបកពីអង់គ្លេសទៅបារាំងហ្នឹងពិបាក លោកប្រធាន។ អ៊ីចឹង សុំឱ្យគូសន្ទនាទាំងពីរហ្នឹងបង្អង់ពេលបន្តិចរវាងសំណួរ និងចម្លើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអំមិញនេះ មានបានជម្រាបដោយផ្ទាល់ បានធ្វើសញ្ញាជម្រាបហើយ ប៉ុន្តែគាត់ស្ដាប់មិនយល់តាមមើល។ សុំលោកអនុវត្តដូច្នេះ គឺសុំឱ្យមានការឃ្លាតគ្នាបន្តិចរវាងការឆ្លើយហើយនិងការសួរ ហើយការសួរក៏សុំឱ្យយឺតៗដែរដើម្បីឱ្យបកប្រែទាន់ ព្រោះអំមិញនេះបកប្រែភាសាមិនទាន់។

**លោក ស្រ៊ា រតនៈ៖**

បាទ ខ្ញុំនឹងអនុវត្តតាមនេះលោកប្រធាន។ តាមពិតខ្ញុំឃើញសញ្ញាខ្ញុំយល់ដែរ ខ្ញុំព្យាយាមបន្ថយដែរ ប៉ុន្តែការបន្ថយនេះនៅតែអត់ទាន់។ អ៊ីចឹង ខ្ញុំព្យាយាមឱ្យកាន់តែយឺតជាងនេះទៀត បាទ។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ចំពោះផែនការ ២ម៉ែត្រគូបក្នុងមួយថ្ងៃនេះ តើលោកធ្លាប់ជួបប្រទះការអនុវត្តមិនទាន់ផែនការដែរទេ?

**ឆ៖** ការងារហ្នឹង រឿងហ្នឹង ព្រោះខ្ញុំមិនមែនស្ថុលជាអ្នកធ្វើការងាររែកដីផ្ទាល់ទេ។ ខ្ញុំជាអ្នកដើរស្ទង់ដី។ អ៊ីចឹង រឿងអ្នកធ្វើគ្រប់ ឬមិនគ្រប់ ខ្ញុំមិនដឹងដែរការងារទីនោះ។

[១៥:៥៤:២៥]

**ស៖** ចុះនៅពេលដែលៗលោកចុះជួយ ចុះទៅបំពេញការងារដូចពលករផ្សេងទៀតនោះ តើលោកទទួលផែនការដូចពលករផ្សេងទៀតហ្នឹង ឬក៏ជាការងារបន្ថែមដោយឡែក?

**ឆ៖** សម្រាប់ពួកខ្ញុំ --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយៗ លោក -- សូមអញ្ជើញលោក វិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថានេះគឺជាលើកទី៣ហើយ ដែលព្រះរាជអាជ្ញាជាតិព្យាយាមសួរសំណួរអំពីការងារដែលសាក្សីរូបនេះគាត់បំពេញដោយចៃដន្យនោះទេ។ គាត់បាននិយាយហើយថា គាត់ជាវាស់ស្ទង់ ដូច្នេះគាត់មិនដឹងអំពីខ្លឹមសារនោះទេ ហើយក៏បាននិយាយច្រើនដងហើយ។ ដូច្នេះខ្ញុំគិតថាវាមិនមានហេតុផលអ្វីត្រូវសួរសំណួរនេះដដែលៗឡើងវិញនោះទេ។ ខ្ញុំសូមជំទាស់ដោយសារសំណួរនេះវាសួរដដែលៗឡើងវិញ។

**លោក ស្រ៊ា រតនះ៖**

ខ្ញុំយល់ឃើញថាសំណួរនេះគាត់មានការពាក់ព័ន្ធ គាត់បានឆ្លើយហើយថាគាត់បានចូលធ្វើការ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់ដឹង មិនមែនជារឿងចៃដន្យគាត់ធ្វើម្តងម្កាលនោះទេ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់ដឹងថាតើក្រៅពីកិច្ចការនេះ គាត់ទទួលបានផែនការបន្ថែមឬយ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់ ហើយសាក្សីឆ្លើយតបនឹងសំណួរចុងក្រោយដែលសួរឡើងដោយសហព្រះរាជអាជ្ញារងជាតិ។ អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយតបនឹងសំណួរនេះ។

**លោក ប៊ិច សុខា៖**

**ឆ៖** សំណួរអំមិញនេះ ខ្ញុំសូមជម្រាបលោកតុលាការថា មិនមែនជាការងារស្នូលរបស់ពួកខ្ញុំទេ។ ពេលដែលអត់មានការងារធ្វើទៅចូលរួមម្តងម្កាល តែក៏មិនបានគេកំណត់ថាឲ្យពួកខ្ញុំធ្វើ ២ម៉ែត្រគូបអីដូចគេដែរ ធ្វើតាមលទ្ធភាព ដល់ម៉ោងឈប់ៗទៅ។ មានប៉ុណ្ណឹង។

[១៥:៥៦:៤៩]

**សួរដោយលោក ស្រ៊ា រតនះ៖**

**សះ** នៅក្នុងឯកសារ E3/403 ដដែលហ្នឹង ដែលមាន ERN ជាភាសាខ្មែរ 00389524, ជាភាសាអង់គ្លេស 00403006, ជាភាសាបារាំង 00422240 លោកបានរៀបរាប់ថា “នៅពេលយប់ធ្វើពីម៉ោង ៦:៣០នាទីដល់ម៉ោង១០”។ លោកបន្តថា៖ “ខ្ញុំគិតថាអ្នកទាំងនោះធ្វើគ្រប់តាមផែនការ តែបើមិនគ្រប់តាមផែនការ លុះត្រាតែអ្នកនោះឈឺ ឬបើអ្នកនោះធ្វើមិនបានហើយនៅពេលថ្ងៃ គឺអាចបន្តនៅពេលយប់ ដោយមានភ្លើងបំភ្លឺ”។ បើតាមបទពិសោធន៍របស់លោកដែលរស់នៅការដ្ឋានទំនប់ ១មករានោះ តើពលករភាគច្រើនបន្តធ្វើការនៅពេលយប់ ឬក៏ពួកគេភាគច្រើនបានបញ្ចប់ការងារនៅពេលថ្ងៃ

ព្រមៗគ្នា?

**ឆ៖** ការងារនៅពេលយប់ -- តាមពេលនោះខ្ញុំក៏មិនដឹងរឿងលម្អិលយ៉ាងណាដែរ ប្រហែលជាខ្ញុំគិតថាវាជាការសម្រុកបន្ថែមអីម្តងម្កាលទេ ប៉ុនគ្រាន់ថា បើភាគច្រើនគេធ្វើការងារនៅពេលថ្ងៃ។

**ស៖** ចុះការងារពេលថ្ងៃធម្មតាហ្នឹងចាប់ធ្វើការនៅម៉ោងប៉ុន្មាន ហើយឈប់សម្រាកនៅម៉ោងប៉ុន្មាន?

**ឆ៖** តាមចាំបានម៉ោងប្រាំពីរកន្លះគេធ្វើហើយ ធ្វើរហូតដល់ម៉ោងដប់មួយកន្លះគេសម្រាក។ ដល់ម៉ោងមួយ ម៉ោងប្រហែលមួយកន្លះហ្នឹង គេធ្វើការបន្តទៀតហើយ ម៉ោងប្រាំគេឈប់។

**ស៖** ករណីមួយទៀតពាក់ព័ន្ធនឹងរបបអាហារ លោកក៏បានលើកឡើងដែរពីមុននេះបន្តិចថា អាហារហូបចុកមិនគ្រប់គ្រាន់។ តើខ្ញុំចង់ដឹងថាតើអាហារហូបចុកមិនគ្រប់គ្រាន់ហ្នឹងជាអ្វីទៅ? លោកទទួលបានអ្វីសម្រាប់ហូប?

[១៥:៥៩:៣៧]

**ឆ៖** អាហារហូបចុកដែលអ្វីដែលខ្ញុំចង់ មិនចង់និយាយរឿងអ្នកណាផ្សេងគឺខ្ញុំមិនដឹងទេ សម្រាប់ខ្លួនខ្ញុំ ពេលខ្លះក៏បាយលាយដំឡូង ខ្លះបាយលាយចេក ពេលខ្លះក៏ខ្វះខាតទៅ មានតែបបរអីចឹងទៅ។ នេះហើយហៅថាមិនគ្រប់គ្រាន់ ឯម្ហូបម្ហាគេមិនមែនដូចយើងចង់ដូចសម័យឥឡូវ ចង់គុយទាវ កាហ្វេ អីចេះណា ឱ្យហូបអីហូបហ្នឹង។ នេះឯងដែលហៅថាមិនគ្រប់គ្រាន់។

**ស៖** តើបើតាមការសង្កេតរបស់លោកមានអ្នកស្លាប់ដោយសារការហូបចុកមិនគ្រប់គ្រាន់ហ្នឹងទេ?

**ឆ៖** សម្រាប់ខ្ញុំឱ្យនឹងភ្នែក ដូចមិនដែលឃើញទេ ព្រោះអ្នកជំងឺ តែឈឺគេបញ្ជូនយកទៅពេទ្យបាត់ហើយ។

**លោក ស្រ៊ា រតនៈ៖**

សូមជម្រាបលោកប្រធាន ខ្ញុំបាទនៅសល់សំណួរប្រហែល -- មានសំណួរពីរឬបីទៀតប៉ុណ្ណោះដែលចំណាយពេលប្រហែលជា៥នាទី។

**សួរដោយ លោក ស្រ៊ា រតនៈ៖**

**ស៖** ដោយសារលោកបានលើកឡើងអំពីអ្នកជំងឺ តើនៅពេលហ្នឹង ហើយនិងថ្នាំពេទ្យមានគ្រប់គ្រាន់ឬទេ?

**ឆ៖** ពេលនោះ ថាបើយើងប្រៀបធៀបនៅសម័យនោះគឺយើងមិនដឹងថាវា -- ហើយកាលនោះខ្ញុំវាមិនមែនជាពេទ្យផង មិនដឹងថាវាថ្នាំប៉ុណ្ណឹង ឃើញប៉ុណ្ណឹងថាគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ មិនបានដឹងដែរទេ ប៉ុន្តែខ្ញុំគិតថាថ្នាំនៅពេលនោះ សម្រាប់ឱ្យយើងឈឺពោះ ឈឺក្បាលអី គេមានថ្នាំឱ្យ។

[១៦:០១:២៦]

**ស៖** ដើម្បីជួយសម្រួលដល់ការឆ្លើយរបស់លោក ចំពោះសំណួរអម្បាញ់មិញនេះ ខ្ញុំចង់សួរថា តើពេទ្យមានជំនាញគ្រប់គ្រាន់ដែរឬទេ? ជាពេទ្យដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវតាមវិជ្ជាជីវៈ ឬក៏យ៉ាងណា?

**ឆ៖** ទាក់ទងនឹងសំណួរនេះ ខ្ញុំពិបាកឆ្លើយហើយណាស់ ព្រោះអីបណ្តុះបណ្តាលគ្រប់គ្រាន់ៗ ខ្ញុំមិនដឹងដែរ ហើយក៏ស្លៀកពាក់ខោអាវខ្មៅដូចគ្នាៗ ដឹងយ៉ាងម៉េចផង។ ថាពេទ្យក៏ពេទ្យទៅ។

**ស៖** ចំពោះការស្នាក់នៅ លោកបានបញ្ជាក់មុននេះបន្តិចថា ការស្នាក់នៅ ក្រុមលោកមានការស្នាក់នៅដាច់ពីប្រជាជនពលរដ្ឋ ពីប្រជាពលករទាំងនោះ។ តើការស្នាក់នៅរបស់លោកហ្នឹងយ៉ាងដូចម្តេចដែរកាលពីសម័យនោះ? លោកស្នាក់នៅកន្លែងណា?

**ឆ៖** ពាក្យថា "នៅ" នៅហ្នឹង គឺមិននៅដាច់ពីប្រជាជនទៅរាប់គីឡូ គឺវានៅក្នុងចំណោមជាមួយគ្នាហ្នឹង ប៉ុន្តែគ្រាន់តែពួកខ្ញុំមានរោងមួយ រោងធ្វើពីដំបូលស្លឹកត្នោតយើងហ្នឹង វាមិនមែនអីពិសេសក្តារជញ្ជាំងអីហំហានទេ ហើយរនាបឫស្សីដេកដូចតែគ្នាហ្នឹង ប៉ុន្តែគ្រាន់តែរោងដាច់ដោយឡែកតែប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំចង់ដឹងពីស្ថានភាពនៃរោងនោះ ហើយនិងរបៀបស្នាក់នៅ តើសូមលោកជួយបញ្ជាក់ឱ្យបានច្បាស់ជាងនេះបន្តិច?

[១៦:០៣:០១]

**ឆ៖** ខ្ញុំដូចជាមិនដឹងជាបរិយាយ ឬក៏អត្ថាធិប្បាយយ៉ាងម៉េចខុសពីប៉ុណ្ណឹងទេ គ្រាន់តែរោងដាច់ដោយឡែក ពីប្រជាជន ប៉ុន្តែមិននៅឆ្ងាយទេ នៅជាមួយតែគ្នាហ្នឹង ប៉ុន្តែគ្រាន់រោងពួកខ្ញុំហ្នឹងមានគ្នាបួននាក់ អ្នកបច្ចេកទេសហ្នឹង ហើយរនាបធ្វើពីឫស្សី ដំបូលគឺស្លឹក ប៉ុណ្ណឹង។ អត់មានស្អីពិសេសអីទៀតទេ ជម្រាបជូនលោកតុលាការប៉ុណ្ណឹង។

**ស៖** តើមានមុង មានភួយ មានខ្នើយសមរម្យ ដូចសម័យបច្ចុប្បន្នទេ?

**ឆ៖** បើមកប្រៀបធៀបដូចសម័យបច្ចុប្បន្ន វាម៉េចដូច។ វាមិនដូចទេ។

**ស៖** សូមលោកឆ្លើយឱ្យចំនឹងសំណួរខ្ញុំ។ សូមឆ្លើយបញ្ជាក់ថា តើមានមុង មានភួយ មានខ្នើយ មានកន្ទេល ដែលសម្រាប់ស្នាក់នៅ -- សម្រាប់ពេលលោកសម្រាកហ្នឹងឬទេ?

**ឆ៖** ពួកខ្ញុំពេលនោះ គឺគ្រែ វាគ្រាន់ជាគ្រែ តែការពិតសម្រាកលើអង្រឹងទេ ចង់អង្រឹងដេកទេ ព្រោះអីពួកខ្ញុំមិនសូវបាននៅនឹងរោងផង ហើយសូម្បីមករោងកន្លែងធ្វើការខ្លួន ក៏ចងអង្រឹងដេកមួយម្នាក់ៗគ្រប់គ្នាអីចឹង។

**ស៖** ដោយសារលោកបញ្ជាក់ថា លោកនៅមិនឆ្ងាយពីប្រជាជនផ្សេងទៀត។ តើស្ថានភាពប្រជាជនផ្សេងទៀតហ្នឹង ស្ថានភាពរស់នៅរបស់ពួកគាត់យ៉ាងដូចម្តេចដែរ?

**ឆ៖** ស្ថានភាពរបស់ពួកគាត់ យើងមើលឃើញនឹងភ្នែក ឃើញគាត់ជាផ្ទះរួម។ រោងវែងៗអីចឹងទៅ រនាបឫស្សីទៅ ពួកគាត់នៅគ្នាទៅ។ រោងរបស់ស្រីៗគេមានរោងគេផ្សេង ប្រុសៗរោងគេផ្សេង។ នេះតាមខ្ញុំឃើញ។

[១៦:០៥:០១]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅវ៉ិចទ័រ -- លោក វ៉ិចទ័រ កូប៉េ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាដោយសារតែសាក្សីផ្តល់ចម្លើយទៅហើយ។ ដូច្នេះ ខ្ញុំមិនមានអ្វីជំទាស់ទៀតទេ ប៉ុន្តែព្រះរាជអាជ្ញាជាតិ តំណាងព្រះរាជអាជ្ញា គាត់បានសួរអំពីស្ថានភាពមនុស្សប្រហែល ២០.០០០នាក់។ ដូច្នេះ គឺវាហួសពីអ្វីដែលសាក្សីនោះគាត់អាចដឹង។ ខ្ញុំគិតថាតំណាងសហព្រះរាជអាជ្ញាជាតិ គួរតែមានការប្រុងប្រយ័ត្ននៅពេលដែលសួរអំពីអ្វីដែលបានកើតឡើង ព្រោះថាយើងមានក្រុមជាច្រើន យើងដឹងហើយព្រឹកមិញថាមានក្រុមជាច្រើនមកពីភូមិផ្សេងៗគ្នា ដូច្នេះការសួរអំពីអាហារ អំពីជម្រក ដែលសួរជាទូទៅអំពីមនុស្ស ២០.០០០នាក់ហ្នឹង គឺគួរតែឱ្យមានការច្បាស់លាស់។ ដូច្នេះព្រះរាជអាជ្ញា -- តំណាងព្រះរាជអាជ្ញាជាតិគួរតែសួរឱ្យបានជាក់លាក់ ឱ្យបានច្បាស់លាស់បន្តិច។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ តាំងសំណួរទៀតទៅ ទំនងជាការបកប្រែភាសាខ្មែរ -- ភាសាបរទេសមិនដឹងទេ ប៉ុនភាសាខ្មែរគាត់បាននិយាយច្បាស់លាស់ហើយតាមការសង្កេតរបស់គាត់ អ្នកដែលធ្វើរោងប្រជាជននៅក្បែរៗគាត់ហ្នឹង វាមានស្ថានភាពយ៉ាងម៉េចដែរ។ អីចឹងគាត់សួរតែក្នុងក្របខ័ណ្ឌអ្នកដែលធ្វើរោងរស់នៅក្បែរៗ

ដែលកន្លែងគាត់រស់នៅទេ។ សំណួរនេះ គឺអាចសួរបានអត់មានបញ្ហាអីទេ។ អញ្ជើញបន្តទៀត!

**លោក ស្រ៊ា រតនៈ៖**

ខ្ញុំបាទអស់សំណួរហើយលោកប្រធាន។

[១៦:០៦:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២១ ខែឧសភា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ប៊ិច សុខា តាមរយៈប្រព័ន្ធសោតទស្សន៍ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះអរគុណ លោក ប៊ិច សុខា ដំណើរការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីមិនទាន់ចប់នៅឡើយទេ ហើយអង្គជំនុំជម្រះកោះអញ្ជើញលោក ឲ្យបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀតនៅទីកន្លែងដែលលោកកំពុងអង្គុយផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅទីនោះ ដែលនឹងចាប់ផ្ដើមចាប់ពីម៉ោងប្រាំបួនព្រឹក។ ពេលនេះលោកអាចសម្រាកបានហើយ លោក ប៊ិច សុខា។

**លោក ប៊ិច សុខា៖**

អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកចុះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបមកចូលរួមសវនាការនៅក្នុង -- នៅសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៨ នាទី)*